សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ហែម សៅម៉ានិច**
កញ្ញា **គាត់ ចាន់ធី**

សាស្ត្រាចារ្យណែនាំ
លោកបណ្ឌិត **អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **ហែម សៅម៉ានិច** និងនាងខ្ញុំឈ្មោះ **តាក់ ចាន់ធី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ ជំនាន់ទី១២ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៨-២០១៩។ កូនសូមថ្លែងអំណរគុណចំពោះ៖

| | |
|---|---|
| **លោកឪពុក ជា ស៊ាងយន** | **លោកឪពុក តាក់ វិញ** |
| **អ្នកម្ដាយ ឡុង គឹមស្រ៊ី** | **អ្នកម្ដាយ ស៊ូ សាន** |

កូនសូមសម្ដែងនូវមហាកតញ្ញូតាធមិជាអនេកប្បការ ចំពោះលោកអ្នកមានគុណទាំងពីរ ដែលបានផ្ដល់កំណើត និងខិតខំបីបាច់ថែរក្សាចិញ្ចឹមរូបកូនតាំងពីក្នុងផ្ទៃ រហូតដល់កូនក្លាយជាយុវត្តីពេញរូបរាង ព្រមទាំងបានទទួលនូវការអប់រំទូន្មានតាំងពីបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សានេះ។ ព្រះគុណដ៏មហាបវរនេះគឺធ្វើឲ្យកូនចងចាំ និងគ្មានអ្វីអាចបំភ្លេចបានឡើយ។ កូនសូមលើកហត្ថប្រណម្យគោរពប្រណិប័តន៍ផ្ញើស្មាដៃនេះ ជូនចំពោះលោកទាំងពីរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់។

សូមគោរពចំពោះ **ឯកឧត្ដមសាកលវិទ្យាធិការ លុយ ចណ្ណា** ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស អស់លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពស់ និងជួយតម្រង់ទិសដល់យើងខ្ញុំ តាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

ជាពិសេសសូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សកក្កដា** ដែលបានចំណាយពេលវេលាទាំងកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី ដោយបានណែនាំអំពីអត្ថន័យខ្លឹមសារ ឃ្លាឃ្លោង និងផ្ដល់គំនិតល្អៗ សំរាប់តាក់តែង រៀបរៀងអត្ថបទសារណានេះ ចាប់តាំងពីដំណាក់កាលនៃការរៀបរៀងចាប់ផ្ដើម រហូតដល់បានសម្រេចជាស្ថាពរ។

ជាបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរ សិរីមង្គលបវរមហាប្រសើរ កើតមានចំពោះលោកអ្នកមានគុណ បងប្អូនសាច់ញាតិ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ ព្រមទាំងក្រុមគ្រួសារឲ្យជួបប្រទះតែពុទ្ធិពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណានេះតាក់តែងឡើង ដើម្បីជាជំនួយដល់ការសិក្សាសម្រាប់ ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ គឺជាលទ្ធផលដែលកើតចេញមកពីការខិតខំប្រឹងប្រែង បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងអស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីអំពី "ការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ" ដើម្បីបន្សល់ទុកជាឯកសារស្រាវជ្រាវសម្រាប់ជូនសិស្ស និស្សិត និងបណ្តាអ្នកសិក្សាស្រាវជ្រាវទាំងឡាយ ដែលមានបំណងធ្វើការចងក្រងជាសារណានេះទុក។ ការសរសេរជាសារណា ដើម្បីបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរនេះ យើងខ្ញុំទាំងពីរបានទទួលបានការដឹកនាំដោយ **លោកបណ្ឌិត អ៊ុន សកក្កដា** និងទទួលបាននូវការសហការផ្តល់ជាឯកសារនានា ការណែនាំការផ្តល់គំនិតយោបល់ល្អៗ ជាពិសេសការជ្រោមជ្រែង និងការផ្តល់មតិយោបល់ល្អៗពីលោកប្រធានផ្នែកគ្រប់គ្រងកាកសំណល់រឹងនៃមន្ទីរបរិស្ថានរាជធានីភ្នំពេញតែម្តង។

ការសម្រេចចិត្តជ្រើសរើស ប្រធានបទខាងលើមកសិក្សាស្រាវជ្រាវ ជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ដោយសារតែយើងខ្ញុំយល់ឃើញថា វាពិតជាមានសារៈសំខាន់ណាស់សម្រាប់បរិស្ថាន ក្នុងនោះមានបង្ហាញនូវចំណេះដឹង និងវិធីសាស្ត្រនៃការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋខ្មែរ និងជួយបណ្តុះគំនិត អ្នកដែលបានអានអត្ថបទមួយនេះឲ្យមានចិត្តស្រលាញ់ និងជួយការពារបរិស្ថានឲ្យបានល្អ និងចាំបាច់ត្រូវមានការចូលរួមពីប្រជាពលរដ្ឋម្នាក់ៗ ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងផ្ទាល់ និងការធ្វើឲ្យទីក្រុងមានសោភ័ណ្ឌភាព និងអាចជាគំរូដល់កូនចៅជំនាន់ក្រោយ។

ការសិក្សាស្រាវជ្រាវអត្ថបទមួយនេះ ត្រូវបានចាប់ផ្តើមឡើងដោយ ការសិក្សាតាមរយៈ ឯកសារច្បាប់មួយចំនួនដែលពាក់ព័ន្ធនឹងបរិស្ថាន ការប្រមូលព័ត៌មានតាមរយៈកាសែត សៀវភៅណែនាំនានា ដែលទាក់ទងនឹងបរិស្ថាន តាមរយៈប្រព័ន្ធអ៊ីធឺណេត ព្រមទាំងការចុះទៅស្រាវជ្រាវឯកសារដោយផ្ទាល់នៅមន្ទីរបរិស្ថានរាជធានីភ្នំពេញ ជាមួយនឹងយោបល់អំពីនីតិវិធី ក្នុងការដោះស្រាយបញ្ហារបស់មន្ត្រីនៃមន្ទីរបរិស្ថាន ដែលអនុលោមពីក្រសួងបរិស្ថាន យកមកច្របាច់បញ្ចូលគ្នាក្នុងគោលបំណងឆ្លុះបញ្ចាំងឲ្យឃើញនូវ ប្រភពដែលនាំឲ្យកើតមានផលប៉ះពាល់ និងចន្លោះខ្វះខាតមួយចំនួនដែលកើតមានចំពោះបរិស្ថាន។

ជាចុងក្រោយ បើទោះបីជាយើងខ្ញុំមានការខិតខំសិក្សាស្រាវជ្រាវ និងត្រួតពិនិត្យយ៉ាងម៉ត់-ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរសារណាមួយនេះ នៅតែមានចន្លោះខ្វះខាត ដូច្នេះ យើងខ្ញុំទាំងពីរសុំអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងដោយអចេតនាទាំងឡាយណា ដែលមានកើតមាន

ឡើងក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ របស់យើងខ្ញុំទាំងពីរ និងត្រៀមខ្លួនជានិច្ចដោយរង់ចាំទទួលនូវមតិរិះគន់កែលម្អក្នុងន័យស្ថាបនាយ៉ាងខ្ពង់ខ្ពស់ពីសំណាក់សិស្ស និស្សិត អ្នកស្រាវជ្រាវ និងមិត្តអ្នកអានទាំងអស់ ដើម្បីជួយផ្តល់ជាមតិ និងគំនិតល្អៗបន្ថែមទៀត ក្នុងការកែលម្អសារណានេះ ឲ្យកាន់តែមានលក្ខណៈល្អប្រសើរថែមទៀតផង។ ក្រោយពីបានសិក្សាស្រាវជ្រាវបញ្ចាប់ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះ នឹងក្លាយជាឯកសារមួយដែលចូលរួមចំណែក និងជំរុញឲ្យបរិស្ថានកាន់តែមានភាពល្អប្រសើរ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ........ ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
៣. គោលបំណងនៃការស្រាវជ្រាវ ........ ១
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
៥. សារៈសំខាន់នៃការស្រាវជ្រាវនេះ ........ ២
៦. វិធីសាស្ត្រនៃកាស្រាវជ្រាវ ........ ២
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២

## ជំពូកទី១

## បរិស្ថាននៅរាជធានីភ្នំពេញ

**១.១. សញ្ញាណទូទៅនៃបរិស្ថាន** ........ ៣
១.១.១. និយមន័យបរិស្ថាន ........ ៣
១.១.២. ប្រភេទនៃបរិស្ថាន ........ ៣
១.១.២.១. បរិស្ថានធម្មជាតិ ........ ៣
១.១.២.២. បរិស្ថានសង្គម-វប្បធម៌ ........ ៣
**១.២. ស្ថានភាពបរិស្ថាននៅរាជធានីភ្នំពេញ** ........ ៤
១.២.១. ប្រភពដែលនាំឲ្យមានការបំផ្លាញដល់បរិស្ថាន ........ ៤
១.២.១.១. កាកសំណល់រឹង ........ ៤
១.២.១.២. ការសំណល់រាវ ........ ៥
ក. ប្រភពរាយប៉ាយ ........ ៥
ខ. ប្រភពចំណុច ........ ៦
១.២.១.៣. ការបំពុលខ្យល់ ........ ៦
ក. ការបំពុលពីរោងចក្រ ........ ៦
ខ. ការបំពុលពីយានយន្ត ........ ៧
គ. ការបំពុលដោយធូលី ........ ៧

ឃ. ការបំពុលដោយចំហេះអុស ធ្យូង ..... ៧
១.២.២. មូលហេតុដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន ..... ៨
១.២.២.១. បញ្ហាថង់ប្លាស្ទិក និងការវេចខ្ចប់ ..... ៨
១.២.២.២. ការដុតកាកសំណល់ ..... ៩
**១.៣. ផលប៉ះពាល់បរិស្ថាននៅក្នុងរាជធានីភ្នំពេញ** ..... ៩
១.៣.១. ការសំណល់រឹង ..... ៩
១.៣.២. កាកសំណល់រាវ ..... ១០
១.៣.៣. ការបំពុលខ្យល់ ..... ១១

## ជំពូកទី២

## ការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ

**២.១. សមត្ថកិច្ចក្នុងការគ្រប់គ្រងបរិស្ថាន** ..... ១២
២.១.១. រដ្ឋបាលថ្នាក់ជាតិ ..... ១២
២.១.១.១. សំណល់រឹង ..... ១២
២.១.១.២. សំណល់រាវ ..... ១៣
២.១.១.៣. ការបំពុលខ្យល់ ..... ១៥
២.១.២. រដ្ឋបាលថ្នាក់ក្រោមជាតិ និងមូលដ្ឋាន ..... ១៦
២.១.២.១. សំណល់រឹង ..... ១៦
ក. រដ្ឋបាលរាជធានី ..... ១៦
ខ. រដ្ឋបាលខណ្ឌ សង្កាត់ក្នុងរាជធានី ..... ១៧
គ. រដ្ឋបាលក្រុង ..... ១៨
ឃ. មន្ទីរបរិស្ថានរាជធានី ..... ១៩
២.១.២.២. សំណល់រាវ ..... ១៩
ក. រដ្ឋបាលរាជធានី ..... ២០
ខ. រដ្ឋបាលខណ្ឌ ..... ២០
គ. រដ្ឋបាលក្រុង ..... ២១
ឃ. មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីខេត្ត ..... ២២
ង. មន្ទីរបរិស្ថានរាជធានី ខេត្ត ..... ២២
**២.២. ការគ្រប់គ្រងសំរាមនៅរាជធានីភ្នំពេញ** ..... ២៣

២.២.១. វិធីសាស្ត្រចោលសំរាមដោយប្រជាពលរដ្ឋ ..... ២៣
២.២.២. វិធីសាស្ត្រគ្រប់គ្រងសំរាមប្រើប្រាស់ដោយរដ្ឋាភិបាល ..... ២៤
២.២.២.១. ទីលានចាក់សំរាម ..... ២៤
២.២.២.២. ការកែច្នៃ ..... ២៤
២.២.២.៣. ឡដុត ឬរោងចក្រដុតសំរាម ..... ២៥

**ជំពូកទី៣**

**ដំណោះស្រាយ និងវិធានការនៃការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ**

**៣.១. ដំណោះស្រាយនៃការគ្រប់គ្រងបរិស្ថាន** ..... ២៦
៣.១.១. សំណល់រឹង ..... ២៦
៣.១.១.១. ការញែកសំណល់ ..... ២៦
៣.១.១.២. ការប្រមូល និងដឹកជញ្ជូន ..... ២៧
៣.១.១.៣. ការកែច្នៃ ..... ២៨
៣.១.១.៤. ការបោះបង់ចោល ..... ២៨
៣.១.១.៥. ការស្តុកទុកបណ្តោះអាសន្ន ..... ២៩
៣.១.២. សំណល់រាវ ..... ៣០
៣.១.៣. ការបំពុលខ្យល់ ..... ៣០
**៣.២. វិធានការទូទៅនៃការគ្រប់គ្រងបរិស្ថាន** ..... ៣១
៣.២.១. សំណល់រឹង ..... ៣១
៣.២.១.១. ការធ្វើឲ្យប្រសើរឡើងនូវសេវាប្រមូលសំណល់ និងការសម្អាត ..... ៣១
៣.២.១.២. កែប្រែឥរិយាបថបញ្ចេញសំណល់ និងកន្លែងទុកដាក់សំណល់ ..... ៣៣
៣.២.១.៣. គាំទ្ររដ្ឋបាលខណ្ឌ/សង្កាត់ ដើម្បីពង្រឹងការត្រួតពិនិត្យ និងការអនុវត្តន៍ ..... ៣៤
ក. បង្កើតគោលការណ៍ណែនាំពីសូចនាករការងារសំរាប់ខណ្ឌនីមួយៗ ..... ៣៤
ខ. បង្កើតក្រុមការងារ/គណៈកម្មការនៅថ្នាក់ខណ្ឌ ..... ៣៥
គ. រៀបចំឲ្យមានកម្មវិធីការអភិវឌ្ឍន៍សមត្ថភាព ..... ៣៥
ឃ. បន្តអនុវត្តន៍ភ្នាក់ងារសង្កាត់ ..... ៣៥
ង. រៀបចំក្របខណ្ឌគ្រប់គ្រង ..... ៣៥
៣.២.២. សំណល់រាវ ..... ៣៥
៣.២.៣. ការបំពុលខ្យល់ ..... ៣៧

**៣.៣. វិធានការផាកពិន័យ** ........................................................................................ ៣៨
៣.៣.១. សំណល់រឹង........................................................................................ ៣៨
៣.៣.២. សំណល់រាវ........................................................................................ ៣៨
៣.៣.៣. ការបំពុលខ្យល់........................................................................................ ៣៩
**សេចក្តីសន្និដ្ឋាន** ........................................................................................ ៤០
**អនុសាសន៍** ........................................................................................ ៤១
**ឯកសារយោង**
**ឧបសម្ព័ន**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បរិស្ថាន និងជីវិតនៅក្នុងសង្គម គឺមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត មនុស្សមានសុខភាពល្អ ឬទ្រុឌទ្រោម និងមានអាយុវែង ឬខ្លី អាស្រ័យទៅនឹងកម្រិតបរិស្ថានដែលគេកំពុងរស់នៅជាមួយ។ បើសិនជា បរិស្ថានស្អាតក៏ធ្វើឲ្យជីវិតរស់នៅរបស់យើង និងសុខភាពរបស់យើងល្អទៅតាមនោះដែរ។ តាំងពីយូរណាស់មកហើយ មនុស្សជងទាំងពួងតែងបានពិចារណាថាខ្លួនគេ ជាផ្នែកមួយនៃបរិស្ថាន ដែលពាក់ព័ន្ធនឹងសុខុមាលភាពចាំបាច់ សំរាប់ជីវិតពួកគេ និងការអភិវឌ្ឍន៍បន្តទៀត។ ប៉ុន្តែ ការយល់ដឹងនេះ ត្រូវចុះអន់ថយជាលំដាប់លំដោយ ដោយសារការរីកចំរើនជឿនលឿនខាងឧស្សាហកម្ម និងនគរូបនីយកម្ម និងការប្រើប្រាស់ដីធ្លី មនុស្សជាអ្នកបង្កើតនូវបញ្ហាទាំងឡាយតាមរយៈសកម្មភាព និងសេចក្តីសំរេចចិត្ត។ ដោយសារតែសកម្មភាពរបស់មនុស្សនេះហើយ បានផ្លាស់ប្តូរបរិស្ថានយ៉ាងឆាប់រហ័ស និងក្នុងទ្រង់ទ្រាយធំ ដូច្នេះ យើងត្រូវយល់ពីបញ្ហាបរិស្ថាន និងគ្រប់គ្រងបញ្ហាទាំងនេះឲ្យបានសមស្រប ដែលអាចការពារបរិស្ថានសំរាប់យើងផ្ទាល់ និងសំរាប់មនុស្សជំនាន់ក្រោយ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មកដល់ពេលនេះ បញ្ហាបរិស្ថានជាផលិតផលមួយ ដែលមានលក្ខណៈពេញលេញប្រព្រឹត្តទៅវិញទៅមកក្នុងសង្គម។ ការដោះស្រាយបញ្ហាបរិស្ថាន ដែលស្មុគស្មាញខ្លាំង និងមានរយៈពេលយូរ និងញឹកញាប់នោះ មិនអាចធ្វើឲ្យបានសំរេចងាយៗនោះទេ។ ក្នុងបញ្ហានេះ យើងត្រូវឲ្យប្រជាពលរដ្ឋទាំងឡាយយល់ដឹងនូវមូលដ្ឋាននៃបញ្ហា ដែលកើតមានឡើងនោះ និងបញ្ជាក់ឲ្យបានច្បាស់លាស់ពីការអភិវឌ្ឍន៍ ការបង្កើតរបៀបប្រើប្រាស់ខាងបរិស្ថាន និងទំនាក់ទំនង ដែលមានការទទួលខុសត្រូវស្មោះភាព និងយកចិត្តទុកដាក់ខ្ពស់។ ដោយមើលឃើញពី ស្ថានភាពបែបនេះហើយ ទើបធ្វើឲ្យមានចំណោទសួរមួយចំនួនលើកឡើងថា តើការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញមានការប្រព្រឹត្តទៅយ៉ាងដូចម្តេច? ហើយថា តើមានដំណោះស្រាយ និងវិធានការអ្វីខ្លះ ទៅលើបញ្ហាទាំងនោះដោយដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីរកឲ្យឃើញអំពីរបៀបនៃការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញក៏ដូចជា ផែនការយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលត្រូវបានដាក់ឲ្យអនុម័ត សំរាប់ផ្តល់ឲ្យប្រជាជនក្នុងសង្គមអនុវត្ត រួមទាំងមានការចូលរួមប្រតិបត្តិការ

របស់មន្ត្រីជំនាញបច្ចេកទេសផ្នែកបរិស្ថាន គឺធ្វើយ៉ាងណាឲ្យបរិស្ថានក្នុងសង្គមមានភាពល្អប្រសើរឡើងវិញ តាមរយៈការផ្សព្វផ្សាយអប់រំ និងចំណេះដឹងទាក់ទងនឹងការការពារបរិស្ថានដល់ប្រជាពលរដ្ឋឲ្យបានទូលាយ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ គឺធ្វើឡើងនៅតែក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ហើយចំពោះសារណានេះ យើងខ្ញុំសូមលើកយកតែពីប្រភព ផលប៉ះពាល់ ការគ្រប់គ្រងបរិស្ថានរបស់ប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល ដំណោះស្រាយ និងវិធានការទៅលើបញ្ហាទាំងនោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវនេះ

ការស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ណាស់សំរាប់យើងខ្ញុំទាំងពីរ និងអ្នកសិក្សាដទៃក្នុងការបំពេញចំណេះដឹងបន្ថែម ក្រៅពីការសិក្សាក្នុងម៉ោងសិក្សានៅសាលា និងសៀវភៅ។ ម៉្យាងវិញទៀត ប្រធានបទនេះបានចូលរួមយ៉ាងសំខាន់ក្នុងដំណើរការនៃការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញឲ្យកាន់តែមានប្រសិទ្ធភាព និងជាពិសេស គឺអ្នកជំនាន់ក្រោយនឹងអាចទទួលបានឯកសារ និងបានស្វែងយល់កាន់តែច្រើន ដើម្បីបំពេញសេចក្តីត្រូវការ ឬក៏អាចជាការជួយបាននូវអ្វីដែលខ្វះខាតនានា នៅពេលបច្ចុប្បន្ននេះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីស្រាវជ្រាវសរសេរចងក្រងសារណានេះ ចំពោះឯកសារ យើងខ្ញុំបានធ្វើការស្រាវជ្រាវលើការគ្រប់គ្រងឯកសារពាក់ព័ន្ធ ដូចជា ច្បាប់ អនុក្រឹត្យ សារាចរណែនាំ កាសែត សៀវភៅណែនាំនានាទាក់ទងនឹងបរិស្ថាន និងតាមរយៈប្រព័ន្ធអ៊ីនធឺណេត ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះ យើងខ្ញុំបានធ្វើការបែងចែកជា បីជំពូក រួមមាន៖

**ជំពូកទី១ ៖ បរិស្ថាននៅរាជធានីភ្នំពេញ**

**ជំពូកទី២ ៖ ការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ**

**ជំពូកទី៣ ៖ ដំណោះស្រាយ និងវិធានការនៃការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ**

ចំពោះខ្លឹមសារ ដែលទាក់ទងទៅនឹងចំណោទបញ្ហា ដែលបានចោទឡើងក៏ដូចជា រាល់ចំណុចដែលបានលើកឡើងខាងលើ យើងខ្ញុំនឹងធ្វើការអត្ថាធិប្បាយខ្លឹមសារក្នុងអត្ថបទស្រាវជ្រាវនេះ។

# ជំពូកទី១
# បរិស្ថាននៅរាជធានីភ្នំពេញ

# ជំពូកទី១

# បរិស្ថាននៅរាជធានីភ្នំពេញ

## ១.១. សញ្ញាណទូទៅនៃបរិស្ថាន

### ១.១.១. និយមន័យបរិស្ថាន

មាននិយមន័យជាច្រើនដែលអ្នកវិទ្យាសាស្ត្របានកំណត់ និងបានចងក្រងឡើងមានដូចជា៖

- **បរិស្ថាន** សំដៅទៅលើ សំណុំនៃសត្វលោក និងអ្វីៗទាំងឡាយដែលបង្កើតជាទីអាកាសនៅជិត ឬក៏នៅឆ្ងាយពីមនុស្ស ហើយបរិស្ថានមានអំពើលើសត្វ និងអ្វីៗទាំងនោះ តែផ្ទុយទៅវិញ សត្វនិងអ្វីទាំងនោះ អាចមានឥទ្ធិពលទៅលើបរិស្ថានវិញ ហើយបរិស្ថានអាចកំណត់ទាំងស្រុង ឬលើផ្នែកខ្លះនៃភាពគង់វង្សគ្រប់បែបយ៉ាងនៃសត្វលោក ។
- **បរិស្ថាន** គឺជាអ្វីៗដែលនៅជុំវិញខ្លួនយើង ហើយមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយវា ដែលជីវិតត្រូវការខ្វះមិនបានឡើយក្នុងការរស់រានមានជីវិត។
- **បរិស្ថាន** មានន័យថា យើងទាំងអស់គ្នា និងអ្វីៗដែលនៅជុំវិញខ្លួនយើង រួមមាន ភាវៈមានជីវិត និង គ្មានជីវិត ដែលយើងអាចមើលឃើញ ឬ មើលមិនឃើញ ស្ទាបបាន ឬស្ទាបមិនបាន ធុំក្លិន ឬមិនធុំក្លិន ដឹងរសជាតិ ឬមិនដឹងរសជាតិ ឮសូរ ឬមិនលឺសូរ ហើយភាវៈទាំងនោះមានទំនាក់ទំនងគ្នា និងជះឥទ្ធិពលទៅវិញទៅមកនៅលើផែនដី។

ទោះបីជាមានការអះអាងខុសៗគ្នាខ្លះ តែជារួម **បរិស្ថាន** គឺសំដៅទៅលើ អ្វីៗទាំងអស់ដែលនៅជុំវិញខ្លួនយើង ទាំងមានជីវិតគ្មានជីវិត មានក្លិនគ្មានក្លិន អាចប៉ះបានមិនអាចប៉ះបាន អាចមើលឃើញមិនអាចមើលឃើញ ហើយដែលមានចំណងទាក់ទងដោយផ្ទាល់ ឬដោយប្រយោល មកលើជីវិតយើងទាំងអស់គ្នា ។

### ១.១.២. ប្រភេទនៃបរិស្ថាន

បរិស្ថាន ចែកចេញជាពីរប្រភេទគឺ បរិស្ថានធម្មជាតិ និងបរិស្ថានសង្គម-វប្បធម៌។

#### ១.១.២.១. បរិស្ថានធម្មជាតិ

បរិស្ថានធម្មជាតិ ជាអ្វីៗដែលកើតឡើងដោយឯកឯង ដោយធម្មជាតិខ្លួនឯងផ្ទាល់ ហើយមានដូចជា ព្រះអាទិត្យ ព្រះច័ន្ទ ផែនដី ព្រៃព្រឹក្សា ទន្លេ សមុទ្រ ខ្យល់ ភ្លើង រ៉ែ និងសត្វគ្រប់ប្រភេទ។

#### ១.១.២.២. បរិស្ថានសង្គម-វប្បធម៌

បរិស្ថានសង្គម-វប្បធម៌ សំដៅទៅលើ អ្វីៗទាំងអស់ដែលកើតមានរូបរាងឡើងដោយស្នាដៃពលកម្ម ផលិតកម្ម ប្រកបដោយប៉ិនប្រសប់ និងច្នៃប្រឌិតរបស់មនុស្ស ដើម្បីសំណូមពរនឹងតម្រូវការក្នុងជីវភាពរស់នៅ។ អ្វីដែលមនុស្សបង្កើតឡើង ក្នុងនោះមាន ផ្ទះ ផ្លូវថ្នល់ រថយន្ត សាលារៀន

វត្តអារាម មន្ទីរពេទ្យ គូរបូតន្ត្រី សម្ភារៈប្រើប្រាស់គ្រប់បែបយ៉ាង ជាដើម។

## ១.២. ស្ថានភាពបរិស្ថាននៅរាជធានីភ្នំពេញ

កំណើនប្រជាជន និងការធ្វើចំណាកស្រុកពីជនបទទៅកាន់ទីក្រុង មានការកើនឡើងគួរឲ្យកត់សំគាល់នៅក្នុងកំឡុងពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ នៅក្នុងប្រទេសកម្ពុជា។ ម៉្យាងវិញទៀត ការរីកចំរើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ក៏បានបង្កឲ្យមានផលប៉ះពាល់ដល់បរិស្ថានផងដែរ ដោយសារតែសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច បានបង្កើតជាផលវិបាកផ្នែកបរិស្ថានសំខាន់ៗ ដែលជាហេតុនាំឲ្យមានការព្រួយបារម្ភពីបញ្ហាបរិស្ថាន និងសុខភាពមនុស្ស។ នៅក្នុងនោះផងដែរ មូលហេតុដែលនាំឲ្យមានការបំផ្លាញដល់បរិស្ថាន គឺបង្កឡើងមកពីប្រភពនៃ កាកសំណល់រឹង កាកសំណល់រាវ និងការបំពុលខ្យល់ ។

### ១.២.១. ប្រភពដែលនាំឲ្យមានការបំផ្លាញដល់បរិស្ថាន

#### ១.២.១.១. កាកសំណល់រឹង

សំណល់រឹង (សំរាម) គឺសំដៅទៅលើវត្ថុ ឬរបស់ដែលសល់ពីជីវភាពរស់នៅជាប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដែលសល់ ឬកើតពីសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម និងផលិតកម្ម ហើយដែលវត្ថុ ឬ របស់សល់ទាំងនោះមិនមានផ្ទុកជាតិពុល ឬមិនបង្កឲ្យមានជាគ្រោះថ្នាក់។ ក្នុងនោះផងដែរ ប្រភពនៃការបង្កើតសំរាមនៅក្នុងរាជធានីភ្នំពេញ មានការបែងចែងជាច្រើនប្រភេទ ដូចជាសំណល់លំនៅដ្ឋាន សំណល់ពាណិជ្ជកម្ម សំណល់មន្ទីរពេទ្យ និងសំណល់ឧស្សាហកម្ម។

- **សំណល់លំនៅដ្ឋាន** ភាគច្រើនជាប្រភេទសំណល់ចេញពីផ្ទះបាយដែលជាប្រភេទសរីរាង្គងាយពុករលួយ អាចយកទៅធ្វើជាជីកំប៉ុស្តបាន ដូចជាបន្លែ សំណល់ផ្លែឈើ សំណល់ម្ហូបអាហារ ក្រដាស ដែក ក្រណាត់ និងសំភារៈវេចខ្ចប់ ជាដើម។ ក្នុងនោះដែរ សំណល់លំនៅដ្ឋានក៏មានប្រភេទប្រកបដោយគ្រោះថ្នាក់ផងដែរ ដូចជា សំណល់ថ្មពិល អាគុយ អំពូលភ្លើង ទូរទស្សន៍ ម៉ាស៊ីនត្រជាក់ ជាដើម ដែលខូចមិនអាចប្រើប្រាស់កើត។
- **សំណល់ពាណិជ្ជកម្ម** ជាប្រភេទសំណល់ចេញពី ទីផ្សារទំនិញ សណ្ឋាគារ រង្គសាល ភោជនីយដ្ឋានជាដើម ហើយភាគច្រើននៃប្រភេទសំណល់នេះ ជាប្រភេទពុំមានគ្រោះថ្នាក់ដូចទៅនឹងប្រភេទសំណល់លំនៅដ្ឋានដែរ។ ចំពោះប្រភេទដែលគ្រោះថ្នាក់ មានដូចជាសម្ភារៈដែលសេសសល់ពីការវេចខ្ចប់ ថ្នាំ សំលាប់សត្វល្អិត សំណល់សំភារៈជជុះ (ថ្មពិល ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ គ្រឿងបន្លាស់អេឡិចត្រូនិក) ម៉ាស៊ីនត្រជាក់ ទូរទឹកកក និងសំណល់កង់ឡានចាស់ៗ។ល។
- **សំណល់មន្ទីរពេទ្យ** ជាប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ ហើយចែកចេញជាប្រភេទ

ដូចជា សំណល់ដែលបង្កឲ្យមានការឆ្លង សំណល់រោគសាស្ត្រ សំណល់ដែលបង្កឲ្យមានការមុត ឬរបួសស្នាម សំណល់ឱសថ សំណល់ពុលសែន សំណល់លោហៈ សំណល់ធុងឧស្ម័ន និងសំណល់វិទ្យុសកម្ម។[1]

- **សំណល់ឧស្សាហកម្ម** គឺជាសំណល់ទាំងឡាយណា ដែលមានប្រភពពីសកម្មភាពឧស្សាហកម្ម ហើយអាចជាសំណល់រឹងលាយជាមួយសំណល់រាវ និងសំណល់ភក់។ សំណល់ចេញពីរោងចក្រនានា ហើយក៏ស្ថិតនៅក្នុងសំណល់ប្រកបដោយគ្រោះថ្នាក់ដែរ។

សំណល់ប្រកបដោយគ្រោះថ្នាក់ គឺសំដៅទៅលើសារធាតុវិទ្យុសកម្មផ្ទុះពុល ឆេះបង្កឲ្យមានជម្ងឺមហារីក ចម្លងជម្ងឺ ធ្វើឲ្យរលាក ធ្វើឲ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីផ្សេងទៀត ដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។[2]

**១.២.១.២. ភាគសំណល់រាវ**

សំណល់រាវ គឺសំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថាន ដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។ តួយ៉ាង ប្រភពនៃសំណល់រាវត្រូវបានបែងចែកជា ២គឺ ប្រភពរាយប៉ាយ និងប្រភពចំណុច។

**ក. ប្រភពរាយប៉ាយ**

ប្រភពរាយប៉ាយ ជាប្រភពដែលបង្កឲ្យមានការបំពុល ដោយសារធាតុបំពុលដីច្រើនកន្លែង ហើយហូរធ្លាក់ចូលទៅក្នុងទឹក លើផ្ទៃដីនៃតំបន់ដ៏ធំមួយ។ ម៉្យាងវិញទៀត ប្រភពនេះមិនសូវងាយស្រួលក្នុងការត្រួតពិនិត្យទេ គឺអាស្រ័យទៅលើការយល់ដឹងរបស់បុគ្គល គ្រួសារ និងសហគមន៍។ ប្រភពរាយប៉ាយ ភាគច្រើននៃទឹកលូសម្អុយ និងទឹកភ្លៀងត្រូវបានគេបង្ហូរតាមប្រឡាយចំហ ចូលទៅក្នុងស្រះ ឬបឹងក្បែរលំនៅដ្ឋានប្រជាជន។ ចំពោះប្រព័ន្ធលូ បានភ្ជាប់ទៅនឹងការបង្ហូរចេញពីលំនៅដ្ឋាននានា ដែលមានសំណល់រាវចេញពីបង្គន់ ឬសំណល់ផ្ទះបាយ ជាដើម។ ចំណែក លូបង្ហូរទាំងនោះ មិនបានហូរចូលទៅក្នុងប្រព័ន្ធសំអាតទេ គឺហូរចូលទៅក្នុងប្រព័ន្ធផ្លូវទឹកដូចជា ទន្លេមេគង្គ ដែលជាប្រភពផ្តល់ទឹកដ៏សំខាន់បំផុតសំរាប់ប្រជាជនប្រើប្រាស់។

---

[1] https://seylanote.wordpress.com/2012/07/12/%E1%9E%80%E1%9E%B6%E1%9E%9A%E2%80%8B%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%94%E1%9F%8B%E2%80%8B%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%84%E2%80%8B%E1%9E%9F%E1%9F%86%E1%9E%8E%E1%9E%9B%E1%9F%8B%E2%80%8B%E1%9E%9A/?fbclid=IwAR3KBbMm8z1LtRf3vShqV1ZbDcIQpp5qqe8_00l3tlTp7jFhLB8oDi43GVw

[2] អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំណល់រឹង (ជំពូក១,មាត្រា៣)

ជាទូទៅ សំណល់រាវដែលបញ្ចេញពីលំនៅដ្ឋាន គឺជាប្រភេទសំណល់រាវដែលបានមកពីសកម្មភាពរស់នៅប្រចាំថ្ងៃ ហើយត្រូវបែងចែកជា សំណល់រាវពណ៌ខ្មៅ និងសំណល់រាវពណ៌ប្រផេះ។ សំណល់រាវពណ៌ខ្មៅ ជាសំណល់ដែលបានមកពីការបង្ហូរបញ្ចូលគ្នារវាងលាមក និងទឹកមូត្រ (ទឹកនោម)។ រីឯ សំណល់រាវពណ៌ប្រផេះជាសំណល់ដែលកើតមកពីទឹកដែលយើងប្រើប្រាស់ដូចជា សំណល់ពីការងូតទឹក បោកសម្លៀកបំពាក់ លាងបន្លែ ជាដើម។ សំណល់រាវទាំងពីរប្រភេទនេះ ត្រូវបានបង្ហូរចូលក្នុងលូរួមមួយដើម្បីបញ្ចេញចោល។

**ខ. ប្រភពចំណុច**

ប្រភពចំណុច ជាប្រភពដែលបញ្ចេញសំណល់ចូលទៅក្នុងបរិស្ថានតាមរយៈបំពង់បង្ហូរលូ ឬប្រឡាយពីទីតាំងប្រភពតែមួយ។ ចំពោះប្រភពនេះ មានភាពងាយស្រួលក្នុងការត្រួតពិនិត្យ និងធ្វើប្រតិកម្មសំអាតទឹកឡើងវិញ ហើយបានជាត្រូវសំអាតទឹកឡើងវិញ ដោយសារតែភាគច្រើននៃការបញ្ចេញចោលសំណល់ទាំងនោះ គឺមិនបានធ្វើការសំអាតជាមុនឡើយ។ ម៉្យាងទៀត ប្រភពនៃការបញ្ចេញសំណល់មានដូចជា រោងចក្រ រោងសិប្បកម្ម រង្គសាល ភោជនីយដ្ឋាន សណ្ឋាគារ និងផ្ទះទឹកដែលតាំងនៅក្បែរ ឬលើទន្លេ តែងតែបញ្ចេញកាកសំណល់នៅក្នុងប្រព័ន្ធទន្លេមេគង្គ ដែលជាហេតុធ្វើឲ្យទឹកកខ្វក់មានជាតិពុល។

នៅក្នុងនោះ សំណល់រាវដែលផលិតចេញពីរោងចក្រ គឺជាសំណល់ដែលបង្កើតតាមរយៈដំណើរសង្វាក់ផលិតកម្មដែលរួមមាន សំណល់រាវពីការសំអាតក្រណាត់ និងទឹកថ្នាំប្រើប្រាស់ដើម្បីជួយធ្វើឲ្យគុណភាពក្រណាត់ល្អ ទន់ និងរឹងមាំ។ ម៉្យាងទៀត រោងចក្រខ្លះក៏មានប្រើប្រាស់សារធាតុគីមីដើម្បីជ្រលក់ពណ៌ដែរ ហើយសំណល់រាវដែលប្រើប្រាស់រួច ត្រូវបានបង្ហូរចូលក្នុងលូដើម្បីបញ្ចេញចោល។

**១.២.១.៣. ការបំពុលខ្យល់**

ការបំពុលខ្យល់ គឺជាការបង្កើតឡើងដោយសារធាតុគីមី ឬជីវៈសរីរាង្គ ដែលបំផ្លាញ ឬបណ្តាលឲ្យមានផលប៉ះពាល់ដល់មនុស្ស ឬភាវៈមានជីវិតទាំងឡាយ និងបំផ្លាញដល់បរិស្ថានក្នុងបរិយាកាស។ បរិយាកាស គឺជាប្រព័ន្ធឧស្ម័នធម្មជាតិយ៉ាងរឹងមាំ ដែលទ្រទ្រង់រាល់ជីវិតមនុស្ស សត្វនានានៅលើផែនដី។ ការបំពុលខ្យល់ គឺជាលំនាំនៃការបញ្ចេញភាគល្អិតតូចៗ ធូលី ផេះ និងឧស្ម័នពុលផ្សេងៗទៅក្នុងបរិយាកាស។ មូលហេតុដែលបណ្តាលឲ្យរាជធានីភ្នំពេញមានការបំពុលខ្យល់ គឺដោយសារៈ

**ក. ការបំពុលពីរោងចក្រ**

ប្រទេសកម្ពុជា គឺវាមិនសូវមានភាពរីកចំរើនខ្លាំងលើវិស័យឧស្សាហកម្មនោះទេ ដោយរោង

ចក្រឧស្សាហកម្មភាគច្រើន គឺជារោងចក្រកក្រណាត់ និងសំលៀកបំពាក់។ តួយ៉ាង ការបំពុលភាគច្រើនមានប្រភពមកពីរោងចក្រ ដោយរោងចក្រភាគច្រើន ប្រើប្រាស់នូវគ្រឿងចក្រចាស់ៗ ដែលចេញសារធាតុពុល លើសពីនេះ រោងចក្រទាំងនោះភាគច្រើននៅក្នុងរាជធានីភ្នំពេញ ដែលធ្វើឲ្យមានកំរិតខ្ពស់ជាងនៅតំបន់ដទៃទៀត។ ចំពោះការបង្ហុយផ្សែងចេញពីរោងចក្រ ដែលមាននូវសារធាតុគីមីផ្សេងៗ ជាផ្នែកមួយធ្វើអោយមានការបំពុលខ្យល់ ដែលអាចអោយមានការប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។ ចំណែកឯ ផ្សែង ឬឧស្ម័ន ដែលភាយចេញពីរោងចក្រអាចបង្កើតទៅជាភ្លៀងអាស៊ីតផងដែរ ដែលអាចធ្វើអោយប៉ះពាល់ដល់ប្រជាពលរដ្ឋ ហើយឧស្ម័នទាំងនោះមានផ្ទុកដោយសារធាតុគីមី ដែលអាចបំផ្លាញស្រទាប់អូសូនដែលធ្វើអោយអាកាសធាតុកាន់តែក្ដៅឡើងៗជារៀងរាល់ឆ្នាំ។ ចំពោះកត្តាទាំងអស់នេះ គឺជាការបំពុលបរិស្ថានដែលធ្វើអោយផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ ប្រសិនបើមិនមានការផ្លាស់ប្តូររោងចក្រឧស្សាហកម្មទៅក្រៅក្រុង។

**ខ. ការបំពុលពីយានយន្ត**

បច្ចុប្បន្ននេះ ប្រជាជននៅក្នុងទីក្រុងភ្នំពេញមានចំនួនច្រើន ដូច្នេះតំរូវការនៃយានយន្តនៅក្នុងការធ្វើដំណើរមានចំនួនច្រើន ដែលនាំឲ្យមានឧស្ម័នពុលច្រើន ដែលត្រូវបានបញ្ចេញទៅក្នុងបរិយាកាស។ ម៉្យាងទៀត ការប្រើប្រាស់ចាស់ៗ ដែលវាបញ្ចេញផ្សែងពុលទៅក្នុងបរិស្ថានច្រើនជាងយានយន្តថ្មីៗ។ លើសពីនេះ ដោយសារតែយានយន្តនៅរាជធានីភ្នំពេញមានកំណើនខ្លាំង ទើបធ្វើឲ្យមានការកកស្ទះចរាចរណ៍ច្រើន។ នៅពេលដែលមានការកកស្ទះចរាចរណ៍ ធ្វើឲ្យមានការបញ្ចេញផ្សែងពុលមានរយៈពេលយូរជាងមុន ហើយចំពោះគុណភាពសាំងក៏ជាមូលហេតុបំពុលខ្យល់ដែរ។

**គ. ការបំពុលដោយធូលីដី**

ធូលី ក៏ជាហេតុបង្កឲ្យមានការបំពុលខ្យល់ដែរ ដោយធូលីដែលចេញមកពីការដឹកជញ្ជូនសម្ភារៈសំណង់ដែលមិនបានគ្របឲ្យបានត្រឹមត្រូវ។ ម៉្យាងទៀត ការទុកសម្ភារៈសំណល់មិនបានល្អដោយទុកនៅតាមចិញ្ចើមផ្លូវជាដើម បានធ្វើឲ្យធូលីទាំងនោះហើរចូលក្នុងបរិយាកាស។ លើសពីនេះ ធូលីដែលជាប់ជាមួយកង់យានយន្ត ក៏ជាផ្នែកមួយដែលធ្វើឲ្យបាត់បង់គុណភាពខ្យល់ផងដែរ។

**ឃ. ការបំពុលដោយចំហេះអូស ធ្យូង**

ការប្រើប្រាស់អូស ធ្យូង ក្នុងការចំអិនអាហារ គឺមានផលប៉ះពាល់ដល់បរិស្ថាន ដោយចំហេះអូស ធ្យូងទាំងនោះ បានបង្កើតនូវឧស្ម័នកាបូនិច និងឧស្ម័នកាបូណាត រួមទាំងឧស្ម័នពុលជាច្រើនទៀតចូលក្នុងបរិយាកាស ព្រមទាំងអាចបង្កឲ្យមានជំងឺផ្សេងៗផងដែរ។

### ១.២.២. មូលហេតុដែលធ្វើអោយប៉ះពាល់ដល់បរិស្ថាន

#### ១.២.២.១. បញ្ហាថង់ប្លាស្ទិច និងការវេចខ្ចប់

ជាតិថង់ប្លាស្ទិក ត្រូវបានផលិតឡើងដោយសារធាតុគីមី ដែលចំរាញ់ចេញពី ប្រេងកាត ឧស្ម័នធម្មជាតិ ដែលបានកកើតឡើងនៅក្រោមដីរាប់លានឆ្នាំមកហើយ។ ធនធានធម្មជាតិខ្លះ មិនអាចកើតឡើងវិញបាន នៅពេលដែលគេប្រើប្រាស់វាអស់ គេហៅថា ធនធានធម្មជាតិមិនអាចកើតឡើងវិញ។ ប្រេងកាត និងត្បូងថ្ម គឺជាធនធានធម្មជាតិមិនអាចកើតឡើងវិញ ហើយថែមទាំងមិនដឹងថាវានឹងបាត់បង់នៅពេលណាដែរ។

ជាតិប្លាស្ទិក ត្រូវបានគេប្រើយ៉ាងទូលំទូលាយ ពីព្រោះវាមានលក្ខណៈសម្បត្តិដូចជា ភាពទាក់ទាញ រឹង ទន់ រលោង អាចបត់ពត់បាន មិនចម្លងកម្តៅ ឬអគ្គិសនី ស្រាល មិនច្រេះចាប់ និងមានតម្លៃថោក បើប្រៀបធៀបនឹងលោហៈធាតុ។

គេប្រើជាតិប្លាស្ទិក ក្នុងវិស័យជាច្រើនដូចជា ក្នុងវិស័យកសិកម្ម គេប្រើប្លាស្ទិក Polyvinyl Chloride (PVC) និងជាតិប្លាស្ទិក High Density Polyethylene (HDPE) សំរាប់ធ្វើបំពង់បង្ហូរទឹក ធុងទឹក។ នៅក្នុងវិស័យឧស្សាហកម្មអគ្គិសនី គេប្រើសំរាប់ផលិត ទូរទស្សន៍ ទូរទឹកកក ម៉ាស៊ីនត្រជាក់ ថង់ប្លាស្ទិច សម្ភារៈវេចខ្ចប់តវ៉ាន់ បំពង់ថ្នាំដុសធ្មេញ ស្បិតសិតសក់ ដបសាប៊ូកក់សក់ និងរបស់របរផ្សេងៗ ដែលធ្វើពីជាតិប្លាស្ទិក។ ជាតិប្លាស្ទិកបង្កជាបញ្ហាយ៉ាងច្រើន ដូចខាងក្រោម៖

- កាកសំណល់ប្លាស្ទិក ធ្វើឲ្យស្ទះលូបង្ហូរទឹក ប្រឡាយ នៅពេលភ្លៀងធ្លាក់ដែលធ្វើអោយជន់លិចផ្លូវសាធារណៈ ហើយជាជម្រកសម្រាប់មេរោគ បាក់តេរី ដែលបណ្តាលឲ្យកើតមានជំងឺផ្សេងៗជាច្រើន។
- ផ្សែងពុល ដែលភាយចេញពីការដុតជាតិប្លាស្ទិក មានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពមនុស្ស។
- កម្មករ និងប្រជាជន ដែលរស់នៅជុំវិញរោងចក្រផលិតជាតិប្លាស្ទិក ប្រឈមនឹងការកើតជំងឺមហារីកមួយចំនួន និងធ្វើឲ្យទារកកើតមកមិនគ្រប់លក្ខណៈ (ប៉ះពាល់តាំងពីនៅក្នុងផ្ទៃ)។
- ស្បោងប្លាស្ទិក ដែលហើរតាមខ្យល់ ហើយធ្លាក់ចូលក្នុងដីកសិកម្ម ពន្យាពេលការលូតលាស់នៃដំណាំដោយវារុំព័ទ្ធនឹងដើមដំណាំ។
- ស្បោងប្លាស្ទិកដែលកប់ក្នុងដីរយៈយូរ បានធ្វើឲ្យស្ទះអុកស៊ីសែនចេញ ចូល ជាហេតុធ្វើឲ្យដីគ្មានជីវជាតិ។

នៅរាជធានីភ្នំពេញមានប្រជាជនសរុប ១៩៧០៣០៣នាក់ ដូច្នេះ ប្រសិនបើប្រជាជន១នាក់បានប្រើប្រាស់ថង់ប្លាស្ទិកចំនួន ៤ ក្នុងមួយថ្ងៃ នោះមានន័យថាមាន ៣៦លានថង់ប្លាស្ទិកត្រូវបាន

បោះចោលរៀងរាល់ថ្ងៃ ក្នុងរាជធានីភ្នំពេញមាន ១៤ខណ្ឌ ១០៥សង្កាត់ និង៩៥៣ក្រុម។ ដូច្នេះ ថង់ប្លាស្ទិកមានចំនួនច្រើនសន្ធឹកសន្ធាប់ណាស់។

**១.២.២.២. ការដុតកាកសំណល់**

នៅក្នុងទីក្រុង និងទីប្រជុំជន ភាគច្រើនការប្រមូលសំរាមត្រូវបានដំណើរការដោយក្រុមហ៊ុនឯកជន។ បើសិន ប្រជាជនចង់ឲ្យមានឡានដឹកសំរាមយកទៅចាក់កន្លែងផ្សេង គេត្រូវតែបង់ប្រាក់ទៅឲ្យក្រុមហ៊ុននោះ។ ជាទូទៅ ក្រុមហ៊ុនឯកជន ប្រមូលតែសំរាមនៅតាមភោជនីយដ្ឋាន ហាងទំនិញ ទីផ្សារនានា។ ចំណែកឯ ការដែលមិនបានបង់ប្រាក់ថ្លៃប្រមូលសំរាម ជាទូទៅគេដុតសំរាមរបស់ពួកគេនៅវាលទំនេរជិតៗផ្ទះ។ ការដុតសំរាម ក៏អាចបង្កទៅជាបញ្ហាធំផងដែរ នៅពេលដែលមនុស្សដុតសំរាមប្លាស្ទិច ឬកញ្ចប់ប្រអប់បាយដែលធ្វើពីប្លាស្ទិក ហើយផ្សែងដែលភាយឡើងទៅលើអាកាសនឹងធ្វើឲ្យបរិយាកាសកខ្វក់ដោយសារ សារធាតុគីមីផ្សេងៗ និងបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់ផ្លូវដង្ហើម។

នៅពេលដែលសំរាមឆេះមិនអស់ វាធ្វើឲ្យភ្លើងឆេះរឹមៗ មានផ្សែងច្រើនហុយឡើងទៅលើអាកាស។ ផ្សែងពណ៌ខ្មៅដែលបញ្ចេញទៅក្នុងអាកាស គឺវាត្រូវបានផ្សំឡើងពីភាគល្អិតជាច្រើនលាន ហើយភាគតូចល្អិតនៃផ្សែងនេះ ជួនកាលអាចនៅក្នុងខ្យល់បានជាច្រើនម៉ោង។ ម៉្យាងទៀត វាមានគ្រោះថ្នាក់ណាស់ ក្នុងការដុតកាកសំណល់កំប៉ុងបាញ់ថ្នាំផ្សេងៗ ព្រោះកំប៉ុងទាំងនេះអាចផ្ទុះហើយធ្វើឲ្យគ្រោះថ្នាក់ដល់មនុស្សដែលនៅជិត។[3]

## ១.៣. ផលប៉ះពាល់បរិស្ថាននៅក្នុងរាជធានីភ្នំពេញ

### ១.៣.១. កាកសំណល់រឹង

សំណល់រឹង ត្រូវបានគេចាត់ទុកថាជាវត្ថុដែលគ្មានប្រយោជន៍ ហើយដែលម្ចាស់មិនចង់បានវាទេ ប៉ុន្តែយើងមិនអាចគេចផុតពីវាបានឡើយ ព្រោះយើងត្រូវការចំណីអាហារ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ។ បើយោងតាមលក្ខណៈរូប និងលក្ខណៈគីមីនៃសំណល់រឹង ប្រសិនបើយើងមិនបានធ្វើការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសទេនោះ វាអាចនឹងជះឥទ្ធិពលមកលើ សុខភាពមនុស្ស សត្វ និងបរិស្ថាន។

- ធ្វើឲ្យបាត់បង់សោភណ្ឌភាពទីក្រុង និងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ
- ជាប្រភព និងទីជម្រកនៃពពួកមេរោគឆ្លង ព្រមទាំងសត្វល្អិតចង្រៃជាច្រើន
- សំណល់រឹងមួយចំនួនដែលមិនបានទុកដាក់ត្រឹមត្រូវ បានបំបែកធាតុ(រលួយ) បង្កឲ្យមានក្លិន

[3] ឯកសារ ការអប់រំបំណិនជីវិតស្ដីពីបរិស្ថានពីនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ ឆ្នាំ២០១៣ នៃក្រសួងអប់រំ យុវជន និងកីឡា

ស្អុយប៉ះពាល់ដល់អ្នករស់នៅក្បែរ និងបរិស្ថានជុំវិញ។

- សំណល់ប្រកបដោយគ្រោះថ្នាក់ ដែលមានផ្ទុកទៅដោយសារធាតុពុល និងអាចជះឥទ្ធិពលអាក្រក់ដល់សុខភាពប្រជាជន ដូចជា ប៉ះពាល់ដល់ផ្លូវដង្ហើម កើតមានជំងឺសើស្បែក និងបណ្តាលឲ្យកើតមានជំងឺរ៉ាំរ៉ៃផ្សេងៗ។
- ចំពោះទឹកសម្អុយ ដែលចេញពីសំណល់ប្រកបដោយគ្រោះថ្នាក់នោះ ដែលមួយផ្នែកអាចផ្តល់ជាជម្រកដល់ភ្នាក់ងារចម្លងជំងឺមួយចំនួនធំ និងមួយផ្នែកទៀតដែលផ្ទុកទៅដោយសារធាតុគីមីពុលអាចជ្រាបចូលក្នុងដី បានធ្វើឲ្យប៉ះពាល់ដល់គុណភាពដី ទឹក និងទឹកក្រោមដី ធ្វើឲ្យមាន ការបំពុលទឹក និងដី។ ចំណែកឯ សារធាតុមួយចំនួនដែលមិនអាចបំបែកធាតុបាន ដូចជា កៅស៊ូ ប្លាស្ទិក កែវ ជាដើម ដែលត្រូវការទីតាំងដ៏ធំដើម្បីទុកដាក់វា។
- ការបោះចោលសំណល់រាយប៉ាយ អាចបង្កឲ្យស្ទះដល់ប្រព័ន្ធលូសាធារណៈ តាមរយៈការហូរនាំដោយទឹកភ្លៀងខូចដល់ សោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់សាធារណៈ។

**១.៣.២. ភាគសំណល់រាវ**

សំណល់រាវ គឺជាវត្ថុរាវ ដែលជាផលិតផល និងជាសារធាតុផ្សំ ជាមួយនឹងសារធាតុរឹងខ្លះ ដែលត្រូវបានបញ្ចេញចោលជាប្រចាំ ទៅតាមបណ្តាញប្រព័ន្ធលូទឹកស្អុយផ្សេងៗ។ ហើយនៅពេលដែលគ្រប់គ្រងសំណល់រាវមិនបានល្អនឹងបង្កឲ្យមានការបំពុលជាច្រើនកើតឡើង ដូចជា ការបំពុលទឹក ការបំពុលដី និងការបំពុលទឹកនៅក្នុងដី ហើយក៏ធ្វើឲ្យប៉ះពាល់ដល់មនុស្ស សត្វ និង រុក្ខជាតិទៀតផង។ នៅពេលសំណល់រាវបានបង្ហូរចូលក្នុងទឹក និងដីនឹងធ្វើឲ្យទឹកពុល ព្រមទាំងដីអស់ជីវជាតិ។ ម្យ៉ាងទៀត នៅពេលដែលសំណល់ជ្រាបចូលក្នុងដី វាអាចនឹងប៉ះពាល់ដល់គុណភាពទឹកដែលនៅក្នុងដីទៀតផង។ បន្ថែមពីនេះ ការធ្វើឲ្យខូចគុណភាពទឹក ដោយការបង្ហូរទឹកកង្វក់ និងចោលសំរាមនេះចូលក្នុងទឹក ដែលជាបញ្ហាដែលធ្វើឲ្យទឹកមានលក្ខណៈកករ។ បន្ទាប់មក នៅពេលដែលមនុស្សបានយកទឹកនោះ មកប្រើប្រាស់នឹងធ្វើឲ្យប៉ះពាល់ដល់សុខភាព ដែលនឹងងាយកើតនូវជំងឺនានា ដោយជាធម្មតា ទឹកកង្វក់ទាំងនោះ គឺមានក្លិន ដែលធ្វើឲ្យមនុស្សមិនឃ្លានចំណីអាហារ ធ្វើឲ្យទន់ខ្សោយក្នុងការដកដង្ហើម ក្អួតចង្អោរ និងការបង្កឲ្យមានវិបត្តិដល់ខួរក្បាលជាដើម។ ទន្ទឹមនឹងនេះ ធ្វើឲ្យមានការបំផ្លាញដល់ជីវចំរុះ ដោយសារសារធាតុគីមី ឬសំណល់គ្រោះថ្នាក់ ដែលមាននៅក្នុងទឹក នឹងធ្វើឲ្យជីវចំរុះមួយចំនួនក្នុងមជ្ឈដ្ឋាននោះត្រូវថយចុះ ឬក៏អាចបាត់បង់ទាំងស្រុង។ លើសពីនេះ ការខ្វះខាតក្នុងការគ្រប់គ្រងនេះ ក៏ប៉ះពាល់យ៉ាងខ្លាំងទៅដល់សោភ័ណ្ឌភាពនៃការរៀបចំក្រុង ដែលទឹកលូនោះបានបញ្ចេញក្លិនមិនសមរម្យ ហើយព្រមទាំងធ្វើឲ្យសេដ្ឋកិច្ចជាតិមានការធ្លាក់ចុះផងដែរ។

### ១.៣.៣. ការបំពុលខ្យល់

ខ្យល់ គឺជាធាតុសំខាន់មួយនៅក្នុងការទ្រទ្រង់ជីវិតមនុស្ស។ ក្នុងនោះដែរ ខ្យល់ដែលបានផ្ទុកនូវសារធាតុពុល នៅក្នុងបរិយាកាស ក្នុងគេហដ្ឋាន និងក្រៅគេហដ្ឋានបានសម្លាប់មនុស្សអស់ជាច្រើននាក់។ ខ្យល់ ឬផ្សែងពុលដែលនៅក្នុងបរិយាកាស បានធ្វើឲ្យសុខភាពមនុស្សអន់ថយដោយប្រឈមនឹងជំងឺជាច្រើនដូចជា ជំងឺគាំងបេះដូង មហារីកសួត រលាកទងសួតពុំរ៉ៃ រោគហឺតជាដើម។ ចំពោះឧស្ម័នពុល ដែលបានបញ្ចេញទៅក្នុងបរិយាកាសធ្វើឲ្យទឹកភ្លៀងមានជាតិអាស៊ីតដែលនៅពេលប្រើប្រាស់ ធ្វើឲ្យកើតមាននូវជំងឺសើរស្បែក និងជំងឺជាច្រើន ទន្ទឹមនឹងនេះអាចប៉ះពាល់ដល់សំណង់អគារផងដែរ។

# ជំពូកទី២
# ការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ

# ជំពូកទី២
# ការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ

## ២.១. សមត្ថកិច្ចក្នុងការគ្រប់គ្រងបរិស្ថាន

ដើម្បីធ្វើឲ្យមានប្រសើរឡើងនូវ ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណ្ឌភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ អនុក្រឹត្យនេះ មានគោលដៅប្រគល់មុខងារសំរាម សំណល់រឹងទីប្រជុំជនទៅរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋបាលរាជធានីទៅរដ្ឋបាលខណ្ឌ ដែលជារបត់នៃការគ្រប់គ្រងថ្មីមួយស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។[4]

ដើម្បីធានាបាន ការអនុវត្តប្រកបដោយភាពរលូន ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក៏ដូចជាសំដៅទៅលើការកាត់បន្ថយបញ្ហាប្រឈមនានា ពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរាជធានី ខេត្ត ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានសូមធ្វើការណែនាំការអនុវត្តមួយចំនួន។

### ២.១.១. រដ្ឋបាលថ្នាក់ជាតិ

#### ២.១.១.១. សំណល់រឹង

នៅក្នុងប្រទេសកម្ពុជា មាត្រា៩ នៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹងឆ្នាំ១៩៩៩ កំណត់ឲ្យក្រសួងបរិស្ថាន មានតួនាទីរៀបចំគោលការណ៍ណែនាំលើ ការបោះចោល ប្រមូលដឹកជញ្ជូនស្តុក កែច្នៃកាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមផ្ទះតាមបណ្តា ខេត្ត ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព។ ចំណែកឯ អជ្ញាធរខេត្ត ក្រុង ត្រូវទទួលខុសត្រូវរៀបចំផែនការគ្រប់គ្រងសំរាមរយៈពេលខ្លី មធ្យម និងវែង នៅតាមតំបន់គ្រប់គ្រងរបស់ពួកខ្លួន។[1]

ម៉្យាងវិញទៀត ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ត្រូវសម្របសម្រួលជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំបង្កើតក្រុមការងារអន្តរក្រសួងមួយដើម្បីពិភាក្សា និងសម្របសម្រួលជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋបាលខេត្តទៅឲ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឲ្យ

[4] Counccil of Minister of cambodia,"Sub-Decree on Solid,"3, article 4.

រដ្ឋបាលខណ្ឌ។

ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំការផ្សព្វផ្សាយអនុក្រឹត្យ និងលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ចុះសិក្សា ប្រមូលព័ត៌មាន និងរៀបចំផែនការ ដើម្បីសម្របសម្រួលដល់ការផ្ទេរ និងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។
- ពិនិត្យតាមដាន វាយតម្លៃ និងរៀបចំសិក្ខាសាលា ដើម្បីឆ្លុះបញ្ចាំង និងដកស្រង់បទពិសោធន៍ លើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។
- រៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនានា អំពីការអនុវត្តអនុក្រឹត្យនេះ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

ជាងនេះទៅទៀត នៅក្នុងឆ្នាំ២០០៦ ក្រសួងបរិស្ថានសហការជាមួយ អង្គការមិនមែនរដ្ឋាភិបាល(COMPED) និងអ្នកជំនាញអន្តរជាតិនានា បានរៀបចំនូវគោលការណ៍ណែនាំបរិស្ថាននានាដែលមានស្រាប់ និងដើម្បីលើកកម្ពស់នូវការយល់ដឹង និងបង្កើនចំណេះដឹងដល់ភាគីដែលពាក់ព័ន្ធនឹងប្រធានបទនេះ។

**២.១.១.២. សំណល់រាវ**

ក្រសួងសាធារណៈការ និងដឹកជញ្ជូន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងការងារបច្ចេកទេសប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងមានតួនាទី ដូចខាងក្រោម៖[5]

- ដឹកនាំរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ និងផែនការអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច។
- រៀបចំបទដ្ឋានបច្ចេកទេស ស្តីពីការសាងសង់ គ្រប់គ្រង ប្រតិបត្តិការ និងការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជនក្នុងការវិនិយោគសាងសង់ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- គាំទ្រធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារៈដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

[5] អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ (ជំពូកទី២ មាត្រា៥)

- សហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍន៍សមត្ថភាព និងការចែករំលែកបទពិសោធន៍ អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់ថ្នាក់ជាតិ។
- ជំរុញដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងប្រតិបត្តិការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- សម្របម្រួល និងកៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់។
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់។

ក្រសួងបរិស្ថានមានតួនាទីដឹកនាំនយោបាយ និងកំណត់យុទ្ធសាស្ត្រ អំពីការគ្រប់គ្រងទឹកកខ្វក់ និងត្រួតពិនិត្យដំណើរការប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងបញ្ចេញទឹកកខ្វក់ និងមានភារកិច្ចដូចខាងក្រោម៖[6]

- រៀបចំគោលនយោបាយ ឬផែនការយុទ្ធសាស្ត្រ សំរាប់គ្រប់គ្រងការបំពុលទឹកសាធារណៈ ដែលបង្កពីការបញ្ចេញទឹកកខ្វក់។
- រៀបចំស្តង់ដាទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងស្តង់ដាបញ្ចេញទឹកសំអាតរួចចេញពីស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។
- ចូលរួមផ្តល់ប្រឹក្សាបច្ចេកទេសលើសំណើវិនិយោគបង្កើតប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ត្រួតពិនិត្យ វាយតម្លៃបំពាក់បរិក្ខារ ដំណើរការស្ថានីយ៍ប្រព្រឹត្តកម្ម។
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន លើការងារវិនិយោគប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- គាំទ្រសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្កើនការអប់រំ និងផ្សព្វផ្សាយដល់សាធារណជន អំពីប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ក្នុងគោលដៅការពារគុណភាពបរិស្ថាន។

ក្រសួងមហាផ្ទៃ មានតួនាតីគាំទ្រ សម្របសម្រួល និងជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងកក្រោម៖[7]

- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍ អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

[6] អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ (ជំពូកទី២ មាត្រា៦)
[7] អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ (ជំពូកទី២ មាត្រា៧)

ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- សម្របសម្រួល និងកៀរគរការគាំទ្រនានា ទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ផ្តល់ការអន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- ជំរុញ និងផ្តល់ការណែនាំ ដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងនាមអាណាព្យាបាលលើការងារគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**២.១.១.៣. ការបំពុលខ្យល់**

ចំពោះការបំពុលខ្យល់ ក្រសួងបរិស្ថានមានតួនាទី ដូចខាងក្រោម៖

- ក្រសួងបរិស្ថាន ត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់។
- ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល។
- ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា។
- ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតម្លៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់ទូទាំងព្រះរាជាណាចក្រកម្ពុជា។
- ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភព ដែលបង្កឲ្យមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់ឲ្យបានប្រសើរឡើងវិញ ក្នុងករណីរកឃើញថាតំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កឲ្យមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន។
- ក្រសួងបរិស្ថាន សហការជាមួយក្រសួងពាក់ព័ន្ធ មានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយ បានបញ្ចេញសារធាតុបំពុលខ្យល់ ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព។
- ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ

និងត្រូវជូនព័ត៌មានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដែលបង្កមកពីការបំពុលខ្យល់។[8]

## ២.១.២. រដ្ឋបាលថ្នាក់ក្រោមជាតិ និងមូលដ្ឋាន

### ២.១.២.១. សំណល់រឹង

យោងតាម មាត្រា៥ នៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង "ការអនុវត្តន៍ក្នុង ការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោល សំរាមតាមបណ្តាលខេត្ត ក្រុង" គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរខេត្តនិងក្រុង។[9] ដូច្នេះ ការបែងចែកសមត្ថកិច្ច និងតួនាទីមានដូចខាងក្រោម៖

**ក. រដ្ឋបាលរាជធានី**

នៅក្នុងដែនសមត្ថកិច្ចនេះត្រូវ៖

- ផ្សព្វផ្សាយ អំពីខ្លឹមសារនៃ អនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដល់រដ្ឋបាលខណ្ឌ សង្កាត់ មន្ទីរ និងអង្គការជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឲ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែកក្នុងអនុក្រឹត្យលេខ ១១៣។
- ពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីពិនិត្យលិទ្ធភាពក្នុងការធ្វើប្រតិភូកម្មទៅឲ្យ រដ្ឋបាលខណ្ឌ ឬ/និងសង្កាត់ នូវមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនមួយផ្នែក ឬទាំងស្រុង ដោយភ្ជាប់ជាមួយធនធាន មធ្យោបាយ និងសម្ភារៈ។
- ពិនិត្យការអនុវត្ត កិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីធ្វើការកែសម្រួលកិច្ចសន្យា ដោយពិនិត្យលទ្ធភាព ក្នុងការផ្ទេរការអនុវត្តកិច្ចសន្យាទៅឲ្យ រដ្ឋបាលខណ្ឌឲ្យស្របទៅនឹងតម្រូវការជាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣។
- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការសហការចូលរួមពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ។
- ចាត់ចែងឲ្យមាន ធុងសំរាមសាធារណៈ និងកំណត់កន្លែងសមស្រប សម្រាប់ស្តុកសំរាមសំណល់រឹងទីប្រជុំជនបណ្តោះអាសន្ន តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល

[8] អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

[9] Council of Minister of cambidia,"Sub-Decree on Solid,"3, article 5.

និងដឹកជញ្ជូន។

- សហការជាមួយ ក្រសួងស្ថាប័នពាក់ព័ន្ធ ពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងបម្រុងទុក សម្រាប់រៀបចំទីលានដោយផ្តោតលើទីតាំង ដែលអាចមានលទ្ធភាព សម្រាប់ការប្រើប្រាស់រួមគ្នារវាងរាជធានី និងខេត្ត ដែលមានព្រំប្រទល់ជាប់គ្នា។
- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដូចមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

**ខ. រដ្ឋបាលខណ្ឌ សង្កាត់ក្នុងរាជធានី**

នៅក្នុងដែនសមត្ថកិច្ចនេះត្រូវៈ[10]

- សម្របសម្រួលកិច្ចដំណើរការ សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- អប់រំផ្សព្វផ្សាយ និងណែនាំ ដល់ប្រជាពលរដ្ឋឲ្យយកចិត្តទុកដាក់ក្នុង ការញែក វេចខ្ចប់ទុកដាក់ និងការបោះចោលសំរាម សំណល់រឹង ឲ្យបានត្រឹមត្រូវនៅតាមទីកន្លែង និងពេលវេលា ដែលបានកំណត់ស្របតាមកម្មវិធីប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង។
- ត្រូវសម្របសម្រួល ក្នុងការកំណត់ទីតាំងទុកដាក់សំរាម សំណល់រឹងបណ្តោះអាសន្ន រួមទាំងធុងសំរាមសាធារណៈឲ្យបានសមស្រប ដោយមិនបង្កជាបញ្ហាប៉ះពាល់ដល់ការធ្វើចរាចរណ៍ សុខុមាលភាពសាធារណៈ សោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់សង្គម។
- សហការជាមួយមន្ទីរបរិស្ថាន ជួយដាក់ស្លាកសញ្ញាហាមឃាត់ ការទុកដាក់ និងការបោះចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ នៅតាមទីតាំងសំខាន់ៗមួយចំនួន នៅក្នុងរាជធានីភ្នំពេញ។
- ត្រូវធានាថា គ្មានសំរាម សំណល់រឹងនៅសេសសល់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងជំរុញការងារប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង របស់ក្រុមហ៊ុនផ្តល់សេវា ឲ្យអនុវត្តបានទៀងទាត់តាមកម្មវិធី។ ក្នុងករណី ក្រុមហ៊ុនផ្តល់សេវា មិនបានគោរពតាមកម្មវិធី ដឹកជញ្ជូនរបស់ខ្លួន រាប់ទាំងការដឹកជញ្ជូន ដែលធ្វើឲ្យជ្រុះសំរាម ហូរទឹកសំរាមលើដងផ្លូវ និងមានសំរាមសល់គរចោលច្រើន ត្រូវធ្វើរបាយការណ៍មករដ្ឋបាលរាជធានីភ្នំពេញភ្លាម អំពីទីតាំងដែលក្រុមហ៊ុនមិនបានអនុវត្តនោះ ដើម្បីមានវិធានការ។
- ដឹកនាំ កងកំលាំងនគរបាលខណ្ឌ សង្កាត់ ភ្នាក់ងារអនាម័យ មន្ត្រីបរិស្ថានចុះទប់ស្កាត់ណែនាំ និងពិន័យជាប្រាក់ ចំពោះអ្នកចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ និងអ្នក

[10] សេចក្តីណែនាំ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ

បញ្ចេញសំរាមសំណល់រឹងមកដាក់ក្រៅលំនៅដ្ឋាន ខុសទីតាំង និងម៉ោងពេលកំណត់។

- ចូលរួមសម្របសម្រួល ដោះស្រាយបញ្ហានានា ពាក់ព័ន្ធនឹងការងារសំអាត ប្រមូល ដឹកជញ្ជូន និងថ្លៃសេវាដឹកជញ្ជូនសំរាម សំណល់រឹង របស់ប្រជាពលរដ្ឋ ម្ចាស់អាជីវកម្ម សេវាកម្ម មូលដ្ឋានបង្កើតសំណល់ ជាមួយក្រុមហ៊ុនផ្តល់សេវាកម្មសំរាម សំណល់រឹង នៅក្នុងមូលដ្ឋានរបស់ខ្លួន។
- ចូលរួមសហការ ពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។[11]

**គ. រដ្ឋបាលក្រុង**

នៅក្នុងដែនសមត្ថកិច្ចនេះត្រូវៈ

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃ អនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេស ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដល់រដ្ឋបាលរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឲ្យមានយល់ជ្រួតជ្រាបពី តួនាទី ភារកិច្ចរៀងៗខ្លួន ដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣។
- សហការពិនិត្យ លើការអនុវត្តកិច្ចន្យាកន្លងមក និងធ្វើការពិគ្រោះយោបល់ជមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីកែសម្រួលកិច្ចសន្យាឲ្យស្របទៅនឹងតម្រូវការជាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣។
- ក្នុងករណី មិនទាន់មានសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវរៀបចំឲ្យមានសេវាគ្រប់គ្រងនេះ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១១៣។
- សិក្សាឲ្យបានច្បាស់លាស់ពី ស្ថានភាពនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានជាអាទិ៍ ប្រភេទ ប្រភព និងបរិមាណសំណល់។
- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយមន្ទីរ និងអង្គភាពជំនាញ រួមជាមួយ ការលើកកម្ពស់ ការកាត់បន្ថយបរិមាណសំណល់ ដែលត្រូវបានបង្កើត និងត្រូវបានបោះបង់ចោល។
- ផ្សព្វផ្សាយ និងណែនាំ ដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ សេវាគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ដោយលើកកម្ពស់ការញែក នៅនឹងប្រភព ការវេចខ្ចប់ និងការបញ្ចេញ ឲ្យបានត្រឹមត្រូវនូវសំរាម សំណល់រឹងទីប្រជុំជន និងការចូលរួមកាត់បន្ថយ ការបង្កើតសំរាមសំណល់រឹងទីប្រជុំជន។

[11] សារាចរអន្តរក្រសួង ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ចាត់ចែងឲ្យ មានធុងសំរាមសាធារណៈ និងកំណត់ទីកន្លែងសមស្រប សម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងប្រមូលនិងដឹកជញ្ជូន។

**ឃ. មន្ទីរបរិស្ថានរាជធានី**

នៅក្នុងដែនសមត្ថកិច្ចនេះត្រូវៈ

- ត្រូវត្រួតពិនិត្យវឌ្ឍនភាពក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំរាម ក្នុងការរៀបចំផែនការ កម្មវិធី និងកាលវិភាគនានា ដែលកំណត់ក្នុងសេចក្តីណែនាំ។
- ត្រូវរៀបចំ ផែនការត្រួតពិនិត្យ ការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុន រួចធ្វើរបាយការណ៍ជូនរដ្ឋបាលរាជធានីភ្នំពេញ។
- លើកកម្ពស់ ការយល់ដឹងដល់ប្រជាពលរដ្ឋ អំពីអនាម័យបរិស្ថាន តាមរយៈការអប់រំ ការផ្សព្វផ្សាយ អំពីការទុកដាក់ ការសំអាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។
- ណែនាំ មន្ត្រីទទួលបន្ទុកការងារបរិស្ថានប្រចាំខណ្ឌនីមួយៗ ឲ្យមានការសហការជាមួយអាជ្ញាធរខណ្ឌ សង្កាត់ ចុះពិនិត្យស្ថានភាព ការផ្តល់សេវាសំអាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងខណ្ឌ សង្កាត់នីមួយៗ ឲ្យបានជាប្រចាំ និងរាយការណ៍មករដ្ឋបាលខណ្ឌ ដើម្បីរកវិធីដោះស្រាយ។
- ត្រូវអនុវត្តវិធានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងអនុវត្តវិធានការដាក់ពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។
- ផ្តល់កិច្ចសហការឲ្យបានជិតស្និទ្ធិជាមួយ អាជ្ញាធរមូលដ្ឋានខណ្ឌ សង្កាត់ ក្នុងករៀបចំភ្នាក់ងារពិន័យ ព្រមទាំងធ្វើការអប់រំដល់ភ្នាក់ងារពិន័យអំពីយន្តការ និងនីតិវិធីនៃការអនុវត្តឲ្យមានប្រសិទ្ធភាព។[12]

ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែមានភាពខ្វះខាតផ្នែកហរិញ្ញវត្ថុ និងធនធានមនុស្ស អាជ្ញាធរថ្នាក់មូលដ្ឋាន បានធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនឲ្យទទួលភារកិច្ច ក្នុងការប្រមូលដឹកជញ្ជូន និងបោះចោលសំរាមនៅទីលានចាក់សំរាម។[13]

**២.១.២.២. សំណល់រាវ**

[12] សេចក្តីណែនាំស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

[13] Janya Sang-Arun and Chau Kim Heng, A Guide for Technology,8.

**ក. រដ្ឋបាលរាជធានី**

រដ្ឋបាលរាជធានី ត្រូវបំពេញតួនាទីដឹកនាំគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតនៅដែនសមត្ថកិច្ច និងភារកិច្ច ដូចខាងក្រោម៖[14]

- រៀបចំផែនការមេ សម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- រៀបចំ លិខិតបទដ្ឋានចាំបាច់នានា សម្រាប់ណែនាំការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- ត្រួតពិនិត្យ ការប្រមូលកម្រៃសេវាប្រើប្រាស់ បណ្តាញលូមេ មេរង និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូមេ មេរង និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- ត្រួតពិនិត្យ និងវាយតំលៃការអនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូ។
- ជំរុញ ការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស។
- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្ម សម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូមេ មេរង និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- កៀរគររកប្រភពថវិកាពីដៃគូរអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**ខ. រដ្ឋបាលខណ្ឌ**

រដ្ឋបាលខណ្ឌ ត្រូវបំពេញតួនាទីប្រតិបត្តិការងារគ្រប់គ្រងបណ្តាញលូខ្នែង និងខ្នែងរង ដែលស្ថិតក្នុងដែនសមត្ថកិច្ច និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព សម្រាប់អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំ បណ្តាញលូខ្នែង និងខ្នែងរង។
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស។
- រៀបចំ និងគ្រប់គ្រងសេវាប្រើប្រាស់បណ្តាញលូខ្នែរ និងខ្នែងរង។
- ផ្តល់ការអនុញ្ញាត ការស្នើរសុំភ្ជាប់បណ្តាញលូ ការស្នើសុំប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

[14] អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

- ធ្វើការតភ្ជាប់តំណលូទឹកកខ្វក់ ចេញពីលំនៅដ្ឋានមកបណ្តាញលូខ្មែង និងខ្មែងរង ដោយទទួលកម្រៃសេវាកំណត់។
- អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូខ្មែង និងខ្មែងរង។
- អនុវត្ត ការប្រមូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូខ្មែង និងខ្មែងរង។
- អាចធ្វើប្រតិភូកម្ម លើការងារមួយផ្នែកនៃការគ្រប់គ្រង បណ្តាញលូខ្មែង និងខ្មែងរងជូនរដ្ឋបាលសង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬជំរុញឲ្យមានការចូលរួមពីរដ្ឋបាលសង្កាត់ ក្នុងការអនុវត្តមុខងារទាំងនេះឲ្យមានប្រសិទ្ធភាព។
- កៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធលូខ្មែង និងខ្មែងរង។

ជំរុញការអប់រំប្រជាពលរដ្ឋក្នុងការថែទាំ និងចូលរួមប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**គ.រដ្ឋបាលក្រុង**

រដ្ឋបាលក្រុង ត្រូវបំពេញតួនាទីប្រតិបត្តិការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោមៈ[15]

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងារកសាង ជួសជុល ស្តារ ថែទាំប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- អនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស។
- ធ្វើការតភ្ជាប់តំណលូទឹកកខ្វក់ ចេញពីលំនៅដ្ឋានមកបណ្តាញលូខ្មែង និងខ្មែងរង ដោយទទួលកម្រៃសេវាកំណត់។
- រៀបចំ និងគ្រប់គ្រងសេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ផ្តល់ការអនុញ្ញាតការស្នើសុំតភ្ជាប់បណ្តាញលូ ការសុំប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និង សេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- ជំរុញការអប់រំប្រជាពលរដ្ឋក្នុងការថែទាំ និងចូលរួមប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

[15] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ មាត្រា១១

- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- អាចធ្វើប្រតិភូកម្ម លើការងារមួយផ្នែកនៃការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជូនរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬជំរុញឲ្យមានការចូលរួមពីរដ្ឋបាលឃុំសង្កាត់ក្នុងការអនុវត្តមុខងារទាំងនេះឲ្យមានប្រសិទ្ធភាព។
- កៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារៈ ក្នុងការអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**ឃ. មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត សហការជាមួយ អង្គភាពជំនាញពាក់ព័ន្ធត្រូវបំពេញតួនាទីជាសេនាធិការឲ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំផែការមេសម្រាប់គ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- ចូលរួមផ្តល់យោបល់បច្ចេកទេស លើសំណើគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- ពិនិត្យផ្តល់យោបល់ ការស្នើសុំតភ្ជាប់បណ្តាញលូ ការប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងចូលរួមសហការអនុវត្តទណ្ឌកម្មលើបទល្មើស។
- លើកកម្ពស់ ការយល់ដឹងប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាន តាមរយៈការអប់រំផ្សព្វផ្សាយពីការប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។
- រៀបចំរបាយការណ៍ ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធកម្មទឹកកខ្វក់។

**ង. មន្ទីរបរិស្ថានរាជធានី ខេត្ត**

មន្ទីរបរិស្ថាន រាជធានី ខេត្ត សហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ ត្រូវបំពេញតួនាទីជាសេនាធិការឲ្យរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការងារគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញក្រោយប្រព្រឹត្តកម្ម និងមានភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំផែនការមេគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញ។
- ចូលរួមផ្តល់យោបល់បច្ចេកទេស លើសំណើគម្រោងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការ

បញ្ចេញ។

- ផ្តល់យោបល់លើការស្នើសុំការបញ្ចេញទឹកកខ្វក់ពី អគារអាជីកម្ម បុរីលំនៅដ្ឋាន ទីក្រុង រណប តំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ឬតំបន់ទឹក សាធារណៈ។
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបញ្ចេញទឹកកខ្វក់ ឬការបំពុលទឹក និងចូលរួមសហការអនុវត្តទណ្ឌកម្មលើបទល្មើស។
- លើកកម្ពស់ការយល់ដឹងប្រជាពលរដ្ឋ អំពីអនាម័យបរិស្ថាន តាមរយៈ ការអប់រំផ្សព្វផ្សាយពី ការគ្រប់គ្រប់ទឹកកខ្វក់។
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីការគ្រប់គ្រង និងការបញ្ចេញទឹកកខ្វក់។

## ២.២. ការគ្រប់គ្រងសំរាមនៅរាជធានីភ្នំពេញ

ប្រជាជនកម្ពុជា ភាគច្រើនហាក់បីដូចជាមានការយល់ដឹងតិចតួច អំពីរបៀបនៃការចោល សំណល់ឲ្យបានត្រឹមត្រូវ។ ការណ៍នេះ ដោយសារតែសង្កេតឃើញថា នៅតែមានសំរាម ឬសំណល់ រឹងយ៉ាងច្រើនបោះចោលតាមកន្លែងទីសាធារណៈ តាមដងផ្លូវ ឬនៅតាមកន្លែងទំនេរ នៅក្បែរអគារ លំនៅដ្ឋាន។[16] ជាងនេះទៀត នៅទីក្រុង នៅតែមានការខ្វះខាតប្រព័ន្ធសមស្របមួយ ដើម្បីប្រមូល ដឹកជញ្ជូន និងកំចាត់ចោលនូវសំណល់រឹងឲ្យបានត្រឹមត្រូវ។[17]

### ២.២.១. វិធីសាស្ត្រចោលសំរាមដោយប្រជាពលរដ្ឋ

ប្រជាជនកម្ពុជា បោះចោលសំរាមទៅតាមវិធីផ្សេងៗគ្នា ដោយប្រជាជនកម្ពុជាតែងតែបែង ចែកសំណល់រឹងនៅទីកន្លែងកកើតសំរាម។ ការញែកសំណល់ ដែលអាចកែច្នៃវិញបានធ្វើឡើង ដោយមានការស្ម័គ្រចិត្ត។ អ្នករើសសំរាមក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការបែងចែកសំណល់ ដែលអាចលក់បានពីធុងសំរាម និងនៅកន្លែងដែលចោលសំរាម។ **ឧទាហរណ៍៖** មានអ្នករើសសំរាម ជាង ២.០០០នាក់ ធ្វើការរកសំរាមដែលអាចលក់បានពីធុងសំរាមនៅតាមជាយក្រុង និងនៅទីលាន ចាក់សំណល់នៅតំបន់ភ្នំពេញ។

ការគ្រប់គ្រងសំរាម ត្រូវបានអនុវត្តដោយមនុស្សជាច្រើន គឺតាមរយៈការដុត។ ខណៈពេល ដែលការដុតសំរាមក្នុងទីក្រុងកម្រនឹងធ្វើឡើង វាត្រូវបានគេសង្កេតឃើញថាមនុស្សជាច្រើននៅក្នុង តំបន់ជនបទ មាននិន្នាការទៅដុតសំរាម ដោយពួកគេយល់ឃើញថា វាជាវិធីសាស្ត្រងាយស្រួល ជាងក្នុងការយកសំរាមទៅចោល។ ទាំងអស់នេះ ឆ្លុះបញ្ចាំងពីការពិតផងដែរ ថាការផ្តល់សេវា

[16] Sour et al,"Municipal Solid", 79

[17] Ministry of Environment, "Cambodia Environment",62

ប្រមូលសំរាមនៅមានកំរិត និងខ្វះទីលានចាក់សំរាម។

### ២.២.២. វិធីសាស្ត្រគ្រប់គ្រងសំរាមដែលប្រើសប្រាស់ដោយរដ្ឋាភិបាល

#### ២.២.២.១. ទីលានចាក់សំរាម

នៅក្នុងបណ្តាប្រទេសអាស៊ាន ដែលកំពុងអភិវឌ្ឍន៍ផងដែរ ការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា គឺសាមញ្ញ ដែលភាគច្រើនពាក់ព័ន្ធនឹងការប្រមូលសំរាម ការចាត់ចែង និងការចោលនៅឯទីលានចាក់សំរាម និងកន្លែងចាក់សំរាម ឬសំណល់។ សំរាមជាច្រើន ត្រូវបានបោះចោល នៅកន្លែងចាក់សំរាម ឬសំណល់។ គេសង្កេតឃើញថា មានប្រហែលជា ៦០ទីកន្លែងសំរាប់ចាក់សំរាមកំពុងដំណើរការនៅទូទាំងប្រទេសកម្ពុជា ប៉ុន្តែភាគច្រើននៃតំបន់ទាំងនោះត្រូវបានគេដឹងថា មានគុណភាពអន់ ហើយការរចនាបច្ចេកទេសនៅមានកំរិត។ ករណីលើកលែងមួយភ្នំពេញ នៅឆ្នាំ២០០៩ ទីលានចាក់សំរាមដង្កោ ត្រូវបានសាងសង់ឡើង ដោយប្រើប្រាស់បច្ចេកទេសទំនើបរួមបញ្ចូលគ្នា រួមទាំងប្រព័ន្ធបង្ហូរ ឬសង្កត់សំរាម និងប្រព័ន្ធលូបង្ហូរទឹកស្អុយ។

#### ២.២.២.២. ការកែច្នៃ

ក្រៅពី ទីលានចាក់សំរាម រដ្ឋាភិបាល (មូលដ្ឋាន) ធ្វើកិច្ចសហប្រតិបត្តិការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការនៅក្នុងវិស័យពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម ឬសំណល់នេះ បានអនុវត្តការធ្វើជីកំប៉ុស និងកម្មវិធីកែច្នៃជាច្រើន។[18]

នៅទីក្រុងភ្នំពេញ គម្រោងជីកំប៉ុស្តត្រូវបានអនុវត្តដោយ អាជ្ញាធរគ្រប់គ្រងសំរាមភ្នំពេញ[19] (Phnom Penh Waste Management "PPWM" Authority) ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលដូចជា អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា(COMPED) និងអង្គការស្តារ៉ូ (SCARO)។ អាជ្ញាធរគ្រប់គ្រងសំរាមភ្នំពេញ គឺទទួលខុសត្រូវលើការប្រមូលសំរាម ឬសំណល់សរីរាង្គរឹង នៅតំបន់ដែលបានកំណត់មួយចំនួន (**ឧទាហរណ៍៖** សង្កាត់បឹងកេងកង I និងII ហើយនិងសង្កាត់ផ្សារដើមគរ និងនៅកន្លែងសត្តឃាត) និង ផ្គត់ផ្គង់សំរាមទាំងនេះទៅអង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា និងអង្គការស្តារ៉ូ សំរាមគម្រោងជីកំប៉ុស្ត។[20] ជាងនេះទៅទៀត អាជ្ញាធរគ្រប់គ្រងសំរាម

---

[18] Janya Sang-Arun and Chau Kim Heng, A Guide for Technology, 54.

[19] Phnom Penh Waste Management(PPWM) Authority was created by the Municipality of Phnom Penh (MPP) in order to be responsible for overall solid waste management in Phnom Penh, according to Keo Rathana,"Solid Waste Management in Cambodia ,"May 2009, accessed on March 31, 2015, URL: http://www.cicp.org.kh/userfiles/Worrking%20paper/CICP%20Working%20Paper%2017%20solid%20waste%20management Edited.pdf.

[20] 3RKH,"3R Good Practices in Cambodia: Phnom Penh Waste Management (PPWM)", accessed on April 06,2015, URL: http//www.faculty.ait.ac.th/visu/NGOs/pdfs/cambodia-%20NGO/SJ-PPWM.pdf

ភ្នំពេញ ក៏បានផ្តល់ទីតាំងនៅឯទីលានចាក់សំរាម ទៅអង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជាផងដែរ ដើម្បីអនុវត្តគម្រោងធ្វើជីកំប៉ុស្ត។

ទាក់ទងទៅនឹងការកែច្នៃសំរាម ក្រុមហ៊ុនស៊ិនទ្រី មានគម្រោងបង្កើតរោងចក្រកែច្នៃសំរាមជាមួយសាលារាជធានីភ្នំពេញដើម្បីកាត់បន្ថយសំណល់ ឬសំរាមឲ្យនៅសល់សូន្យ។[21] ទោះយ៉ាងណាក៏ដោយ នៅពេលបច្ចុប្បន្ន មិនមានព័ត៌មានថា តើផែនការនេះកំពុងត្រូវបានអនុវត្តឬទេ និងអាចត្រូវសម្រេចបាននៅរយៈពេលប៉ុន្មានឆ្នាំនោះទេ។

**២.២.២.៣. ឡដុត ឬរោងចក្រដុតសំរាម**

ការចោលសំរាមឬសំណល់វេជ្ជសាស្ត្រ ត្រូវបានចោលតាមរយៈឡដុតសំរាម។[22] ទាក់ទងទៅនឹងឡដុតសំណល់វេជ្ជសាស្ត្រ មន្ទីរពេទ្យ ពហុគ្លីនិក គ្លីនិក និងមណ្ឌលសុខភាព ដែលមិនមានឡដុត បញ្ជូនសំរាម ឬសំណល់ទៅកាន់មន្ទីរពេទ្យដែលមានឡដុតនៅនឹងកន្លែង។[23] ទោះជាយ៉ាងណាក៏ដោយ សំណល់វេជ្ជសាស្ត្រតិចតួចប៉ុណ្ណោះ ដែលមានបរិមាណប្រមាណជា ៣៥៧ គីឡូក្រាម និង៦៨លីត្រ ត្រូវបានរាយការណ៍ថា ត្រូវបានដុតប្រចាំថ្ងៃដោយឡដុតសំរាមនៅនឹងកន្លែងនៅតាមមន្ទីរពេទ្យតូចៗមួយចំនួន។ ចំពោះ ផេះ និងសំរាម ឬសំណល់មួយចំនួនដែលបានបង្កើតពី ការដុតរំលាយត្រូវបាន បោះចោលនៅកន្លែង នៅក្នុងតំបន់ជុំវិញនៃការដុតនោះ ខណៈពេលដែលផ្នែកខ្លះ ដែលនៅសល់ត្រូវបានប្រមូលផ្តុំដោយក្រុមហ៊ុនPSBK ដើម្បីបោះចោលនៅទីលានចាក់សំរាម។

[21] CINTRI, "Recycling Project," last modified 2011 , accessed on April 06, 2015, URL: http://www.cintri.com.kh/PHP/RecyclingProject.php

[22] Meeting with Denis Schrey, country Representative of Cambodia of Konrad-Adenauer-stiftung (KAS) on April 03, 2015

[23] Ministry of Environment, "Cambodia Environment",67

# ជំពូកទី៣
# ដំណោះស្រាយ និងវិធានការនៃការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ

# ជំពូកទី៣

# ដំណោះស្រាយ និងវិធានការនៃការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ

## ៣.១. ដំណោះស្រាយនៃការគ្រប់គ្រងបរិស្ថាន

### ៣.១.១. សំណល់រឹង

យោងតាមរបាយការណ៍របស់ក្រសួងបរិស្ថាន បច្ចុប្បន្ននៅក្នុងមួយថ្ងៃ សំណល់រឹងសំរាមនៅក្នុងរាជធានីភ្នំពេញបានកើនរហូតដល់ ៣០០០តោន ក្នុងនោះ ៦៥% ជាសំរាមសើម, ២០% ប៉ុណ្ណោះដែលធ្វើឲ្យអត្រាសំរាមដែលត្រូវបោះចោលនៅទីលានសំរាមមានពី ៧០% ទៅ ៨០% និងសំរាមមួយចំនួនទៀត ត្រូវបានចោលអនាធិបតេយ្យនៅតាមផ្លូវសាធារណៈនានា។ ប្រភពឲ្យដឹងទៀតថា សំណល់ដែលត្រូវបានអ្នកចូលរួមប្រមូលបាន គឺភាគច្រើនជាសំណល់សំរាម ថង់ប្លាស្ទិកដែលត្រូវបានបោះរាយប៉ាយ នៅតាមទីធ្លាសាធារណៈនានា ដែលក្រោយពីការដើរកម្សាន្តរបស់ប្រជាពលរដ្ឋមួយចំនួន ដែលមិនបានទុកដាក់សំរាមឲ្យបានត្រឹមត្រូវ។

#### ៣.១.១.១. ការញែកសំណល់

ការញែកសំណល់នៅតាមលំនៅដ្ឋាន គឺដើម្បីកាត់បន្ថយនូវបរិមាណសំណល់ដែលត្រូវយកទៅចាក់ចោលនៅទីតាំងចាក់សំណល់រឹង។ វិធីសាស្ត្រមួយចំនួន ដែលមានអាចយកទៅអនុវត្ត ឬគួរគិតពិចារណាមានដូចតទៅ៖

- ការញែកសំណល់ ដែលប្រកបដោយគ្រោះថ្នាក់ ចេញពីសំណល់ដែលមិនគ្រោះថ្នាក់ : ទោះបីជា នៅតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋមិនមែនជាប្រភពចំលង ដែលបង្កើតឡើងនូវសំណល់គ្រោះថ្នាក់ក៏ដោយ ក៏ប៉ុន្តែវាក៏មានប្រភេទសំណល់មួយចំនួនដូចជា ថ្មពិលអាគុយ សំណល់ថ្នាំពេទ្យ ដែលសេសសល់ ឬផុតកាលកំណត់នៃការប្រើប្រាស់ជាដើម ដូច្នេះ សំណល់វត្ថុទាំងនេះ គួរតែញែកចេញឲ្យដាច់ពីគ្នារវាងសំណល់ធម្មតា។ លើសពីនេះទៀត សំណល់ធម្មតាដែលអាចយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតបាន គួរតែញែកចេញពីសំណល់ដែលត្រូវបោះចោល។ **ឧទាហរណ៍៖** ថង់ប្លាស្ទិក និងកញ្ចប់មួយចំនួនដែលយើងអាចយកទៅលាងសំអាត ដើម្បីទុកប្រើប្រាស់ឡើងវិញចៀសវាងការទិញស្បោងឬប្រអប់មកទុកប្រើប្រាស់។
- ការញែកសំណល់សំរាប់កែច្នៃ : គឺជាការញែកសំណល់រឹងដូចជា ក្រដាស កំប៉ុងអាលុយមីញ៉ូម អំបែងដបឬកែវ និងសារធាតុប្លាស្ទិក ឲ្យចេញពីគ្នា។ រឹងប្រភពបង្កើតសំណល់រឹង ដើម្បីយកទៅកែច្នៃ គឺជាមធ្យោបាយល្អប្រសើរមួយ ដើម្បីសន្សំសំចៃវត្ថុធាតុដើម មានន័យថាយើងអាចកាត់បន្ថយការទាញយកធនធានធម្មជាតិយកមកប្រើប្រាស់។

- ការញែកសំណល់ដែលនៅតាមទីសាធារណៈ រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម : ការញែកសំណល់រឹងទៅតាមសាធារណៈ រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម មានភាពលំបាក និងស្មុគស្មាញជាងតាមលំនៅដ្ឋាន ដោយទីនោះជាកន្លែងដែលមមាញឹក និងមានទំនាក់ទំនងទៅនឹងប្រជាជនទូទៅ។ ដូច្នេះ ការញែកសំណល់នេះ វាទាក់ទងទៅនឹងឥរិយាបថ ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងស្មារតីចូលរួមក្នុងសកម្មភាពនៃការញែកសំណល់នេះ។

**៣.១.១.២. ការប្រមូល និងដឹកជញ្ជូន**

ការប្រមូល និងដឹកជញ្ជូនសំណល់រឹងមានភាពស្មុគស្មាញ ដោយសារការបញ្ចេញសំណល់មាននៅគ្រប់ទីកន្លែងទាំងអស់រួមទាំង លំនៅដ្ឋាន ទីផ្សារ រោងចក្រ សហគ្រាស ផ្លូវថ្នល់ និងទីសាធារណៈផ្សេងៗទៀត។ ចំណែកឯ មធ្យោបាយ និងវិធីសាស្ត្រក្នុងការប្រមូល គឺប្រែប្រួលទៅតាមទីតាំង និងស្ថានភាពនៃកន្លែងបង្កើតសំណល់នោះ។ ប្រទេសមួយចំនួននៅអាស៊ី បានអនុវត្តវិធីសាស្ត្រផ្សេងៗគ្នាក្នុងការប្រមូលដូចជា៖

- **ការប្រមូលតាមលំនៅដ្ឋាន** : សេវាកម្មនៃការប្រមូលសំណល់ គឺប្រមូលនៅតាមផ្ទះនីមួយរបស់ប្រជាពលរដ្ឋ។ ក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំណល់ត្រូវធ្វើការប្រមូលឲ្យបានទៀងទាត់ពេលវា និងមានកម្មវិធីប្រមូលជាក់លាក់ ព្រមទាំងផ្សព្វផ្សាយជូនប្រជាពលរដ្ឋឲ្យបានដឹងជ្រួតជ្រាប។ ចំពោះ ចំនួនជើងដែលត្រូវធ្វើការប្រមូល ត្រូវអនុវត្តឲ្យបានសមរម្យដែលធានាពុំឲ្យមានការកកស្ទះ ឬសេសសល់ឡើយ។
- **ការប្រមូលតាមសហគមន៍** : សេវាកម្មនៃការប្រមូលសំណល់ចូលទៅប្រមូលនៅតាមទីតាំងស្តុករួម នៅតាមសហគមន៍។ ក្នុងនោះ មានការប្រមូលនៅតាមទីសាធារណៈ និងទីផ្សារ ដោយត្រូវប្រមូល និងបោសសំអាតជារៀងរាល់ថ្ងៃ ដើម្បីចៀសវាងការកកស្ទះសំណល់តាមដងផ្លូវទីសាធារណៈ ឬតាមសួនច្បារ។ ក្នុងករណី ទីលានចាក់សំណល់នៅឆ្ងាយ ក៏ត្រូវធ្វើការប្រមូលយកទៅចាក់នៅកន្លែងស្តុកបណ្តោះអាសន្នដែលមិនធ្វើឲ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន។ បន្ថែមនេះ ក្នុងករណីសំរាមពេញធុង ដែលដាក់តាមផ្លូវត្រូវប្រមូលចេញដោយប្តូរធុងថ្មី ឬបង្វិលធុងចាស់ ដែលទទេមកដាក់នៅទីកន្លែងដដែលវិញ។ ក្នុងនេះ ក៏ត្រូវបំផុសប្រជាពលរដ្ឋ ឲ្យជួយថែរក្សាធុងសំរាមសាធារណៈផង។
- **ការប្រមូលតាមដងផ្លូវ** : សេវាកម្មនៃការប្រមូលសំណល់ ចូលទៅប្រមូលនៅទីតាំងស្តុកផ្សេងៗនៅតាមដងផ្លូវ ដោយក្នុងនោះត្រូវការមធ្យោបាយ និងដឹកជញ្ជូន។ ក្នុងនោះ ត្រូវប្រើប្រាស់ រថយន្តមានទ្រុងជិត ហើយពេលដឹកជញ្ជូនត្រូវគ្របពីលើការពារការធ្លាក់រាយប៉ាយ

តាមផ្លូវ។ ម្យ៉ាងវិញទៀត ត្រូវផ្ទុកចំណុះសមរម្យ ដោយមិនឲ្យលើសចំណុះ ការពារពេលមានបញ្ហាផ្សេងៗ កើតមានក្នុងពេលធ្វើការដឹកជញ្ជូន។ លើសពីនេះ ត្រូវមានមធ្យោបាយគ្រប់គ្រងក្នុងការដឹកជញ្ជូន ដោយគិតទៅដល់ពេលមានបញ្ហាខូចគ្រឿងចក្រ។ ក្នុងនោះ ត្រូវធ្វើការដឹកសំណល់ឲ្យអស់ តាមកម្មវិធីដែលបានកំណត់ប្រចាំថ្ងៃ ហើយនៅក្នុងពេលដឹកជញ្ជូន ត្រូវរក្សាភាពស្ងប់ស្ងាត់តាមដែលអាចធ្វើទៅបាន។

**៣.១.១.៣. ការកែច្នៃ**

ការកែច្នៃសំណល់រឹង សំដៅទៅលើសកម្មភាពទាំងឡាយដែលធ្វើឲ្យកាត់បន្ថយនូវបរិមាណ ឬគុណភាពនៃសំណល់រឹង ដើម្បីសំរាលដល់ការធ្វើប្រព្រឹត្តកម្មសំអាត ឬការបោះចោលសំណល់រឹងនៅទីលាន។ ការកែច្នៃសំណល់រឹងចែកចេញជា៖

- **ការកាត់បន្ថយបរិមាណសំណល់** : គឺសកម្មភាពដែលធ្វើឲ្យសំណល់មានតិច។ ដើម្បីឲ្យមានការថយចុះនៃកាកសំណល់រឹង ត្រូវធ្វើការរៀបចំ និងការប្រើប្រាស់ដែលមានលក្ខណៈសន្សំសំចៃ ដើម្បីរក្សាបរិមាណនៃការប្រើប្រាស់ ។
- **ការប្រើប្រាស់ឡើងវិញ** : គឺសំដៅទៅលើការយកសំណល់មកប្រើប្រាស់ឡើងវិញ ដោយរូបរាង និងសមាសភាគនៅដដែល រួមមាន ដប ក្រដាស ឬប្លាស្ទិក យកទៅលាងសំអាតរួចយកមកប្រើប្រាស់ឡើងវិញ។
- **ការកែច្នៃ** : គឺជាដំណើរការ ៣យ៉ាង ការកែច្នៃ ដំណើរការផលិត និងការប្រើប្រាស់ឡើងវិញ។ ផលិតផល ឬសម្ភារៈ ដែលអាចកែច្នៃបាន គឺជាសម្ភារៈដែលគេប្រើវាជាវត្ថុដើម ដើម្បីបង្កើតនូវរបស់អ្វីមួយថ្មីបាន និងអាចត្រូវបានគេប្រើប្រាស់វាឡើងវិញថែមទៀតផង។ ការកែច្នៃ ត្រូវបានគេកំណត់ជាការប្រមូល និងការញែកនូវសម្ភារៈពីសំណល់ និងបន្ទាប់មកធ្វើដំណើរការ ផលិតនូវសម្ភារៈពីសំណល់ និងបន្ទាប់មកធ្វើដំណើរការផលិត នូវរបស់អ្វីដែលអាចលក់នៅទីផ្សារបាន។
- **ការធ្វើកំប៉ុស្ត** : សំណល់ចេញពីលំនៅដ្ឋានភាគច្រើនជា ប្រភេទសរីរាង្គដែលអាចយកទៅធ្វើជាជីកំប៉ុស្ត។ កំប៉ុស្ត គឺជាផលិតផលនៃសមាសធាតុសរីរាង្គនៅក្នុងលក្ខខ័ណ្ឌលំនឹង ដែលអាចជួយពង្រឹងសមត្ថភាពដី និងបន្ថែមជីដល់ដី បន្ទាប់ពីបានបញ្ចប់ការបំបែកធាតុ ឬពុករលួយក្រោមអំពើនៃបាក់តេរី ខ្យល់ និងទឹក។ សមាសធាតុសរីរាង្គ ដែលអាចធ្វើជាកំប៉ុស្តបានមានដូចជា សំណល់ផ្ទះបាយ លាមកសត្វ លាមកមនុស្ស បន្លែ ឬសំណល់ដំណាំ សំណល់ស្លឹកឈើ សំណល់សាច់ ឬផលិតផលនេសាទ។

**៣.១.១.៤. ការបោះបង់ចោល**

គោលបំណងសំខាន់ក្នុងការគ្រប់គ្រងសំណល់រឹង គឺរៀបចំការបោះចោលសំណល់ឲ្យបានត្រឹមត្រូវ ដើម្បីសុខុមាលភាពរបស់មនុស្ស សត្វ និងបរិស្ថានទាំងមូល។ នៅពេលដែលវិស័យឧស្សាហកម្ម មិនទាន់មានការរីកចម្រើនខ្លាំងក្លាទេ នោះសំណល់រឹងត្រូវបានគេយកទៅចោលនៅតាមទីវាលដែលទំនេរ។ ប៉ុន្តែចាប់ពីវិស័យឧស្សាហកម្មបានរីកចម្រើនមក សមាសធាតុបង្កសំណល់ក៏មានភាពស្មុគស្មាញផងដែរ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ និងបច្ចេកវិទ្យាត្រឹមត្រូវ ដើម្បីធ្វើការបោះបង់ចោលសំណល់ឲ្យបានត្រឹមត្រូវ។ ហើយ បទពិសោធន៍ក្នុងការបោះបង់ចោលសំណល់រឹង ដែលប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានអនុវត្តមានដូចតទៅ៖

- បោះចោលនៅទីចាក់សំណល់អនាម័យ
- បំលែងធ្វើជាជីកំប៉ុស្ត
- នាំចេញទៅប្រទេសផ្សេងទៀត
- ដុតតាមបច្ចេកវិទ្យា
- កែច្នៃឡើងវិញនូវសារធាតុដែលអាចកែច្នៃបាន

**៣.១.១.៥. ការស្តុកទុកបណ្តោះអាសន្ន**

ការស្តុកទុកបណ្តោះអាសន្ន គឺសំដៅទៅលើការស្តុកទុកក្នុងរយៈពេលខ្លីមួយ ដើម្បីរង់ចាំសេវានៃការប្រមូលយកទៅចាក់ចោលនៅទីតាំងចាក់សំណល់។

ការស្តុកគួរតែរក្សាទុកក្នុងធុងដែលមានគម្របត្រឹមត្រូវ និងទំហំល្មម (ងាយស្រួលដល់ការលើកដាក់ចំពោះអ្នកប្រមូលសំណល់) និងអាចដាក់សំណល់គ្រប់គ្រាន់ ទៅតាមរយៈពេលនៃការស្តុកទុក អាស្រ័យទៅលើប្រភេទសំណល់នោះ។ បើជាប្រភេទសំណល់ចំណីអាហារ គឺគួរកុំស្តុកទុកឲ្យលើសពី រយៈពេល៤ថ្ងៃ បើមិនដូច្នេះទេ សំណល់ទាំងនោះនឹងរលួយ ដែលបណ្តាលឲ្យជះក្លិនស្អុយ និងបង្កឲ្យមានការរីករាលដាលនូវមេរោគឆ្លងផ្សេងៗ។ ចំណែកប្រភេទធុងគួរតែជ្រើសរើសធុងដែលមាំប្រើជាប់បានយូរ តែមានទម្ងន់ស្រាល ដើម្បីងាយស្រួលដល់ការផ្ទេរសំណល់ពីកន្លែងមួយទៅកន្លែងមួយទៀត ឬទៅធុងផ្សេងទៀត។

នៅទីតាំងផ្សេងដូចជា តាមផ្សារក៏ដូចជាទីសាធារណៈដែរ ការរក្សាទុកគួរតែរៀបចំទុកដាក់ក្នុងធុងឲ្យបានត្រឹមត្រូវ ចៀសវាងការគរជាគំនរចោល ព្រមទាំងធ្វើឲ្យរាយប៉ាយដោយសត្វពាហនៈដែលទៅកកូរកកាយរកចំណី និងមនុស្សមួយចំនួនទៅកកាយ ដើម្បីរកវត្ថុដែលអាចយកទៅកែច្នៃបាន។ លើសពីនេះទៀត សំណល់ដែលមិនបានទុកដាក់ត្រឹមត្រូវអាចប៉ើងតាមខ្យល់ និងជះក្លិនមិនល្អដល់បរិស្ថាន។ ការដាក់ធុង នៅតាមដងផ្លូវសារធារណៈ ឬសួនច្បារត្រូវដាក់ឲ្យបានគ្រប់គ្រាន់ហើយដាក់នៅកន្លែងដែលសមរម្យ មិនបង្កឲ្យប៉ះពាល់ដល់សុវត្ថិភាពសណ្តាប់ធ្នាប់ និងប៉ះពាល់

ដល់ចរាចរណ៍។

**៣.១.២. សំណល់រាវ**

ជាទូទៅ សំណល់រាវ មានប្រភពបង្កចម្លងមកពីរោងចក្រ លំនៅដ្ឋាន និងកន្លែងអាជីវកម្មមួយចំនួន ហើយចំពោះ បច្ចេកវិទ្យាក្នុងការគ្រប់សំណល់រាវនៅមានកំរិត ដែលបង្កើតឲ្យមានផលប៉ះពាល់ដល់ការរស់នៅ និងបរិស្ថាន។ ដូច្នេះ ក្នុងការរ៉ាប់រងសំណល់រាវ គួរមានដំណោះស្រាយដូចខាងក្រោមៈ

- ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រាវ ដែលអាចសំអាតសារធាតុរាវ ដែលកង្វក់ក្នុងសំរាមមុនការបោះចោល។
- ការគ្រប់គ្រងទៅលើ ការបញ្ចេញសំណល់រាវពីរោងចក្រដែលមានសារធាតុបំពុល ហើយបង្ហូរចូលក្នុងទឹក។
- ធានាឲ្យបាននូវផ្តល់សេវាក្នុងការប្រមូលសំរាម ដែលមានផ្តល់នូវការវេចខ្ចប់ត្រឹមត្រូវ ជៀសវាងការហូរទឹកស្អុយចេញពីសំរាម។
- ការរៀបចំនូវការអប់រំដល់ប្រជាពលរដ្ឋ ដើម្បីឲ្យមានស្វែងយល់ដល់ក្នុងការរ៉ាប់រងសំណល់រាវ។
- ពង្រឹងការអប់រំទៅដល់ប្រជារាស្ត្រនៅតាមលំនៅដ្ឋានក្នុងការរក្សា និងវេចខ្ចប់ឲ្យបានត្រឹមត្រូវ និងចៀសវាងការបង្ហូរតាមបង្គន់ដែលអាចប៉ះពាល់ដល់ប្រព័ន្ធទឹក។
- ការបង្ហូរទឹកពីសំរាមមុនបោះចោល ឬការវេចខ្ចប់ក៏អាចចូលរួមក្នុងការពារមិនឲ្យមានការហូរទឹកចេញពីសំរាម។
- ប្រជាពលរដ្ឋ ត្រូវធ្វើការបែងចែកនូវប្រភេទសំណល់ឲ្យបានច្បាស់លាស់។

**៣.១.៣. ការបំពុលខ្យល់**

ការបំពុលខ្យល់ ជាទូទៅត្រូវបានបង្កើតឡើងភាគច្រើន ដោយសារកត្តារបស់មនុស្ស។ ក្នុងកត្តានេះ ការបំពុលខ្យល់កើតឡើងដោយទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ ដែលដំណោះស្រាយអាចមានដូចខាងក្រោមៈ

- ប្រើប្រាស់ប្រេងសាំងដែលគ្មានជាតិសំណ
- ប្រើប្រាស់ផលិតផលប្រេងកាតដែលមានកំរិតស្ពាន់ធ័រទាប
- ដាំដើមឈើតាមបណ្តោយផ្លូវដែលមានចរាចរណ៍មមាញឹក ព្រោះវាអាចស្រូបយកធូលី
- កាត់បន្ថយយានយន្តប្រើប្រាស់ឥន្ទនៈផូស៊ីល
- តំបន់ឧស្សាហកម្ម និងកន្លែងចាក់សំរាមត្រូវនៅឆ្ងាយពីទីប្រជុំជន

- កាត់បន្ថយយានយន្តឯកជននៅតាមផ្លូវសាធារណៈ និងលើកទឹកចិត្តប្រជាជនឲ្យប្រើប្រាស់ទោចក្រយាន(កង់) ឬរថយន្តសាធារណៈ
- សាងសង់ផ្លូវធំៗ និងអគារខ្ពស់ៗជាមូលហេតុប្រមូលផ្តុំសារធាតុបំពុលក្នុងកម្រិតខ្ពស់
- រៀបចំធ្វើផែនការកសាងទីក្រុងដោយយកចិត្តទុកដាក់ដល់សុខភាពប្រជាជនជាបឋម
- សង់បំពង់ផ្សែងរោងចក្រ ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្រប ដើម្បីទាញយកភាគល្អិតអាសូត អុកស៊ីត និងស្ពាន់ធ័រអុកស៊ីត
- អនុវត្តការយកពន្ធលើ ការបញ្ចេញចោលឧស្ម័នកាបូនឌីអុកស៊ីត និងស្ពាន់ធ័រឌីអុកស៊ីត ហើយប្រើប្រាស់ឧបករណ៍បំប្លែងកាតាលីកម្ម ដើម្បីជួយដល់ការត្រួតពិនិត្យកាកសំណល់ផ្សេងៗ។

## ៣.២. វិធានការទូទៅនៃការគ្រប់គ្រងបរិស្ថាន

### ៣.២.១. សំណល់រឹង

#### ៣.២.១.១. ការធ្វើឲ្យប្រសើរឡើងនូវសេវាប្រមូលសំណល់ និងការសម្អាត

សេវាប្រមូល និងសម្អាត គឺជាសកម្មភាពដ៏សំខាន់ ដើម្បីធានាបាននូវបរិស្ថានស្អាត អនាម័យ និងសោភ័ណ្ឌភាពរបស់ទីក្រុង។

- ធ្វើការវាយតំលៃពីប្រសិទ្ធភាពរបស់ក្រុមហ៊ុនប្រមូលសំណល់
- ការកែលំអឲ្យមានផែនការប្រតិបត្តិការ និងប្រមូល ដែលមានស្រាប់កាន់តែប្រសើរឡើងសម្រាប់ខណ្ឌនីមួយៗ រួមមាន ការរៀបចំកាលវិភាគប្រមូលសំណល់ ចាត់ចែងទីតាំងប្រមូល (ទីតាំងសមរម្យ) និងផ្លូវចូលប្រមូល ដោយមានការសហការគ្នារវាងក្រុមហ៊ុនប្រមូល (ក្រុមហ៊ុនស៊ីនទ្រី និងក្រុមហ៊ុនដទៃទៀត) និងរដ្ឋបាលខណ្ឌះ
    - រៀបចំកាលវិភាគប្រមូលសំរាម
    - ទីតាំងស្តុកសំរាមបណ្តោះអាសន្ន
    - រៀបចំផែនការ/កាលវិភាគ បោសសំអាតតាមដងផ្លូវ និង តាមទីសាធារណៈ
    - សមត្ថភាពក្រុមហ៊ុនផ្តល់សេវាសំអាត
    - វិសាលភាពតំបន់សំអាត
    - ការគាំទ្រពីអាជ្ញាធរមូលដ្ឋាន/រាជធានីក្នុងការងារអនុវត្តន៍ និងរៀបចំទីតាំង
    - ត្រួតពិនិត្យតម្លាភាពសេវា
- ណែនាំ និងជម្រុញការអនុវត្ត សកម្មភាពប្រមូលសំណល់តាមសហគមន៍ ពិសេសចំពោះទីតាំងទាំងឡាយណា ដែលក្រុមហ៊ុនស៊ីនទ្រីពិបាកក្នុងការចូលដឹកសំរាម ដើម្បីជៀសវាងការ

បោះចោលសំរាមខុស។

- បង្កើតប្រសិទ្ធភាពក្នុងការងារទំនាក់ទំនងល្អ រវាងអាជ្ញាធររាជធានី និងក្រុមហ៊ុនប្រមូលសំរាម ដើម្បីត្រួតពិនិត្យប្រតិបត្តិការប្រមូលសំណល់ ក្រុមហ៊ុនប្រមូលសំរាម គួរប្រើប្រាស់ប្រព័ន្ធបច្ចេកទេស គ្រប់គ្រងទិន្នន័យ ដើម្បីឲ្យគេអាចតាមដាន ធ្វើផែនការដាក់ពេលវេលាប្រមូល វិភាគ និងត្រួតពិនិត្យដំណាក់កាលទាំងមូល។
    - របាយការណ៍វិភាគត្រូវចែករំលែកជាមួយភាគីពាក់ព័ន្ធក្នុងរាជធានីឲ្យបានទៀងទាត់
    - យន្តការត្រួតពិនិត្យ យន្តការឆ្លើយតប គួរតែត្រូវបានដាក់ឲ្យមាន ដើម្បីផ្តល់ឱកាសដល់អតិថិជន/ប្រជាពលរដ្ឋ ដាក់ពាក្យបណ្តឹង ឬមានយោបល់កែលម្អទៅលើបទពិសោធន៍នៃការប្រមូលសំរាមនៅក្នុងតំបន់របស់ពួកគេ ដែលអាចឲ្យក្រុមហ៊ុន ស៊ីនទ្រី វិភាគនូវមតិយោបល់ទាំងនោះ និងអាចផ្តល់ដំណោះស្រាយឲ្យបានត្រឹមត្រូវ។ ក្រុមហ៊ុនស៊ីនទ្រី គួរសហការជាមួយអាជ្ញាធរមូលដ្ឋាន ធ្វើការណែនាំដល់ម្ចាស់លំនៅដ្ឋាន ត្រួតពិនិត្យឥរិយាបទចោលសំរាម និងចាប់អ្នកបោះសំណល់ចោលខុសច្បាប់ និងបង្កើតការចូលរួម។
- ការពិនិត្យឡើងវិញនូវថ្លៃសេវាកម្ម ដើម្បីឲ្យការប្រមូលសំរាមមានប្រសិទ្ធភាពខ្ពស់ ការវិភាគសេដ្ឋកិច្ចទៅលើប្រព័ន្ធ ថ្លៃសេវាកម្មដែលអាចធ្វើបាន ដើម្បីកំណត់ថ្លៃឈ្នួលសេវាកម្មដែលមានភាពជាក់លាក់មួយក្នុងការធានាឲ្យបាននូវនិរន្តរភាព និងភាពពេញលេញនៃការប្រមូលសំរាមដែលផ្តល់ឲ្យអតិថិជន។ ក្រុមហ៊ុនស៊ីនទ្រី អាចចូលរួមបានតាមរយៈការបង្ហាញរបាយការណ៍ប្រតិបត្តិការរបស់ខ្លួន ដើម្បីតម្លាភាព និងជួយដល់ការថ្លៃសេវាឲ្យបានប្រសើរ។ វិធីសាស្ត្រពីរយ៉ាង ដែលត្រូវបានគេអនុវត្តន៍បានជោគជ័យទៅលើ ប្រព័ន្ធកំណត់តម្លៃសេវាប្រមូល គឺការកំណត់តម្លៃដែលផ្តោតទៅលើបរិមាណ និងការកំណត់តម្លៃដែលគិតលើទម្ងន់។
- កំណត់ឡើងវិញទៅលើ ភាពដៃគូជាមួយករុមហ៊ុនស៊ីនទ្រី ដើម្បីឆ្ពោះទៅរកទីផ្សារប្រកួតប្រជែងដំណើរការនេះអាចទទួលបានជោគជ័យតាមរយៈការបង្កើតគុណភាពតម្លៃសំណល់ការប្រមូលផ្តុំទីផ្សារតាមតំបន់ តាមរយៈការបែងចែកទីផ្សារតាមតំបន់នីមួយៗ សំរាប់ក្រុមហ៊ុន ឬក៏ការបង្កើតឲ្យមានការដាក់ដេញថ្លៃ ដើម្បីជំរុញការប្រកួតប្រជែង។

**ចំណាំះ** ការដាក់ឲ្យមានការដេញថ្លៃ : សាលារាជធានីភ្នំពេញនឹងវាយតម្លៃនូវលទ្ធភាពនៃការដាក់ឲ្យមាន ការដេញថ្លៃប្រកបដោយមានការប្រកួតប្រជែងទៅលើ ក្រុមហ៊ុនផ្តល់សេវាប្រមូលសំរាម។ ទោះបីជាយ៉ាងណាក៏ដោយ កុងត្រាជាមួយក្រុមហ៊ុនស៊ីនទ្រីនឹងមិនត្រូវបញ្ចប់ឆាប់ៗនេះ

ឡើយ ដូចនេះហើយ យុទ្ធសាស្ត្រនេះអាចមានប្រសិទ្ធភាពនៅក្នុងរយៈពេលវែងមួយ។ យុទ្ធសាស្ត្រនេះ រដ្ឋាភិបាលអាចបែងចែកទីតាំងនៅក្នុងរាជធានីភ្នំពេញជាច្រើនតំបន់ (ខណ្ឌ/សង្កាត់) ហើយប្រកាសឲ្យក្រុមហ៊ុននានា ដាក់ពាក្យដេញថ្លៃសំរាប់តំបន់នីមួយៗ។ ដំណើរការនេះ នឹងធ្វើឲ្យរដ្ឋាភិបាលពិនិត្យមើលគ្រប់ក្រុមហ៊ុនទាំងអស់ និងជ្រើសរើសយកក្រុមហ៊ុនដែលល្អជាងគេ។ បន្ថែមពីនេះ ការដែលអនុញ្ញាតឲ្យក្រុមតែមួយទទួលខុសត្រូវសំរាប់តំបន់ណាមួយជាក់លាក់នោះ និងជំរុញឲ្យក្រុមហ៊ុនទាំងអស់ អនុវត្តន៍សេវាកម្មប្រមូលសំរាមមានប្រសិទ្ធភាពល្អ។ ការជំរុញវិនិយោគ ក្នុងវិស័យនេះ ក៏អាចកសាង និងបង្កើតគុណតម្លៃសំណល់ក្នុងទីផ្សារ។

### ៣.២.១.២. កែប្រែឥរិយាបថបញ្ចេញសំណល់ និងកន្លែងទុកដាក់សំណល់

ការកែប្រែឥរិយាបថ ឬទំលាប់ ក្នុងការវេចខ្ចប់ ទុកដាក់ និងបញ្ចេញ ឲ្យបានត្រឹមត្រូវទៅតាមកន្លែង និងពេលវេលា ដែលបានកំណត់ គឺជាកត្តាសំខាន់ឆ្ពោះទៅរកភាពជោគជ័យ។

- អភិវឌ្ឍគោលការណ៍ណែនាំបច្ចេកទេស (សៀវភៅណែនាំ) ស្តីពីការវេចខ្ចប់សំណល់ និងការបញ្ចេញសំណល់
  - តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធទាំងអស់
  - ចំណាត់ថ្នាក់ អ្នកបង្កើតសំណល់/ប្រភពសំណល់
  - ចំណាត់ថ្នាក់ប្រភេទសំណល់
  - គោលការណែនាំលំអិត ពីការវេចខ្ចប់ និងបញ្ចេញ
  - វិធីសាស្ត្រប្រមូលសំណល់ សម្រាប់ប្រភេទនីមួយៗ
- ការរៀបចំទីតាំងបញ្ចេញសំណល់ ដោយប្រើឧបករណ៍អប្បបរិមា (ធុងតូចៗ និងធុងកុងតន័រធំៗ ជាដើម)។
- សម្ភារៈទុកដាក់សំណល់ ឬការបញ្ចេញសំណល់ ត្រូវរៀបចំឲ្យបានសមស្របទៅតាមវិធីសាស្ត្រប្រមូលសំណល់ (មធ្យោបាយប្រមូល ពីផ្ទះមួយទៅផ្ទះមួយ និងធុង/គំនរសំរាម)
  - បន្តអនុវត្តមធ្យោបាយប្រមូល ពីផ្ទះមួយទៅផ្ទះមួយនៅទីប្រជុំជនក្រុង និងធុង/គំនរសំរាមនៅតំបន់ជាយក្រុង
  - រៀបចំកាលវិភាគប្រមូលសឲ្យស៊ីចង្វាក់នឹងការបញ្ចេញ និងទីតាំងបញ្ចេញ
  - រៀបចំកាលវិភាគប្រមូលសំណល់ផ្សេងៗពីគ្នា (សំណល់កែច្នៃ សំណល់គ្រោះថ្នាក់ សំណល់ធំៗ)
- ការចែកចាយព័ត៌មាន ស្តីពីកម្មវិធី គ្រប់គ្រងសំណល់ (ថ្មី) និងការបញ្ចេញសំណល់
  - ធ្វើអោយព័ត៌មាននេះ ទៅដល់ប្រជាពលរដ្ឋ

  - យុទ្ធនាការបញ្ជ្រាបការយល់ដឹង និងការអនុវត្តន៍ល្អ
  - យុទ្ធនាការផ្សព្វផ្សាយតាមបណ្ដាញសង្គម (Facebook)
  - បញ្ចូលក្នុងកម្មវិធីអប់រំ
- ការអនុវត្ត/ការដាក់ឲ្យប្រើកម្មវិធីថ្មី សំរាប់ការគ្រប់គ្រងសំណល់ និងការបញ្ចេញសំណល់
  - ត្រូវអនុវត្តន៍ ជាជំហានៗ (ជាដំណាកាល)
  - ប្រើប្រាស់យន្តការផាកពិន័យ (យន្តការដែលមានស្រាប់ ឬត្រូវកែសម្រួលក្នុងករណីចាំបាច់)
  - ការចូលរួម/អន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន (ខណ្ឌ សង្កាត់ ភូមិ)
  - មន្ត្រីខណ្ឌ សង្កាត់ ត្រូវជូនព័ត៌មានដល់គ្រប់ប្រជាពលរដ្ឋ
- ពង្រឹងវិធានការប្រឆាំងនឹងការបោះចោលសំណល់ខុសច្បាប់
  - ការដំឡើងផ្ទាំងបដា/ស្លាកសញ្ញា ចោលសំរាមផ្ដេសផ្ដាស នៅទូទាំងរាជធានីភ្នំពេញ
  - យន្តការផាកពិន័យ ជាសាច់ប្រាក់ ឬ ការបម្រើសេវាបរិស្ថាននៅក្នុងសហាគមន៍
  - ពង្រឹងការអនុវត្តន៍ច្បាប់
  - ដំឡើងវីដេអូ កាមេរ៉ា នៅទីសាធារណៈ (ប្រសិនបើអាចធ្វើបាន)

**៣.២.១.៣. គាំទ្ររដ្ឋបាលខណ្ឌ/សង្កាត់ ដើម្បីពង្រឹងការត្រួតពិនិត្យ និងការអនុវត្តន៍**

ការងារតាមដាន និងត្រួតពិនិត្យ គឺជាការងារដ៏សំខាន់ក្នុងការធានាឲ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាព និងគុណភាព។

**ក. បង្កើតគោលការណ៍ណែនាំសូចនាករការងារសំរាប់ខណ្ឌនីមួយៗ**

បង្កើតគោលការណ៍ណែនាំសូចនាករដែលបង្ហាញពីសូចនាករការងារសំរាប់ខណ្ឌនីមួយៗ អនុវត្តន៍មានដូចជា៖

- ទីតាំងផ្តល់សេវាកម្ម
- អត្រាសេវាប្រមូលសំរាម
- ភាពញឹកញាប់នៃការប្រមូលសំរាម
- សម្ភារៈដែលអាចកែច្នៃបាន
- សំណល់រាយប៉ាយ
- បណ្ដឹងពីសាធារណៈ
- សោភ័ណ្ឌភាព និងអនាម័យទីតាំង។

**ខ. បង្កើតក្រុមការងារ/គណៈកម្មការនៅថ្នាក់ខណ្ឌ**

ដើម្បីធ្វើការសម្របសម្រួលការងារ រវាងក្រុមហ៊ុនឯកជនផ្តល់សេវាកម្ម និងប្រជាពលរដ្ឋ ហើយតាមដានរាល់ការអនុវត្តន៍របស់អ្នកផ្តល់សេវាកម្ម ព្រមទាំងរៀបចំផែនការសំរាប់ការគ្រប់គ្រងសំណល់រឹង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមការងារទាំងនេះ គួរតែមានជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីសាលារាជធានីភ្នំពេញ ឬក៏រដ្ឋបាលខណ្ឌខ្លួនឯងផ្ទាល់ ដើម្បីធានាដល់ដំណើរការរបស់វា។

**គ. រៀបចំឲ្យមានកម្មវិធីការអភិវឌ្ឍន៍សមត្ថភាព**

សាលារាជធានីភ្នំពេញនឹងអនុវត្តន៍កម្មវិធីការអភិវឌ្ឍសមត្ថភាព សំរាប់បុគ្គលិកសាលាខណ្ឌ ជាពិសេសសំរាប់ ក្រុមការងារ ឬគណៈកម្មាធិការ ដើម្បីឲ្យពួកគេមានលទ្ធភាពរៀបចំផែនការគ្រប់គ្រងសំណល់ និងតាមដានការអនុវត្តន៍របស់ក្រុមហ៊ុនផ្តល់សេវាកម្ម។

**ឃ. បន្តអនុវត្តន៍ភ្នាក់ងារសង្កាត់**

វិធីសាស្ត្រដែលមានភ្នាក់ងារសង្កាត់ ពីរនាក់ក្នុងមួយសង្កាត់ សំរាប់ការត្រួតពិនិត្យប្រចាំថ្ងៃ និងណែនាំប្រជាពលរដ្ឋ នៅលើការវេចខ្ចប់សំណល់ឲ្យបានត្រឹមត្រូវ និងការបញ្ចេញសំរាម គួរតែបន្តអនុវត្តន៍។ ភ្នាក់ងារសង្កាត់ទាំងនេះអាចត្រូវបានដាក់បញ្ចូលនៅក្នុងក្រុមការងារខណ្ឌ ហើយពួកគេនឹងត្រូវបានបណ្តុះបណ្តាលបនន្ថែមទៀត ដើម្បីឲ្យមានចំណេះដឹងលើ គោលការណ៍ណែនាំបច្ចេកទេស និងសូចនាករត្រួតពិនិត្យផ្សេងៗ។

**ង. រៀបចំក្របខណ្ឌគ្រប់គ្រង**

រៀបចំក្របខណ្ឌគ្រប់គ្រងដោយបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន លើទិដ្ឋភាពបច្ចេកទេសនៃការទុកដាក់សំណល់ចុងក្រោយ រួមទាំងការគូសផែនទី ការតាមដាន និងត្រួតពិនិត្យការប្រមូលសំរាម។ ចាត់តាំងភារកិច្ច និងបណ្តុះបណ្តាលរដ្ឋបាលខណ្ឌលើរបៀបតាមដានដោយប្រើប្រព័ន្ធទូរស័ព្ទ ដូចជា Facebook, WhatsApp និងកម្មវិធីបណ្តាញសង្គមផ្សេងៗទៀត។[24]

## ៣.២.២. សំណល់រាវ

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការឲ្យបានម៉ឺនម៉ាត់ក្នុងការៈ

- ទប់ស្កាត់ការរំលោភយកដីសាធារណៈនៃប្រព័ន្ធលូ ឬការសាងសង់សំណល់ផ្សេងៗ ដែលធ្វើឲ្យខូចខាតប្រព័ន្ធលូ ឬរាំងស្ទះដល់ចរន្តហូរនៃប្រព័ន្ធលូ។
- ទប់ស្កាត់ ការរំលោភយកដីសាធារណៈនៃអាងស្តុកធម្មជាតិ ឬការចាក់ដីលុបអាងស្តុកធម្មជាតិដែលធ្វើឲ្យបាត់បង់សមត្ថភាពស្តុក ឬសម្អាតទឹកកខ្វក់។

[24] Final Workshop on Formulation of a Waste Management Strategy for Phnom Penh 2018-2015

- សិក្សា និងធ្វើការបង្វែរប្រព័ន្ធលូបញ្ចេញទឹកកខ្វក់ទីប្រជុំជនដែលហូរ ចូលផ្ទាល់ទៅក្នុងតំបន់ទឹកសាធារណៈ ឲ្យហូរឆ្លងកាត់អាងស្តុកធម្មជាតិ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជាមុន។
- រៀបចំផែនការ និងជំរុញការអនុវត្តការស្តារអាងស្តុកធម្មជាតិ ដើម្បីធានាសមត្ថភាពស្តុក និងសម្អាតតាមលក្ខណៈធម្មជាតិនៃទឹកកខ្វក់ទីប្រជុំជន។
- ធ្វើការគ្រប់គ្រង និងដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ដើម្បីធានាគុណភាពទឹកកខ្វក់សំអាតរួច ដែលត្រូវបញ្ចេញ គឺឆ្លើយតបនឹងស្តង់ដាបញ្ចេញទឹកកខ្វក់។

ម្ចាស់លំនៅដ្ឋាន និងលំនៅដ្ឋានប្រមូលផ្តុំ ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោមៈ

- រៀបចំអាងសិបទិចអនុលោមតាមលិខិតអនុញ្ញាតសាងសង់។
- ស្នើសុំធ្វើ ការតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ។
- បង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ក្នុងករណីដែលទឹកកខ្វក់ក្នុងតំបន់ទីប្រជុំជន ត្រូវបានប្រមូលទៅសំអាតនៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។

ម្ចាស់អគារអាជីវកម្ម ដែលទីតាំងស្ថិតនៅក្នុងតំបន់ទីប្រជុំជន មានស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោមៈ

- រៀបចំអាងសិបទិចរួមអនុលោមតាមលិខិតអនុញ្ញាតសាងសង់។
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូ ចូលទៅក្នុងប្រព្រ័ន្ធលូដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។
- ស្នើសុំលិខិតអនុញ្ញាត បញ្ចេញចោលទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូ ដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។
- បង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

ម្ចាស់អគារអាជីកម្ម ដែលទីតាំងស្ថិតនៅក្នុងតំបន់ទីប្រជុំជន ពុំមានស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួមត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោមៈ

- រៀបចំអាងសិបទិចរួមអនុលោមតាមលិខិតអនុញ្ញាតសាងសង់។
- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ឲ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់។

- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ក្នុងករណីត្រូវប្រើប្រាស់សម្រាប់ ការបញ្ចេញទឹកកខ្វក់ដែលសម្អាតរួច។
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ ចូលក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ។

ម្ចាស់អាគារអាជីវកម្ម និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្តដែលមានទីតាំងនៅតាមដង ឬដីចំណីសមុទ្រ ទន្លេ ស្ទឹង ព្រែក បឹង។ល។ ឬស្ថិតនៅលើផ្ទៃទឹកដែលទទួលបានសិទ្ធអាជីវកម្មស្របច្បាប់ត្រូវទទួលខុសត្រូវគ្រប់គ្រងទឹកកខ្វក់ពីសមត្ថភាពអាជីវកម្មរបស់ខ្លួន ដូចខាងក្រោម៖

- មិនធ្វើការបង្ហូរទឹកកខ្វក់ ដែលមិនទាន់បានឆ្លងកាត់ប្រព្រឹត្តកម្មសម្អាតចូលទៅក្នុងតំបន់ទឹកសាធារណៈ។
- រៀបចំប្រព័ន្ធស្តុកទឹកកខ្វក់រួម សម្រាប់ការបូមបញ្ចេញទៅក្នុងប្រព័ន្ធលូសាធារណៈ ឬដឹកជញ្ជូនចេញយកទៅសម្អាតនៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម តាមការតម្រូវរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ។
- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ឲ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់។
- ស្នើសុំលិខិតអនុញ្ញាត បញ្ចេញចោលទឹកកខ្វក់ ដែលសម្អាតរួចចូលទៅក្នុងតំបន់ទឹកសាធារណៈ។

ម្ចាស់បុរីលំនៅដ្ឋាន និងទីក្រុងរណប ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវ ក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖

- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ក្នុងតំបន់គ្រប់គ្រងរបស់ខ្លួន ឲ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់។
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ក្នុងករណីត្រូវការប្រើប្រាស់សម្រាប់ការបញ្ចេញទឹកកខ្វក់ដែលសម្អាតរួច។
- ស្នើសុំលិខិតអនុញ្ញាត បញ្ចេញចោលទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ។

### ៣.២.៣ ការបំពុលខ្យល់

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ:

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល ដើម្បីឲ្យឆ្លើយតបទៅនឹងកំណត់កំរិតស្តង់ដារ។
- ទទួលខុសត្រូវក្នុងការដំឡើង គ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុល ដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែ ម្តង។
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវ ក្នុងកិច្ចសម្របសម្រួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរប់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ។

## ៣.៣ វិធានការផាកពិន័យ

### ៣.៣.១ សំណល់រឹង

ក្នុងករណីមិនអនុវត្តតាមការណែនាំ ឬក៏ប្រព្រឹត្តល្មើសនឹងចំណុចណាមួយខាងលើ ម្ចាស់ទីតាំងនិងក្រុមហ៊ុនផ្តល់សេវាម្មទាំងអស់ នឹងត្រូវទទួលការផាកពិន័យអន្តរការណ៍ដូចខាងក្រោមៈ

- ពិន័យជាប្រាក់ចាប់ពី ១០.០០០រៀល ដល់ ២.០០០.០០០រៀន។
- ពិន័យជាប្រាក់ចាប់ពី ១.០០០.០០០រៀល ដល់ ៥០.០០០.០០០រៀល ឡើងទៅនឹងត្រូវបិទអាជីវកម្ម ឬផ្អាកការរដ្ឋាសាងសង់ជាបណ្តោះអាសន្ន ក្នុងករណីធ្ងន់ធ្ងរដែលមន្ត្រីជំនាញពិនិត្យឃើញថាមានការបង្កផលប៉ះពាល់ដល់បរិស្ថាន និងសង្គម។
- ក្នុងករណី មិនរាងចាល ត្រូវទទួលការពិន័យជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។
- ចំពោះបុគ្គលណា ដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះ នៅក្នុងរយៈពេល ៣០ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើពី៦០ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងបីដង។ បើផុតរយៈពេល ៩០ថ្ងៃ ត្រូវរៀបចំឯកសារប្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន។
- មន្ទីរបរិស្ថានរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ ភ្នាក់ងារអនាម័យ និងស្ថាប័នមានសមត្ថកិច្ចនានា ជាអ្នកអនុវត្តវិធានការពិន័យអន្តរការណ៍ខាងលើ ចំពោះម្ចាស់ទីតាំងឬបុគ្គលណាដែលបានអនុវត្តខុសនឹងសេចក្តីណែនាំ។

### ៣.៣.២ សំណល់រាវ

បុគ្គលដែលយកសំរាម សំណល់រឹង សំណល់ប្រេងឥន្ទនៈ សារធាតុគីមី ឬសំណល់ភក់ចាក់ចូលប្រព័ន្ធលូ ឬប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោមៈ

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាបប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀលទៅ ៥.០០០.០០០ (ប្រាំលាន)រៀល
- ការប្រមូលយកសំណល់ ឬសារធាតុ ដែលបានចាក់ចូល ចេញ ពីប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។[25]

### ៣.៣.៣ ការបំពុលខ្យល់

បើការប្រព្រឹត្តល្មើសបង្កឲ្យមាន គ្រោះថ្នាក់ដល់រាងកាយ ឬជីវិតមនុស្ស ដល់ទ្រព្យសម្បត្តិឯកជន ដល់ទ្រព្យសម្បត្តិសាធារណៈ ដល់បរិស្ថាន ដល់ធនធានធម្មជាតិ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ដប់លានរៀល (១០.០០០.០០០រៀល) ដល់ហាសិបលានរៀល (៥០.០០០.០០០រៀល) ឬផ្តន្ទាទោស ដាក់ពន្ធនាគារពីមួយឆ្នាំដល់ប្រាំឆ្នាំ ឬទោសទាំងពីរនេះ។ ឬ បុគ្គលដែលប្រព្រឹត្តល្មើសត្រូវទទួលជួសជុលសងការខូចខាត និងសងជំងឺចិត្តថែមទៀត។

[25] អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ (មាត្រា៥០)

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើ យើងសង្កេតឃើញថា នាពេលបច្ចុប្បន្ននេះ បញ្ហាបរិស្ថាន គឺជាបញ្ហាធំមួយនៅក្នុងសង្គម ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺប្រទេសកម្ពុជា ជាដើម។ បើតាមការបកស្រាយខាងលើ ការគ្រប់គ្រងបរិស្ថាន គឺជាផ្នែកមួយយ៉ាងសំខាន់ចំពោះភាវៈទាំងអស់គឺទាំងភាវៈមានជីវិត និងភាវៈគ្មានជីវិត។ ទន្ទឹមនឹងនេះ បរិស្ថាននៅក្នុងរាជធានីភ្នំពេញ គឺជាកត្តាមួយសំខាន់ ដើម្បីឲ្យទីក្រុងមានសោភ័ណ្ឌភាព និងការរស់នៅរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់នោះឲ្យមានលក្ខណៈល្អប្រសើរ។

ដើម្បីធានាឲ្យបាននូវការរៀបចំសណ្តាប់ធ្នាប់ក្នុងទីក្រុងនេះ ការបែងចែក និងការសិក្សាទៅលើបុព្វហេតុដែលនាំឲ្យមានការរៀបចំក្រុងកើតឡើង ដែលក្នុងនោះមានដូចជា កំណើនប្រជាជន សេដ្ឋកិច្ចប្រជាជន សេដ្ឋកិច្ច ចរាចរណ៍ សន្តិសុខ និងសណ្តាប់ធ្នាប់ ដែលត្រូវបានចោទជាបញ្ហាដែលបណ្តាលឲ្យមានការរៀបចំនេះ។ ដោយនៅក្នុងការស្រាវជ្រាវនេះ ផ្តោតសំខាន់ទៅលើ ការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ ដោយមានការបំពុលដោយកាកសំណល់រឹង រាវ និងខ្យល់ ដែលជាបញ្ហាធ្វើឲ្យមានផលប៉ះពាល់សុខភាព ព្រមទាំងការរស់នៅរបស់ប្រជាជន ដែលនៅតំបន់នោះយ៉ាងធ្ងន់ធរ។ តួយ៉ាង បញ្ហាទាំងនេះក៏ត្រូវបានភ្ជាប់មកជាមួយនឹងដំណោះស្រាយដែរ ដើម្បីឲ្យសមស្របក្នុងការបង្កើតគុណភាពនៃបរិស្ថានផងដែរ។

សរុបមក ការគ្រប់គ្រងបរិស្ថាននៅក្នុងរាជធានីភ្នំពេញ តម្រូវឲ្យមានការសិក្សា ស្វែងយល់បន្ថែមទៀត ដើម្បីឈានដល់ការរៀបចំដែលមានប្រសិទ្ធិភាព។ ក្នុងនោះដែរ ដើម្បីឲ្យមានប្រសិទ្ធភាព ដល់តែមានការចូលរួមរវាងប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ និងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍ក្រុងភ្នំពេញនេះ ព្រមទាំងប្រទេសឲ្យមានសណ្តាប់ធ្នាប់ និងសោភ័ណ្ឌភាពល្អ។

# អនុសាសន៍

# អនុសាសន៍

ដោយផ្អែកទៅលើសេចក្តីសន្និដ្ឋានដូចបានរៀបរាប់ខាងលើ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីជាយោបល់មួយក្នុងការជួយកាត់បន្ថយនូវការគ្រប់គ្រងបរិស្ថាននៅរាជធានីភ្នំពេញ៖

- មិនចោលសំរាមកាកសំណល់ជាតិពុលចាល់ក្នុងទឹក
- ជួយថែរក្សាសម្អាតទីធ្លាសាធារណៈ និងគេហដ្ឋាន
- កាត់បន្ថយការប្រើថ្នាំគីមី ការកាប់បំផ្លាញព្រៃឈើ
- ដាំដើមឈើឡើងវិញក្នុងសាលារៀន សហគមន៍
- ជួយរក្សាអនាម័យទឹក ដីកាត់បន្ថយផ្សែងពុលផ្សេងៗ
- ចូលរួមធ្វើអនាម័យតាមសហគមន៍ និងបំផុសការការពារបរិស្ថាន
- បំផុសការផ្សព្វផ្សាយឲ្យបានទូលាយ ពីសារៈសំខាន់នៃការការពារបរិស្ថាន តាមរយៈការរួបរួមសាមគ្គីគ្នាគ្រប់មជ្ឈដ្ឋាន
- ជំរុញការអនុវត្តច្បាប់បរិស្ថានឲ្យមានប្រសិទ្ធភាព
- សាងសង់រោងចក្រ អោយឆ្ងាយពីទីក្រុង និងទីប្រជុំជន
- ទុកដាក់សម្រាមអោយមានរបៀប សម្អាត និងដឹកចេញពីទីក្រុងអោយបានស្អាត
- បង្កើតរោងចក្រកែច្នៃសម្រាម
- អប់រំប្រជាពលរដ្ឋអោយមានការយល់ដឹង ពីវិធីថែរក្សា និងការពារបរិស្ថាន
- ប្រើប្រាស់យានយន្តស្របតាមបច្ចេកទេស
- បន្ថយតម្លៃផ្គត់ផ្គង់ទឹកស្អាត ក្នុងការរក្សាអនាម័យ
- ចាត់វិធានការច្បាប់តឹងរឹង សម្រាប់អ្នកបំពុលបរិស្ថាន
- កាត់បន្ថយការប្រើប្រាស់សារធាតុគីមីពុល

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត

- អនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសំណល់រឹង
- អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ២៣៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។
- សេចក្តីណែនាំស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ, លេខ០០២/១៩ សណនស ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩។

## សៀវភៅ

- ឯកសារ ការអប់រំបំណិនជីវិតស្តីពីបរិស្ថាន ពីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ ២០១៣ នៃក្រសួងអប់រំ យុវជន និងកីឡា។

## គេហទំព័រ

- https://l.facebook.com/l.php?u=https%3A%2F%2Fdrive.google.com%2Ffile%2Fd%2F13-EnRrGBi1uhR6lliUmzLPqQHRYWYGB1%2Fview%3Fusp%3Ddrivesdk%26fbclid%3DIwAR176TbtAJvEnw-gxGYpB_xdDKHBmeeeh-fM2LCBj3yKgXCiM1UvAhWsbrU&h=AT2zwnvZWuoHB3FG2-H9P4a8Dgf-MFZhJlzDPE2j1hWHby19eYfXaY5s0ZmlGef0_bUVdybHXxD69pAVcd6ng46ghmTcdGXqlfFQHjFn6iToD-4DjqnFhvEDgkL-Ubjl7Me2
- https://l.facebook.com/l.php?u=https%3A%2F%2Fdrive.google.com%2Ffile%2Fd%2F115Q6UqhxY7Xo_fV364orMJ4SO5Msn2qP%2Fview%3Fusp%3Ddrivesdk%26fbclid%3DIwAR2XeIgBrRU6FN7KZ5MUczCdZZ4F4XCPUJKCnihYPKrElhJZ8UxV2VuWv7U&h=AT0uiAq9V4WQBtgEshBd2FVcR_5--3IH7ObXkv5Qi9vNPv3PIPSjibCRq7efJh9dhIQPbttzTt3I5SSBLTckVqThFgsK3OAZWF-UI2hE5i94aUoLTXY02JQCiNSfLwlszskH
- https://seylanote.wordpress.com/2012/07/12/%E1%9E%80%E1%9E%B6%E1%9E%9A%E2%80%8B%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%94%E1%9F%8B%E2%80%8B%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%84%E2%80%8B%E1%9E%9F%E1%9F%86%E1%9E%8E%E1%9E%9B%E1%9F%8B%E2%80%8

B%E1%9E%9A/?fbclid=IwAR3KBbMm8z1LtRf3vShqV1ZbDcIQpp5qqe8_00I3tlTp7jFhLB8oDi43GVw

- http://www.cicp.org.kh/userfiles/Worrking%20paper/CICP%20Working%20Paper%2017%20solid%20waste%20management Edited.pdf.
- 3RKH,″3R Good Practices in Cambodia: Phnom Penh Waste Management (PPWM)″, accessed on erApril 06,2015, URL: http//www.faculty.ait.ac.th/visu/NGOs/pdfs/cambodia-%20NGO/SJ-PPWM.pdf
- CINTRI, ‶Recycling Project, ″last modified 2011 , accessed on April 06, 2015, URL: http://www.cintri.com.kh/PHP/RecyclingProject.php
- Meeting with Denis Schley, country Representative of Cambodia of Konrad-Adenauer-sifting (KAS) on April 03, 2015
- Ministry of Environment, ‶Cambodia Environment″,67

# ឧបសម្ព័ន្ធ

## បញ្ជីរាយឈ្មោះឯកសារក្នុងឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១** តារាងកំណត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់ទីប្រជុំជន នៅរាជធានីភ្នំពេញ
- **ឧបសម្ព័ន្ធទី២** សេចក្តីណែនាំស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ លេខ ០០២/១៩ សណន.ស
- **ឧបសម្ព័ន្ធទី៣** សារាចរអន្តរក្រសួងស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន លេខ ១០៧០ ស.ជ.ណ.ប.ស្ត
- **ឧបសម្ព័ន្ធទី៤** អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន លេខ ១១៣ អនក្រ.បក
- **ឧបសម្ព័ន្ធទី៥** អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ លេខ ២៣៥ អនក្រ.បក
- **ឧបសម្ព័ន្ធទី៦** អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង លេខ ៤២ អនក្រ.បក
- **ឧបសម្ព័ន្ធទី៧** រូបភាព

# ឧបសម្ព័ន្ធទី១
# តារាងកំណត់កម្រៃសេវាគ្រប់គ្រង
# សំរាម សំណល់រឹងទីប្រជុំជននៅ
# រាជធានីភ្នំពេញ

# ឧបសម្ព័ន្ធទី២
# សេចក្តីណែនាំស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងនៅ
# រាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ: ០៨៤/១៩ សណាន-ស

# សេចក្ដីណែនាំ
## ស្ដីពី
## ការគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

សុខសន្តិភាពពេញផ្ទៃប្រទេស ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ប្រជាពលរដ្ឋមានជីវភាពកាន់តែធូរធារឡើងៗ ហើយសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញក៏មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើឱ្យបរិមាណសំរាម សំណល់រឹងមានការកើនឡើងជាលំដាប់ ប៉ុន្តែការគ្រប់គ្រងសំរាមនៅមិនទាន់សមស្របតាមលិខិតបទដ្ឋានគតិយុត្ត និងលក្ខណៈបច្ចេកទេសនៅឡើយ ដែលតម្រូវឱ្យរដ្ឋបាលរាជធានីភ្នំពេញ ត្រូវយកចិត្តទុកដាក់គ្រប់គ្រងឱ្យបានហ្មត់ចត់។

កន្លងមក រដ្ឋបាលរាជធានីភ្នំពេញបានខិតខំប្រឹងប្រែងប្រើគ្រប់មធ្យោបាយទាំងសម្ភារ និងស្មារតី និងបានសហការជាមួយក្រុមហ៊ុន សម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ប៉ុន្តែការងារនេះនៅពុំទាន់បានឆ្លើយតបតាមគោលបំណង និងសេចក្តីត្រូវការនៃភាពស្អាតរបស់ទីក្រុងនៅឡើយ ដែលតម្រូវឱ្យប្រជាពលរដ្ឋ អ្នកបង្កើតសំរាម សំណល់រឹង និងក្រុមហ៊ុនសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ព្រមទាំងអ្នកពាក់ព័ន្ធនានាចូលរួមសហការទទួលខុសត្រូវអនុវត្តឱ្យបានព្រមៗគ្នា ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដូច្នេះ ដើម្បីឱ្យរាជធានីភ្នំពេញ មានសោភ័ណភាព សណ្តាប់ធ្នាប់ អនាម័យ និងបរិស្ថានស្អាតជានិច្ច ក្លាយជាទីក្រុងបៃតង ដែលជាទីកន្លែងផ្តល់នូវសុខុមាលភាពរស់នៅរបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ និងយោងតាមច្បាប់ស្តីពី "កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ និងអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន" រដ្ឋបាលរាជធានីភ្នំពេញ សូមដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម៖

**១. ចំពោះម្ចាស់លំនៅឋាន ទីតាំងអាជីវកម្ម សេវាកម្ម ភោជនីយដ្ឋាន ទីផ្សារ ទីកន្លែងកំសាន្ត ម្ចាស់ប្រភពបង្កើតសំណល់នានា និងប្រជាពលរដ្ឋ មានភារកិច្ចដូចខាងក្រោម៖**

- ត្រូវធ្វើការញែកសំរាមទៅតាមប្រភេទដាក់ដោយឡែកពីគ្នា រវាងសំណល់ផ្ទះបាយ (សំរាមសើម) និងសំរាមអាចកែច្នៃបាន (សំរាមស្ងួត) ដោយត្រូវធ្វើការវេចខ្ចប់ដាក់ក្នុងថង់ ឬធុងសំរាមផ្សេងពីគ្នា មិនឱ្យមានការលេចធ្លាយ ឬជ្រាបទឹក និងក្លិនស្អុយ រួចយកទៅដាក់នៅតាមមុខលំនៅឋាន ឬតាមទីតាំងដែលបានកំណត់ដោយរដ្ឋបាលខណ្ឌ សង្កាត់ ឱ្យបានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់ល្អ
- សំរាមដែលបានវេចខ្ចប់ហើយ ត្រូវបញ្ចេញឱ្យបានទៀងទាត់ទៅតាមកម្មវិធីប្រមូល និងដឹកជញ្ជូនដែលបានកំណត់។ ក្នុងករណីយកសំរាមមកមិនទាន់រថយន្តដឹកសំរាម គឺមិនត្រូវទុកសំរាមចោលមុខលំនៅឋាន លើចិញ្ចើមផ្លូវ ឬទ្រូងផ្លូវឡើយ ត្រូវយកសំរាមទាំងនោះទៅរក្សាទុកក្នុងទីតាំងរបស់ខ្លួនជាបណ្តោះអាសន្ន រង់ចាំការបញ្ចេញនៅវេនលើកក្រោយទៀត

- ចំពោះការប្រារព្ធពិធីផ្សេងៗ ឬការប្រគុំតន្ត្រីនៅតាមទីសាធារណៈ ម្ចាស់ពិធីត្រូវរៀបចំឱ្យមានធុងសំរាម និងវេចខ្ចប់ ទុកដាក់សំរាម សំណល់រឹងក្នុងធុងឱ្យមានសណ្តាប់ធ្នាប់ មានអនាម័យ និងមានសោភ័ណភាពល្អ
- ហាមដាច់ខាតការបោះចោល ឬការដុតសំរាម សំណល់រឹង នៅតាមដងផ្លូវ ទីសាធារណៈ ទីវាលតាមប្រព័ន្ធទឹកលូ ប្រឡាយ ឬប្រភពទឹកសាធារណៈ ក្នុងដីឡូតិ៍ទំនេរ ឬក្នុងដីកម្មសិទ្ធិឯកជន។

២. **ចំពោះម្ចាស់ទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម ការដ្ឋានសាងសង់ មានភារកិច្ចដូចខាងក្រោម៖**
- ត្រូវធ្វើការញែក និងបែងចែកសំណល់អាចកែច្នៃ ឬប្រើប្រាស់ឡើងវិញបាន ដាច់ដោយឡែកពីសំរាម សំណល់រឹងនិងសំណល់គ្រោះថ្នាក់ ដែលត្រូវបោះចោល និងប្រមូលដឹកជញ្ជូនដោយក្រុមហ៊ុនឯកជន
- ត្រូវរៀបចំឱ្យមានទីកន្លែងទុកដាក់សំរាម សំណល់រឹង សំណល់គ្រោះថ្នាក់ដែលបានញែករួច ទៅតាមប្រភេទនីមួយៗ ដើម្បីធានាឱ្យមានអនាម័យ និងសោភ័ណភាពល្អស្អាត ទាំងខាងក្នុង និងជុំវិញទីតាំងរបស់ខ្លួន
- សំណល់ការដ្ឋានសំណង់មានដូចជា កំទេចកំទីដី ថ្ម ឥដ្ឋ ក្បឿង បាយអរ ខ្សាច់... មិនអាចដឹកយកទៅចាក់បំពេញទីកន្លែងណាមួយផ្សេងទៀតបានទេ បើគ្មានការអនុញ្ញាតពីរដ្ឋបាលមូលដ្ឋានជាមុន
- ចំពោះសំណល់ឧស្សាហកម្ម សិប្បកម្ម ការដ្ឋានសំណង់ ជាប្រភេទគ្រោះថ្នាក់មានដូចជា កំទេចក្រណាត់ អេប៉ុង ភក់ កៅស៊ូ កញ្ចក់ សេរ៉ាមិច ម្នាងសិលា ថ្នាំលាប។ល។ ត្រូវប្រមូល និងដឹកជញ្ជូនយកទៅចាក់នៅទីលានចាក់សំណល់ឧស្សាហកម្ម
- ហាមដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹង នៅតាមដងផ្លូវ ទីសាធារណៈ ទីវាលតាមប្រព័ន្ធទឹកលូ-ប្រឡាយ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជននានា។

៣. **ចំពោះក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង មានភារកិច្ចដូចខាងក្រោម៖**
- ទទួលខុសត្រូវលើការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ពីតាមលំនៅឋាន ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស ទីផ្សារ ទីកន្លែងកំសាន្ត អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានា នៅក្នុងរាជធានីភ្នំពេញឱ្យបានស្អាតជាប្រចាំ
- ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ឱ្យបានច្បាស់លាស់ និងសមស្របតាមស្ថានភាពភូមិសាស្ត្រ ដោយមានការពិគ្រោះយោបល់ និងឯកភាពពីអាជ្ញាធរសង្កាត់ ខណ្ឌ និងរដ្ឋបាលរាជធានីភ្នំពេញ
- ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយ និងផ្តល់កម្មវិធីដឹកជញ្ជូនសំរាម សំណល់រឹង ដល់អាជ្ញាធរខណ្ឌ សង្កាត់ ភូមិ ប្រជាពលរដ្ឋគ្រប់លំនៅឋាន និងគ្រប់ម្ចាស់ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានានៅក្នុងរាជធានីភ្នំពេញឱ្យបានដឹង ដើម្បីងាយស្រួលក្នុងការបញ្ចេញសំណល់ឱ្យបានស្របគ្នានឹងម៉ោងដឹកជញ្ជូន
- ត្រូវធានាការប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងទៅកាន់ទីលានទុកដាក់សំរាម សំណល់រឹង កុំឱ្យជ្រុះរាយប៉ាយលើផ្លូវ កុំឱ្យហូរស្រក់ទឹកសំណល់ធ្លាក់មកលើថ្នល់ផ្លូវ និងត្រូវបោសសម្អាតកន្លែងដែលប្រមូលនោះឱ្យបានស្អាតល្អ
- ត្រូវធានាបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅតាមដងផ្លូវនីមួយៗឱ្យបាន

ស្អាត និងគោរពទៅតាមម៉ោងពេលនៃកម្មវិធីដែលបានកំណត់។ ក្នុងករណីយឺតយ៉ាវមិនបានអនុវត្ត តាមកម្មវិធីម៉ោងពេលកំណត់ នឹងត្រូវទទួលការព្រមានពីអាជ្ញាធរមានសមត្ថកិច្ច និងទណ្ឌកម្មផ្សេងៗ តាមច្បាប់ជាធរមាន

- ត្រូវរៀបចំឱ្យមានរថយន្តដឹកជញ្ជូន ដែលមានស្លាកសញ្ញាសម្គាល់រថយន្តដឹកសំរាមអាចកែច្នៃបាន (សំរាមស្ងួត) និងសំរាមផ្ទះបាយ (សំរាមសើម) ដោយភ្ជាប់ជាមួយនូវតារាងផែនការ និងកាលវិភាគរថយន្តចេញចូលដឹកជញ្ជូនតាមប្រភេទនីមួយៗឱ្យដាច់ចេញពីគ្នា និងច្បាស់លាស់
- ត្រូវផ្សព្វផ្សាយកម្មវិធី និងកាលវិភាគប្រមូលសំរាម សំណល់កែច្នៃ សំណល់គ្រោះថ្នាក់ ឱ្យដល់ដៃប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយសហការជាមួយរដ្ឋបាលខណ្ឌ សង្កាត់មានសមត្ថកិច្ច
- ត្រូវរៀបចំដាក់ធុងសំរាមនៅតាមទីធ្លាសាធារណៈ សួនច្បារ និងតាមផ្លូវសាធារណៈសំខាន់ៗឱ្យទៅតាមប្រភេទសំរាម និងសំណល់រឹងនីមួយៗ ។

៤. **ការផ្តល់សេវាប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹង និងសំណល់គ្រោះថ្នាក់៖**

- ម្ចាស់ទីតាំងនីមួយៗ ត្រូវទទួលយកសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង និងសំណល់គ្រោះថ្នាក់ ជាមួយក្រុមហ៊ុន ឬអង្គភាព ដែលទទួលបានអាជ្ញាប័ណ្ណប្រមូល និងដឹកជញ្ជូនសំណល់ទាំងនេះ
- ម្ចាស់ទីតាំងទាំងអស់ដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់គ្រោះថ្នាក់ ត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទុកដាក់សំណល់ទាំងនោះ ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានីភ្នំពេញ និងក្រសួងស្ថាប័នពាក់ព័ន្ធ។

៥. **រដ្ឋបាលខណ្ឌ សង្កាត់ មានភារកិច្ចដូចខាងក្រោម៖**

- សម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- អប់រំផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋឱ្យយកចិត្តទុកដាក់ក្នុងការញែក វេចខ្ចប់ ទុកដាក់ និងការបោះចោលសំរាម សំណល់រឹងឱ្យបានត្រឹមត្រូវនៅតាមទីកន្លែង និងពេលវេលាដែលបានកំណត់ស្របតាមកម្មវិធីប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង
- ត្រូវសម្របសម្រួលក្នុងការកំណត់ទីតាំងទុកដាក់សំរាម សំណល់រឹងបណ្តោះអាសន្ន រួមទាំងធុងសំរាមសាធារណៈឱ្យបានសមស្រប ដោយមិនបង្កបញ្ហាប៉ះពាល់ដល់ការធ្វើចរាចរណ៍ សុខុមាលភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម
- សហការជាមួយមន្ទីរបរិស្ថាន ជួយដាក់ស្លាកសញ្ញាហាមឃាត់ ការទុកដាក់ និងការបោះចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ នៅតាមទីតាំងសំខាន់ៗមួយចំនួននៅក្នុងរាជធានីភ្នំពេញ
- ត្រូវធានាថាគ្មានសំរាម សំណល់រឹងនៅសេសសល់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយត្រូវធ្វើការតាមដានត្រួតពិនិត្យ និងជំរុញការងារប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងរបស់ក្រុមហ៊ុនផ្តល់សេវាឱ្យអនុវត្តបានទៀងទាត់តាមកម្មវិធី។ ក្នុងករណីក្រុមហ៊ុនផ្តល់សេវា មិនបានគោរពតាមកម្មវិធីដឹកជញ្ជូនរបស់ខ្លួន រាប់ទាំងការដឹកជញ្ជូនដែលធ្វើឱ្យជ្រុះសំរាម ហូរទឹកសំរាមលើដងផ្លូវ និងមានសំរាមសល់គរចោលច្រើន ត្រូវធ្វើសេចក្តីរាយការណ៍មករដ្ឋបាលរាជធានីភ្នំពេញភ្លាមអំពីទីតាំងដែលក្រុមហ៊ុនមិនបានអនុវត្តនោះ ដើម្បីមានវិធានការ

- ដឹកនាំកងកំលាំងនគរបាលខណ្ឌ សង្កាត់ ភ្នាក់ងារអនាម័យ មន្ត្រីបរិស្ថាន ចុះទប់ស្កាត់ ណែនាំ និង ពិន័យជាប្រាក់ចំពោះអ្នកចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់ និងអ្នកបញ្ចេញសំរាម សំណល់រឹងមកដាក់ក្រៅលំនៅឋាន ខុសទីតាំង និងម៉ោងពេលកំណត់
- ចូលរួមសម្របសម្រួលដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសម្អាត ប្រមូល ដឹកជញ្ជូន និងថ្លៃសេវាដឹកជញ្ជូនសំរាម សំណល់រឹង របស់ប្រជាពលរដ្ឋ ម្ចាស់អាជីវកម្ម សេវាកម្ម មូលដ្ឋានបង្កើតសំណល់ ជាមួយក្រុមហ៊ុនផ្តល់សេវាកម្មសំរាម សំណល់រឹង នៅក្នុងមូលដ្ឋានរបស់ខ្លួន
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**៦. មន្ទីរបរិស្ថានរាជធានីភ្នំពេញ មានភារកិច្ចដូចខាងក្រោម៖**

- ត្រូវត្រួតពិនិត្យវឌ្ឍនភាពក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំរាម ក្នុងការរៀបចំផែនការ កម្មវិធី និងកាលវិភាគនានា ដែលកំណត់ក្នុងសេចក្តីណែនាំនេះ
- ត្រូវរៀបចំផែនការត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុន រួចធ្វើរបាយការណ៍ជូនរដ្ឋបាលរាជធានីភ្នំពេញ
- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាន តាមរយៈការអប់រំ ការផ្សព្វផ្សាយ អំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំមន្ត្រីទទួលបន្ទុកការងារបរិស្ថានប្រចាំខណ្ឌនីមួយៗ ឱ្យសហការជាមួយអាជ្ញាធរខណ្ឌ សង្កាត់ ចុះពិនិត្យស្ថានភាពការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងខណ្ឌ សង្កាត់នីមួយៗឱ្យបានជាប្រចាំ និងរាយការណ៍មករដ្ឋបាលខណ្ឌ ដើម្បីរកវិធីដោះស្រាយ
- ត្រូវអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងអនុវត្តវិធានការផាកពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន
- ផ្តល់កិច្ចសហការឱ្យបានជិតស្និទ្ធិជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌ សង្កាត់ ក្នុងការរៀបចំភ្នាក់ងារពិន័យ ព្រមទាំងធ្វើការអប់រំដល់ភ្នាក់ងារពិន័យអំពីយន្តការ និងនីតិវិធីនៃការចុះអនុវត្តឱ្យមានប្រសិទ្ធភាព។

**៧. យន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍**

ក- ក្នុងករណីមិនអនុវត្តតាមការណែនាំ ឬក៏ប្រព្រឹត្តល្មើសនឹងចំណុចណាមួយខាងលើ ម្ចាស់ទីតាំង និងក្រុមហ៊ុនផ្តល់សេវាកម្មទាំងអស់នៅក្នុងចំណុច ១, ២ និង ៣ នៃសេចក្តីណែនាំនេះ នឹងត្រូវទទួលការពិន័យអន្តរការណ៍ដូចខាងក្រោម៖

- ពិន័យជាប្រាក់ចាប់ពី ១០.០០០រៀល ដល់ ២.០០០.០០០រៀល (ចាប់ពីមួយម៉ឺនរៀល ដល់ពីរលានរៀល) ដូចមានចែងក្នុងមាត្រា ៣៩-៤៩ នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន"
- ពិន័យជាប្រាក់ចាប់ពី ១.០០០.០០០រៀល ដល់ ៥០.០០០.០០០រៀល (ចាប់ពីមួយលានរៀល ដល់ហាសិបលានរៀល) ឡើងទៅ នឹងត្រូវបិទអាជីវកម្ម ឬផ្អាកការដ្ឋានសាងសង់ជាបណ្តោះអាសន្ន ក្នុងករណីធ្ងន់ធ្ងរ ដែលមន្ត្រីជំនាញពិនិត្យឃើញថាមានការបង្កផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ដូចមានចែងនៅក្នុងមាត្រា២០-២២ នៃច្បាប់ស្តីពី "កិច្ចការពារបរិស្ថាន និងការ

គ្រប់គ្រងផនជានធម្មជាតិ" ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ន.ស/រ.ក.ម/១២៩៦ /៣៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

- ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន
- ចំពោះបុគ្គលណា ដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះនៅក្នុងរយៈពេល ៣០ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី ៦០ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល ៩០ថ្ងៃ ត្រូវរៀបចំឯកសារប្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

ខ- មន្ទីរបរិស្ថានរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ ភ្នាក់ងារអនាម័យ និងស្ថាប័នមានសមត្ថកិច្ចនានា ជាអ្នកអនុវត្តវិធានការពិន័យអន្តរការណ៍ខាងលើ ចំពោះម្ចាស់ទីតាំង ឬបុគ្គលណាដែលបានអនុវត្តខុសនឹងសេចក្តីណែនាំនេះ។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ប្រធានមន្ទីរបរិស្ថានរាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១២ ប្រធានមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលជាប្រជាពលរដ្ឋ ម្ចាស់ទីតាំង ឬអ្នកទទួលខុសត្រូវ (ក្នុងចំណុច ១ និង ២) ប្រធានក្រុមហ៊ុនផ្តល់សេវាកម្មសំរាម សំណល់រឹង (ក្នុងចំណុច៣) នៅក្នុងរាជធានីភ្នំពេញទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យបានម៉ឺងម៉ាត់ ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible]ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ. ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៩
**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
"ដើម្បីសហការ"
- រដ្ឋបាលខណ្ឌទាំង១២
- មន្ទីរ-អង្គភាពជំនាញចំណុះរដ្ឋបាលរាជធានីភ្នំពេញ
- ក្នុងចំណុច ១, ២ និង ៣
"ដើម្បីអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
"ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ ឯកសារ

# ឧបសម្ព័ន្ធទី៣

# សារាចរអន្តរក្រសួងស្តីពី

# ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រង

# សំរាម សំណល់រឹងទីប្រជុំជន

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងបរិស្ថាន** | **ក្រសួងមហាផ្ទៃ**

លេខៈ ១០៧០ ស.ជ.ណ.ប.ស្ល

# សារាចរអន្តរក្រសួង
## ស្តីពី
## ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាព សាធារណៈ និងបរិស្ថាន រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ អនុក្រឹត្យនេះមានគោលដៅប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅរដ្ឋបាលខណ្ឌ ដែលជារបត់នៃការគ្រប់គ្រងថ្មីមួយស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

ដើម្បីធានាបាននូវការអនុវត្តអនុក្រឹត្យនេះ ប្រកបដោយភាពរលូន ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក៏ដូចជាសំដៅកាត់បន្ថយបញ្ហាប្រឈមនានាពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលកំពុងកើតមាននៅតាមបណ្តាទីប្រជុំជនរាជធានី ខេត្ត ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានសូមធ្វើការណែនាំការអនុវត្តមួយចំនួនដូចខាងក្រោម ៖

**១. ថ្នាក់ជាតិ៖**

ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំបង្កើតក្រុមការងារអន្តរក្រសួងមួយដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឲ្យរដ្ឋបាលខណ្ឌ។

ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម៖

- រៀបចំការផ្សព្វផ្សាយអនុក្រឹត្យ និងលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចុះសិក្សា ប្រមូលព័ត៌មាន និងរៀបចំផែនការដើម្បីសម្របសម្រួលដល់ការផ្ទេរ និងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ពិនិត្យតាមដាន វាយតម្លៃ និងរៀបចំសិក្ខាសាលាដើម្បីឆ្លុះបញ្ចាំង និងដកស្រង់បទពិសោធន៍លើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- រៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនានាអំពីការអនុវត្តអនុក្រឹត្យនេះ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

**២. រដ្ឋបាលរាជធានី ត្រូវ៖**

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលខណ្ឌ សង្កាត់ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីពិនិត្យលទ្ធភាពក្នុងការផ្ទេរប្រតិភូកម្មទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងសង្កាត់នូវមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមួយផ្នែក ឬទាំងស្រុង ដោយភ្ជាប់ជាមួយធនធាន មធ្យោបាយ និងសម្ភារ

- ពិនិត្យការអនុវត្តកិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីធ្វើការកែសម្រួលកិច្ចសន្យា ដោយពិនិត្យលទ្ធភាពក្នុងការផ្ទេរការអនុវត្តកិច្ចសន្យាទៅឱ្យរដ្ឋបាលខណ្ឌឱ្យស្របទៅនឹងតម្រូវការជាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការសហការចូលរួមពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ

- ចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូលនិងដឹកជញ្ជូន

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងបម្រុងទុកសម្រាប់រៀបចំទីលាន ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងរាជធានី និងខេត្តដែលមានព្រំប្រទល់ជាប់គ្នា

- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដូចដូចមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

**៣. រដ្ឋបាលខេត្ត ត្រូវ៖**

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទីភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយត្រូវពិនិត្យ និងបែងចែកធនធានមធ្យោបាយ និងសម្ភារដែលបាននិងកំពុងប្រើប្រាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យ

រដ្ឋបាលក្រុង ស្រុក

- ពិនិត្យការអនុវត្តកិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលបាន និងកំពុងអនុវត្ត និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីកែសម្រួលកិច្ចសន្យា និងផ្ទេរការចុះកិច្ចសន្យា និងការគ្រប់គ្រងការអនុវត្តកិច្ចសន្យាទៅឱ្យរដ្ឋបាលក្រុង ស្រុកឱ្យស្របទៅនឹងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- ណែនាំ សម្របសម្រួល និងជំរុញដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការសហការចូលរួមពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ

- ជំរុញ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុកក្នុងការពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងការសិក្សាស្វែងរកទីតាំងសម្រាប់រៀបចំទីលាន ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងក្រុង ស្រុកដែលមានព្រំប្រទល់ជាប់គ្នា

- តាមដាន ត្រួតពិនិត្យការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដូចមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

## ៤. រដ្ឋបាលខណ្ឌ សង្កាត់ក្នុងរាជធានី៖

- រដ្ឋបាលខណ្ឌត្រូវផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន រដ្ឋបាលសង្កាត់ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឲ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលរាជធានី

- រដ្ឋបាលសង្កាត់ត្រូវបន្តផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងដល់រដ្ឋបាលរបស់ខ្លួន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ ត្រូវអនុវត្តតួនាទី ភារកិច្ចផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលរាជធានី។

## ៥. រដ្ឋបាលក្រុង ស្រុក ត្រូវ៖

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន រដ្ឋបាលឃុំ សង្កាត់ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣

- ពិនិត្យលទ្ធភាពក្នុងការធ្វើប្រតិភូកម្មមុខងារមួយផ្នែកនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់

- សហការពិនិត្យលើការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន

ពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីកែសម្រួលកិច្ចសន្យាឱ្យស្របទៅនឹងតម្រូវការជាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- ក្នុងករណីមិនទាន់មានសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវរៀបចំឱ្យមានសេវាគ្រប់គ្រងនេះ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- សិក្សាឱ្យបានច្បាស់លាស់ពីស្ថានភាពនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានជាអាទិ៍ប្រភេទ ប្រភព និងបរិមាណសំណល់

- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយមន្ទីរ និងអង្គភាពជំនាញ រួមជាមួយការលើកកម្ពស់ការកាត់បន្ថយបរិមាណសំណល់ដែលត្រូវបានបង្កើត និងត្រូវបានបោះបង់ចោល

- ផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយលើកកម្ពស់ការញែកនៅនឹងប្រភព ការវេចខ្ចប់ និងការបញ្ចេញឱ្យបានត្រឹមត្រូវនូវសំរាម សំណល់រឹងទីប្រជុំជន និងការចូលរួមកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន

- ចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីជានាប្រសិទ្ធភាពក្នុងប្រមូល និងដឹកជញ្ជូន

- សហការជាមួយរដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពជំនាញដើម្បីសិក្សាពីស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងសម្រាប់រៀបចំទីលានថ្មីដោយផ្តោតលើទីតាំងដែលមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងក្រុង ស្រុកដែលមានព្រំប្រទល់ជាប់គ្នា ដើម្បីស្នើសុំការពិនិត្យ សម្រេចពីរដ្ឋបាលខេត្ត និងក្រសួងបរិស្ថាន

- អនុវត្តនូវតួនាទី និងភារកិច្ចផ្សេងទៀតដូចដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១១៣។

**៦. រដ្ឋបាលឃុំក្នុងស្រុក និងសង្កាត់ក្នុងក្រុង ត្រូវ៖**

- បន្តផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដើម្បីឱ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដែលមានចែងក្នុងអនុក្រឹត្យ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មពីរដ្ឋបាលក្រុង ស្រុក

- អនុវត្តតួនាទី ភារកិច្ចផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មពីរដ្ឋបាលក្រុង ស្រុក។

**៧. មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវ៖**

- ផ្សព្វផ្សាយដល់មន្ត្រី បុគ្គលិកក្នុងអង្គភាពរបស់ខ្លួនអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ចូលរួមសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាពដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ

- ចូលរួមពិនិត្យយន្តការ និងកិច្ចសន្យាក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ ដើម្បីឲ្យស្របតាមស្មារតីអនុក្រឹត្យលេខ១១៣

- ចូលរួម និងសហការក្នុងការសិក្សាអំពីស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលកំពុងអនុវត្ត និងអំពីលទ្ធភាពអនុវត្តការញែកសំរាម សំណល់រឹងដែលអាចកែច្នៃ ឬ អាចទាញយកធនធានបាន និងការកាត់បន្ថយការបង្កើតសំណល់

- ចូលរួមសហការរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងសំណើឬ គម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ចូលរួមសហការសិក្សា និងផ្តល់យោបល់លើការស្វែងរកទីតាំងសម្រាប់រៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញការអនុវត្តវិធានការច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- អនុវត្តតួនាទី ភារកិច្ចផ្សេងទៀត ដូចមានចែងក្នុងអនុក្រឹត្យលេខ១១៣។

ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរបរិស្ថានរាជធានី ខេត្តត្រូវសហការផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងមហាផ្ទៃ** | **ក្រសួងបរិស្ថាន** |
| **សម្តេចក្រឡាហោម ស ខេង** | **សាយ សំអាល់** |

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៥

# អនុក្រឹត្យស្តីពី

# ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣៥ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសុវត្ថិភាព សុខភាពសាធារណៈ និងការអភិរក្សជីវចម្រុះ។



KO

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- រៀបចំ កែសម្រួល និងពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ប្រគល់មុខងារប្រតិបត្តិការ និងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ
- កំណត់នូវវិធានការចាំបាច់នានាដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ អំពីការប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន ក្នុងការអភិវឌ្ឍន៍ ឬវិនិយោគសាងសង់ ប្រតិបត្តិការនិងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះ ពុំមានវិសាលភាពអនុវត្តលើការគ្រប់គ្រងសំណល់រាវឧស្សាហកម្មឡើយ។

**មាត្រា៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- ទឹកកខ្វក់ សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់ រួចមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅដ្ឋាន បុរីលំនៅដ្ឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និង តំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត
- សំណល់រាវ សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម
- ប្រព័ន្ធលូ សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន៖ តំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ(បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)
- បណ្តាញលូរួម សំដៅដល់បណ្តាញលូប្រមូល និងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងជាមួយគ្នា។



kz

- បណ្តាញលូដាច់ដោយឡែក សំដៅដល់បណ្តាញលូប្រមូលនិងបង្ហូរទឹកកខ្វក់ និងទឹកភ្លៀងញែកដាច់ផ្សេងពីគ្នា
- បណ្តាញលូមេ សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងអាងស្តុក ស្ថានីយ៍បូម ឬស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់
- បណ្តាញលូមេរង សំដៅដល់ប្រព័ន្ធលូដែលភ្ជាប់ទៅនឹងបណ្តាញលូមេ និងទទួលទឹកកខ្វក់ពីបណ្តាញលូខ្នែង
- បណ្តាញលូខ្នែង សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងបណ្តាញលូមេ ឬបណ្តាញលូ មេរង។
- បណ្តាញលូខ្នែងរង សំដៅដល់បណ្តាញលូដែលភ្ជាប់ទៅនឹងបណ្តាញលូខ្នែង និងទទួលទឹកកខ្វក់ពីទីតាំង ឬប្រភពបញ្ចេញ
- ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយ៍បូមទឹកលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួមតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ
- អាងស្តុកធម្មជាតិ សំដៅដល់អាងស្តុកទឹក បឹង ប្រឡាយ ឬស្រះសាធារណៈ ដែលបានប្រើប្រាស់សម្រាប់ស្តុក និងសម្អាតទឹកកខ្វក់តាមលក្ខណៈធម្មជាតិ
- ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ
- តំបន់ទឹកសាធារណៈ សំដៅដល់ប្រភពទឹកសម្រាប់ប្រើប្រាស់ជាសាធារណៈ ដូចជា ទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ បឹង ស្រះ ត្រពាំង សមុទ្រ ដៃសមុទ្រ ពាម ប្រព័ន្ធប្រឡាយធារាសាស្ត្រ ទឹកក្រោមដី។ល។
- ទីប្រជុំជន សំដៅដល់ទីប្រជុំជនរាជធានី ទីប្រជុំជនខេត្ត ទីប្រជុំជនក្រុង ទីប្រជុំជនស្រុក និងទីប្រជុំជនខណ្ឌ
- ទីតាំង សំដៅដល់លំនៅដ្ឋាន លំនៅដ្ឋានប្រមូលផ្តុំ បុរីលំនៅដ្ឋាន អគារអាជីវកម្ម និងទីក្រុងរណប
- លំនៅដ្ឋាន សំដៅដល់ផ្ទះស្នាក់នៅជាលក្ខណៈឯកជនផ្ទាល់ខ្លួន
- លំនៅដ្ឋានប្រមូលផ្តុំ សំដៅដល់ផ្ទះស្នាក់នៅដែលទទួលសិទ្ធិកាន់កាប់បន្តពីអាជីវកម្មសាងសង់លំនៅដ្ឋានលក់ តែពុំមានអ្នកទទួលខុសត្រូវរួម
- បុរីលំនៅដ្ឋាន សំដៅដល់តំបន់អភិវឌ្ឍន៍លំនៅដ្ឋានប្រមូលផ្តុំដែលមានម្ចាស់បុរីនៅបន្តទទួលខុសត្រូវរួម
- អគារអាជីវកម្ម សំដៅដល់ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋាន ទីផ្សារ ផ្សារទំនើប អគារពាណិជ្ជកម្ម អគារសេវាកម្ម ទីសត្តឃាត អាផាតមែន និងអគារខុនដូ



ㄓ

- ទីក្រុងរណប សំដៅដល់តំបន់អភិវឌ្ឍន៍ចម្រុះ រួមមាន៖ លំនៅដ្ឋានទំនើប អាផាតមែន អគារខុនដូ ផ្សារទំនើប សណ្ឋាគារ ភោជនីយដ្ឋាន អគារពាណិជ្ជកម្ម អគារសេវាកម្ម មណ្ឌលកំសាន្ត។ល។
- អាងសិបទិច សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ
- កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ សំដៅដល់ការបង់ថ្លៃសម្រាប់ការថែទាំ ជួសជុល ស្តារ និងពង្រីកអណ្តូងលូ បណ្តាញលូ ប្រឡាយចំហ អាងស្តុក និងដំណើរការស្ថានីយ៍បូមទឹកកខ្វក់
- កម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ សំដៅដល់ការបង់ថ្លៃសម្រាប់ការសម្អាតទឹកកខ្វក់
- សំណល់ភក់ សំដៅដល់កាកសំណល់ពីអាងសិបទិច ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត សំដៅដល់ទីកន្លែងសម្រាប់អ្នកទេសចរទៅទស្សនា និងសម្រាកលំហែរកាយ ដែលមានផ្តល់នូវសេវាម្ហូបអាហារ ភេសជ្ជៈ កន្លែងស្នាក់ កីឡា កម្សាន្ត និងទិញទំនិញ។ល។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥.-**

ក្រសួងសាធារណការ និងដឹកជញ្ជូនមានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងការងារបច្ចេកទេសប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ និងផែនការអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច
- រៀបចំបទដ្ឋានបច្ចេកទេសស្តីពីការសាងសង់ គ្រប់គ្រង ប្រតិបត្តិការ និងការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជនក្នុងការវិនិយោគសាងសង់ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គាំទ្រធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើនការអប់រំ និងផ្សព្វផ្សាយដល់សាធារណជន អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទដ្ឋានបច្ចេកទេស

- សហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ជំរុញដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងប្រតិបត្តិការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សម្របសម្រួល និងកៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៦.-**

ក្រសួងបរិស្ថានមានតួនាទីដឹកនាំនយោបាយ និងកំណត់យុទ្ធសាស្ត្រអំពីការគ្រប់គ្រងទឹកកខ្វក់ និងត្រួតពិនិត្យដំណើរការប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ឬផែនការយុទ្ធសាស្ត្រ សម្រាប់គ្រប់គ្រងការបំពុលទឹកតំបន់ទឹកសាធារណៈបង្កពីការបញ្ចេញទឹកកខ្វក់
- រៀបចំស្តង់ដាបញ្ចេញទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងស្តង់ដាបញ្ចេញទឹកសម្អាតរួច ចេញពីស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម
- ចូលរួមផ្តល់ប្រឹក្សាបច្ចេកទេសលើសំណើវិនិយោគបង្កើតប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ត្រួតពិនិត្យវាយតម្លៃការបំពាក់បរិក្ខារ ដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម និងការបញ្ចេញទឹកកខ្វក់ក្រោយការធ្វើប្រព្រឹត្តកម្ម
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនលើការងារវិនិយោគប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើនការអប់រំ និងផ្សព្វផ្សាយដល់សាធារណជនអំពីសេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងគោលដៅការពារគុណភាពបរិស្ថាន។

**មាត្រា៧.-**

ក្រសួងមហាផ្ទៃមានតួនាទីគាំទ្រ សម្របសម្រួល និងជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ



ᥫ

- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ផ្តល់ការអន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញ និងផ្តល់ការណែនាំដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងនាមអាណាព្យាបាលលើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៨.-**

រដ្ឋបាលរាជធានី ត្រូវបំពេញតួនាទីដឹកនាំគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការមេសម្រាប់អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- រៀបចំ និងគ្រប់គ្រងបណ្តាញលូមេ មេរង និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ត្រួតពិនិត្យការប្រមូលកម្រៃសេវាប្រើប្រាស់បណ្តាញលូមេ មេរង និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្ម ទឹកកខ្វក់
- អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូមេ មេរង និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូ
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស
- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូមេ មេរង និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- កៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា៩.-**

រដ្ឋបាលខណ្ឌ ត្រូវបំពេញតួនាទីប្រតិបត្តិការងារគ្រប់គ្រងបណ្តាញលូខ្នែង និងខ្នែងរងដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំបណ្តាញលូខ្នែង និងខ្នែងរង



YF

- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស
- រៀបចំ និងគ្រប់គ្រងសេវាប្រើប្រាស់បណ្តាញលូខ្មែងនិងខ្មែងរង
- ផ្តល់ការអនុញ្ញាតការស្នើសុំតភ្ជាប់បណ្តាញលូ ការស្នើសុំប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ធ្វើការតភ្ជាប់តំណលូទឹកកខ្វក់ចេញពីលំនៅដ្ឋានមកបណ្តាញលូខ្មែង និងខ្មែងរង ដោយទទួលកម្រៃសេវាកំណត់
- អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូខ្មែង និងខ្មែងរង
- អនុវត្តការប្រមូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូខ្មែង និងខ្មែងរង
- អាចធ្វើប្រតិភូកម្មលើការងារមួយផ្នែកនៃការគ្រប់គ្រង បណ្តាញលូខ្មែង និងខ្មែងរងជូនរដ្ឋបាលសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬជំរុញឱ្យមានការចូលរួមពីរដ្ឋបាលសង្កាត់ក្នុងការអនុវត្តមុខងារទាំងនេះឱ្យមានប្រសិទ្ធភាព
- កៀរគររកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធលូខ្មែង និងខ្មែងរង
- ជំរុញការអប់រំប្រជាពលរដ្ឋក្នុងការថែទាំ និងចូលរួមប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា១០.-**

រដ្ឋបាលខេត្ត ត្រូវបំពេញតួនាទីគាំទ្រ និងជំរុញប្រតិបត្តិការ ការថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោម៖

- សហការរៀបចំផែនការមេសម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅតាមទីប្រជុំជនក្រុង ស្រុក
- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំការអនុវត្តន៍វិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សម្របសម្រួលការរៀបចំសេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស
- អនុវត្ត និងសម្របសម្រួលក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងប្រព័ន្ធលូ និង ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់



ꦤ

- កៀរគរកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅតាមទីប្រជុំជនក្រុង ស្រុក។

**មាត្រា១១.-**

រដ្ឋបាលក្រុង ស្រុក ត្រូវបំពេញតួនាទីប្រតិបត្តិការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតក្នុងដែនសមត្ថកិច្ច និងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងារកសាង ជួសជុល ស្តារ ថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- អនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការអនុវត្តទណ្ឌកម្មលើបទល្មើស
- ធ្វើការតភ្ជាប់តំណលូទឹកកខ្វក់ចេញពីលំនៅដ្ឋានមកបណ្តាញលូខ្វែង និង ខ្វែងរងដោយទទួលកម្រៃសេវាកំណត់
- រៀបចំ និងគ្រប់គ្រងសេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ផ្តល់ការអនុញ្ញាតការស្នើសុំតភ្ជាប់បណ្តាញលូ ការសុំប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- អនុវត្តការងារកសាង ជួសជុល ស្តារ និងថែទាំប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- អនុវត្តការប្រមូលកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញការអប់រំប្រជាពលរដ្ឋក្នុងការថែទាំ និងចូលរួមប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- គ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសម្រាប់ការថែទាំ និងការអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- អាចធ្វើប្រតិភូកម្មលើការងារមួយផ្នែកនៃការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជូនរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬជំរុញឱ្យមានការចូលរួមពីរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តមុខងារទាំងនេះឱ្យមានប្រសិទ្ធភាព
- កៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារក្នុងការអភិវឌ្ឍប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា១២.-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត សហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធ

ប្រព្រឹត្តកម្មទឹកកខ្វក់ និងមានភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំផែនការមេសម្រាប់គ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ពិនិត្យផ្តល់យោបល់ការស្នើសុំតភ្ជាប់បណ្តាញលូ ការប្រើប្រាស់សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងចូលរួមសហការអនុវត្តទណ្ឌកម្មលើបទល្មើស
- លើកកម្ពស់ការយល់ដឹងប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាន តាមរយៈការអប់រំផ្សព្វផ្សាយពីការប្រើប្រាស់សេវាប្រព័ន្ធលូ និងសេវាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាពនិងដំណើរការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា១៣.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត សហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការងារគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញក្រោយប្រព្រឹត្តកម្ម និងមានភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំផែនការមេសម្រាប់គ្រប់គ្រងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើគម្រោងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងការបញ្ចេញ
- ផ្តល់យោបល់លើការស្នើសុំការបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប តំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ឬតំបន់ទឹកសាធារណៈ
- ជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបញ្ចេញទឹកកខ្វក់ ឬការបំពុលទឹក និងចូលរួមសហការអនុវត្តទណ្ឌកម្មលើបទល្មើស
- លើកកម្ពស់ការយល់ដឹងប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាន តាមរយៈការអប់រំផ្សព្វផ្សាយពីការគ្រប់គ្រងទឹកកខ្វក់
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីការគ្រប់គ្រង និងការបញ្ចេញទឹកកខ្វក់។

## ជំពូកទី៣

## វិធានការលើការគ្រប់គ្រងទឹកកខ្វក់ ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

**មាត្រា១៤.-**

ស្តង់ដានៃការបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន



ល2

ឬមណ្ឌលកំសាន្ត ចូលទៅក្នុងប្រព័ន្ធលូដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម គឺមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

ស្តង់ដានៃការបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្តដែលបានឆ្លងកាត់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយផ្ទាល់ ឬចូលទៅក្នុងប្រព័ន្ធលូមុនការធ្លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈ គឺមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា១៥.-**

ក្នុងករណីចាំបាច់ ដើម្បីជានាការការពារសុខភាពសាធារណៈ និងអភិរក្សជីវចម្រុះនៃតំបន់ទឹកសាធារណៈណាមួយ ក្រសួងបរិស្ថានអាចពិនិត្យសម្រេចរៀបចំស្តង់ដានៃការបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយផ្ទាល់ ឬចូលទៅក្នុងប្រព័ន្ធលូមុនការធ្លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយឡែកពីស្តង់ដាដែលមានចែងក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ។

ស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែក ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា១៦.-**

ម្ចាស់លំនៅដ្ឋាន និងលំនៅដ្ឋានប្រមូលផ្តុំ ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖

- រៀបចំអាងសិបទិចអនុលោមតាមលិខិតអនុញ្ញាតសាងសង់
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ
- បង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ក្នុងករណីដែលទឹកកខ្វក់ក្នុងតំបន់ទីប្រជុំជនត្រូវបានប្រមូលទៅសម្អាតនៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។

**មាត្រា១៧.-**

ម្ចាស់អគារអាជីវកម្មដែលទីតាំងស្ថិតនៅក្នុងតំបន់ទីប្រជុំជនមានស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖

- រៀបចំអាងសិបទិចរួមអនុលោមតាមលិខិតអនុញ្ញាតសាងសង់
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូ ចូលទៅក្នុងប្រព័ន្ធលូដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូ ដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម

- បង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់រួម។

**មាត្រា ១៨.-**

ម្ចាស់អគារអាជីវកម្ម ដែលទីតាំងស្ថិតនៅក្នុងតំបន់ទីប្រជុំជនពុំមានស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖

- រៀបចំអាងសិបទិចរួមអនុលោមតាមលិខិតអនុញ្ញាតសាងសង់
- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ឱ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២នៃ អនុក្រឹត្យនេះ និង/ឬស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែកដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន មុននឹងបញ្ចេញចូលទៅក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ក្នុងករណីត្រូវប្រើប្រាស់សម្រាប់ការបញ្ចេញទឹកកខ្វក់ដែលសម្អាតរួច
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ចូលក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ។

**មាត្រា ១៩.-**

ម្ចាស់អគារអាជីវកម្ម និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ដែលមានទីតាំងនៅតាមដងឬដីចំណីសមុទ្រ ទន្លេ ស្ទឹង ព្រែក បឹង ។ល។ ឬស្ថិតនៅលើផ្ទៃទឹក ដែលទទួលបានសិទ្ធិអាជីវកម្មស្របច្បាប់ ត្រូវទទួលខុសត្រូវគ្រប់គ្រងទឹកកខ្វក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួន ដូចខាងក្រោម៖

- មិនធ្វើការបង្ហូរទឹកកខ្វក់ ដែលមិនទាន់បានឆ្លងកាត់ប្រព្រឹត្តកម្មសម្អាតចូលទៅក្នុងតំបន់ទឹកសាធារណៈ
- រៀបចំប្រព័ន្ធស្តុកទឹកកខ្វក់រួម សម្រាប់ការបូមបញ្ចេញទៅក្នុងប្រព័ន្ធលូសាធារណៈ ឬ ដឹកជញ្ជូនចេញយកទៅសម្អាតនៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម តាមការតម្រូវរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ
- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ឱ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ នៃ អនុក្រឹត្យនេះ និង/ឬស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែកដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន មុននឹងបញ្ចេញចូលទៅក្នុងតំបន់ទឹកសាធារណៈ
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ដែលសម្អាតរួចចូលទៅក្នុងតំបន់ទឹកសាធារណៈ។

**មាត្រា ២០.-**

ម្ចាស់បុរីលំនៅដ្ឋាន និងទីក្រុងរណប ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចខាងក្រោម៖



VR

- ធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ និងធ្វើការសម្អាតទឹកកខ្វក់ក្នុងតំបន់គ្រប់គ្រងរបស់ខ្លួនឱ្យឆ្លើយតបទៅនឹងស្តង់ដានៃការបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ និង/ឬស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែក ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន មុននឹងបញ្ចេញចូលទៅក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ
- ស្នើសុំធ្វើការតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈ និងបង់កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ក្នុងករណីត្រូវការប្រើប្រាស់សម្រាប់ការបញ្ចេញទឹកកខ្វក់ដែលសម្អាតរួច
- ស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ចូលទៅក្នុងប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ។

**មាត្រា ២១.-**

បន្ថែមលើកាតព្វកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់របស់ខ្លួន ដូចមានចែងក្នុងមាត្រាទី២០ នៃអនុក្រឹត្យនេះ ម្ចាស់គម្រោងអភិវឌ្ឍន៍នៃសំណង់បុរីលំនៅដ្ឋាន ឬទីក្រុងរណបថ្មី ត្រូវទទួលខុសត្រូវរៀបចំបណ្តាញលូទឹកកខ្វក់ដាច់ដោយឡែកពីបណ្តាញលូទឹកភ្លៀងនៅក្នុងតំបន់របស់ខ្លួន។

**មាត្រា ២២.-**

ការសុំតភ្ជាប់បណ្តាញលូពីទីតាំងណាមួយចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវមានការអនុញ្ញាតពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយត្រូវមានការផ្តល់យោបល់បច្ចេកទេសពី៖

- ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ ចំពោះទីតាំងមានបរិវេណក្រោម ៣០.០០០ ម៉ែត្រក្រឡា ឬផ្ទៃក្រឡាអគារតូចជាង ៥.០០០ ម៉ែត្រក្រឡា
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ចំពោះទីតាំងមានបរិវេណចាប់ពី ៣០.០០០ ម៉ែត្រក្រឡាដល់ ១០០.០០០ ម៉ែត្រក្រឡា ឬផ្ទៃក្រឡាអគារចាប់ពី ៥.០០០ ម៉ែត្រក្រឡា ដល់ ១៥.០០០ ម៉ែត្រក្រឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន ចំពោះទីតាំងមានផ្ទៃក្រឡាលើសពី ១០០.០០០ ម៉ែត្រក្រឡា ឬផ្ទៃក្រឡាអគារធំជាង ១៥.០០០ ម៉ែត្រក្រឡា។

យន្តការនៃការផ្តល់សេវាពាក់ព័ន្ធនឹងការស្នើសុំតភ្ជាប់បណ្តាញលូ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

នីតិវិធីលម្អិតក្នុងការស្នើសុំតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ដូចមានចែងតម្រូវក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ២៣.-**

ការសុំបញ្ចេញចោលទឹកកខ្វក់ពីទីតាំងអាជីវកម្ម ដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវមានការ



ꟾꟾꝛ

អនុញ្ញាតពីរដ្ឋបាលរាជធានី ខេត្ត ដោយមានការផ្តល់យោបល់ពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

ការសុំបញ្ចេញចោលទឹកកខ្វក់ពីទីតាំងបុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ខេត្ត ដោយមានការផ្តល់យោបល់ពីមន្ទីរបរិស្ថានរាជធានី ខេត្ត និងឬការផ្តល់យោបល់បច្ចេកទេសពីក្រសួងបរិស្ថាន។

យន្តការនៃការផ្តល់សេវាពាក់ព័ន្ធនឹងការស្នើសុំបញ្ចេញចោលទឹកកខ្វក់ពីទីតាំងអាជីវកម្ម ទីតាំងបុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់ទីរមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

នីតិវិធីលម្អិតក្នុងការស្នើសុំលិខិតអនុញ្ញាតបញ្ចេញចោលទឹកកខ្វក់ ឬទឹកកខ្វក់ដែលបានសម្អាតរួចចូលទៅក្នុងបណ្តាញលូ ឬតំបន់ទឹកសាធារណៈ ដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## មាត្រា ២៤.-

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់ក្នុងការ៖

- ទប់ស្កាត់ការរំលោភយកដីសាធារណៈនៃប្រព័ន្ធលូ ឬការសាងសង់សំណង់ផ្សេងៗដែលធ្វើឱ្យខូចខាតប្រព័ន្ធលូ ឬរាំងស្ទះដល់ចរន្តហូរនៃប្រព័ន្ធលូ
- ទប់ស្កាត់ការរំលោភយកដីសាធារណៈនៃអាងស្តុកធម្មជាតិ ឬការចាក់ដីលុបអាងស្តុកធម្មជាតិដែលធ្វើឱ្យបាត់បង់សមត្ថភាពស្តុក ឬសម្អាតទឹកកខ្វក់
- សិក្សា និងធ្វើការបង្វែរប្រព័ន្ធលូបញ្ចេញទឹកកខ្វក់ទីប្រជុំជនដែលហូរចូលផ្ទាល់ទៅក្នុងតំបន់ទឹកសាធារណៈ ឱ្យហូរឆ្លងកាត់អាងស្តុកធម្មជាតិ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជាមុន
- រៀបចំផែនការ និងជំរុញការអនុវត្តការស្តារអាងស្តុកធម្មជាតិ ដើម្បីធានាសមត្ថភាពស្តុក និងសម្អាតតាមលក្ខណៈធម្មជាតិនៃទឹកកខ្វក់ទីប្រជុំជន
- ធ្វើការគ្រប់គ្រង និងដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ដើម្បីធានាគុណភាពទឹកកខ្វក់សម្អាតរួចដែលត្រូវបញ្ចេញ គឺឆ្លើយតបនឹងស្តង់ដារបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ និង/ឬស្តង់ដានៃការបញ្ចេញទឹកកខ្វក់ដោយឡែក ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## មាត្រា ២៥.-

ហាមឃាត់ជាដាច់ខាត ការចាក់សំរាម សំណល់រឹង សំណល់ប្រេងឥន្ធនៈ សារធាតុគីមី សំណល់កកពីអាងសិបទិច ឬពីប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវរោងចក្រ ចូលទៅក្នុងប្រព័ន្ធលូ អាងស្តុកធម្មជាតិ ឬចូលទៅក្នុងតំបន់ទឹកសាធារណៈ។

## ជំពូកទី៤
## សេវាប្រើប្រាស់ប្រព័ន្ធលូ និងសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់

**មាត្រា២៦.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រង និងការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធលូដែលស្ថិតក្នុងដែនសមត្ថកិច្ច ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសុវត្ថិភាពបរិស្ថាន។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចផ្តល់សិទ្ធិការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធលូ ទៅឱ្យអង្គភាពជំនាញ ឬក្រុមហ៊ុនឯកជនជាអ្នកទទួលអនុវត្តជំនួស។

ការប្រគល់សិទ្ធិការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធលូទៅឱ្យក្រុមហ៊ុនឯកជន ត្រូវធ្វើឡើងស្របតាមនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា២៧.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ត្រូវទទួលខុសត្រូវលើការគ្រប់គ្រង និងការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដែលស្ថិតក្នុងដែនសមត្ថកិច្ចឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសុវត្ថិភាពបរិស្ថាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក អាចផ្តល់សិទ្ធិការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ទៅឱ្យអង្គភាពជំនាញ ឬក្រុមហ៊ុនឯកជនជាអ្នកទទួលអនុវត្តជំនួស។

ការប្រគល់សិទ្ធិការងារផ្តល់សេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ទៅឱ្យក្រុមហ៊ុនឯកជន ត្រូវធ្វើឡើងស្របតាមនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា២៨.-**

ការកំណត់នីតិវិធី យន្តការ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ និងកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងបរិស្ថាន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៩.-**

ចំណូលដែលប្រមូលបានពីកម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ ត្រូវបង់ចូលក្នុងចំណូលផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍន៍ ជួលជុល ស្តារ ឬថែទាំប្រព័ន្ធលូ។

ចំណូលដែលប្រមូលបានពីកម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវបង់ចូលក្នុងចំណូលផ្ទាល់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក សម្រាប់ប្រើប្រាស់ក្នុងដំណើរការ ជួលជុល ថែទាំប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និងសម្រាប់ការតាមដានត្រួតពិនិត្យគុណភាពទឹកកខ្វក់ដែលសម្អាតរួច។

**មាត្រា៣០.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យលទ្ធភាពផ្តល់កញ្ចប់ថវិកាបន្ថែមទៅដល់រដ្ឋបាលថ្នាក់ក្រោម



ck

ជាតិសម្រាប់គាំទ្រអនុវត្តការងារគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ។

## ជំពូកទី៥
## ការត្រួតពិនិត្យ និងអធិការកិច្ច

**មាត្រា៣១.-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត និងការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើការត្រួតពិនិត្យលើការងារតភ្ជាប់លូ ឬបណ្តាញលូចេញពីទីតាំង ចូលទៅក្នុងប្រព័ន្ធលូសាធារណៈដែលបានស្នើសុំនៅក្រោមបញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៣២.-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើអធិការកិច្ចលើបញ្ហាពាក់ព័ន្ធករណី៖

- ការលួចតភ្ជាប់បណ្តាញលូចូលទៅក្នុងប្រព័ន្ធលូសាធារណៈដោយពុំមានលិខិតអនុញ្ញាត
- ការបង្កឱ្យមានការខូចខាតប្រព័ន្ធលូសាធារណៈ ឬប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ឬឯកជន
- បណ្តឹងពីករណីស្ទះ ឬខូចខាតប្រព័ន្ធលូ។

**មាត្រា៣៣.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវចុះធ្វើការត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការបំពាក់បរិក្ខារ និងដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅតាមទីតាំងផ្ទាល់ និងការយកសំណាកទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តរួចមកវិភាគឱ្យបានជាប់ជាប្រចាំ។

**មាត្រា៣៤.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើអធិការកិច្ចលើបញ្ហាពាក់ព័ន្ធករណី៖

- ការលួចបញ្ចេញទឹកកខ្វក់ពីទីតាំងចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយផ្ទាល់ ឬមិនផ្ទាល់ដោយពុំមានលិខិតអនុញ្ញាត
- ការលួចបញ្ចេញទឹកកខ្វក់ពីទីតាំង ដោយពុំឆ្លងកាត់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- បណ្តឹង ឬការទទួលបានព័ត៌មានពីការបំពុលតំបន់ទឹកសាធារណៈពីការបញ្ចេញទឹកកខ្វក់។

**មាត្រា៣៥.-**

មន្ត្រីដែលត្រូវបំពេញភារកិច្ចក្នុងការចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ដូចមានចែងក្នុងមាត្រា៣២ មាត្រា៣៣ មាត្រា៣៤ និងមាត្រា៣៥ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖



kr

- បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួនពេលចូលទៅក្នុងទីតាំង ដើម្បីធ្វើការត្រួតពិនិត្យឬធ្វើអធិការកិច្ច យកគំរូតាង និងកំណត់ត្រា
- ធ្វើកំណត់ហេតុ ឬរបាយការណ៍នៅទីតាំងដែលធ្វើការត្រួតពិត្យ ឬធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួម
- ត្រូវធ្វើការសាកសួរ ឬតម្រូវឱ្យម្ចាស់ទីតាំងឬអ្នកទទួលខុសត្រូវផ្តល់ព័ត៌មាន ឬឯកសារចាំបាច់ពាក់ព័ន្ធនានា សម្រាប់ប្រើប្រាស់ក្នុងការធ្វើកំណត់ហេតុ ឬរបាយការណ៍ និងជាវត្ថុតាង
- ត្រូវផ្តល់ច្បាប់ចំលងនៃកំណត់ហេតុ ឬរបាយការណ៍ឱ្យម្ចាស់ទីតាំង ឬអ្នកទទួលខុសត្រូវ អ្នកចូលរួមពីស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ សាក្សី និងរក្សាច្បាប់ដើមសម្រាប់ប្រើប្រាស់ក្នុងនីតិវិធីបន្ត។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា៣៦.-**

ទណ្ឌកម្មក្នុងអនុក្រឹត្យនេះ រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការតម្រូវសំណងជួសជុល ឬស្តារការខូចខាតប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការតម្រូវសំណងជួសជុល ឬស្តារការខូចខាតបរិស្ថាន
- ការពិន័យអន្តរការណ៍។

ការអនុវត្តទណ្ឌកម្មខាងលើនេះ ជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែការតម្រូវសំណងជួសជុលឬស្តារការខូចខាតបរិស្ថាន ដែលជាសមត្ថកិច្ចផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា៣៧.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេច ពីការអនុវត្តទណ្ឌកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តជំពូកនេះ មានសិទ្ធិប្តឹងតវ៉ាក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតអនុវត្តទណ្ឌកម្មចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅ៖

- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ករណីពាក់ព័ន្ធការតភ្ជាប់បណ្តាញលូ ការងារសេវាប្រើប្រាស់ប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬ
- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ករណីពាក់ព័ន្ធការស្នើសុំ និងការបញ្ចេញទឹកកខ្វក់ពីទីតាំង។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវធ្វើការឆ្លើយតបនឹងបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ថ្ងៃទទួលបានពាក្យបណ្តឹងតវ៉ា។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬ រដ្ឋមន្ត្រីក្រសួងបរិស្ថានខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៣៨.-**

ការពិន័យអន្តរការណ៍ អាចអនុវត្តបានក្នុងករណីដែលជនល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ស្របតាមទោសប្បញ្ញត្តិនៃអនុក្រឹត្យនេះ។ ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរលត់បណ្តឹងអាជ្ញា ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងនៃបទល្មើសហើយបញ្ជូនទៅតុលាការតាមនីតិវិធី ។ ក្នុងករណីនេះ ទោសពិន័យអន្តរការណ៍ ត្រូវក្លាយជាទោសពិន័យជាប្រាក់។

**មាត្រា៣៩.-**

នីតិវិធីសម្រាប់ការចាត់ចែងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ចំពោះអំពើល្មើសដែលកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌។

**មាត្រា៤០.-**

លំនៅដ្ឋាន និងលំនៅដ្ឋានប្រមូលផ្តុំ ដែលតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈដោយពុំបានសុំការអនុញ្ញាត ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន)រៀល ទៅ ១០០.០០០ (ដប់ម៉ឺន)រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល។

**មាត្រា៤១.-**

លំនៅដ្ឋាន និងលំនៅដ្ឋានប្រមូលផ្តុំ ដែលពុំព្រមបង់ប្រាក់សេវាប្រើប្រាស់ប្រព័ន្ធលូ ឬសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ៣០.០០០ (បីម៉ឺន) រៀល ទៅ ១០០.០០០ (ដប់ម៉ឺន) រៀល បន្ថែមលើចំនួនប្រាក់សេវាដែលពុំទាន់បានបង់។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ ២០០.០០០ (ម្ភៃម៉ឺន) រៀល បន្ថែមលើចំនួនប្រាក់សេវាដែលពុំទាន់បានបង់។

**មាត្រា៤២.-**

អគារអាជីវកម្មដែលពុំបានរៀបចំអាងសិបទិចរួម ឬតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈ ដោយ

ពុំបានសុំការអនុញ្ញាត ឬធ្វើការបញ្ចេញចោលទឹកកខ្វក់ចូលប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ ដោយពុំបានសុំការអនុញ្ញាតដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០០.០០០ (ដប់ម៉ឺន)រៀល ទៅ ១.០០០.០០០ (មួយលាន)រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥០០.០០០ (ហាសិបម៉ឺន)រៀល ទៅ ៥.០០០.០០០ (ប្រាំលាន)រៀល។

**មាត្រា៤៣.-**

អគារអាជីវកម្ម បុរីលំនៅស្ថាន ឬទីក្រុងរណប ដែលពុំព្រមបង់ប្រាក់សេវាប្រើប្រាស់ប្រព័ន្ធលូ ឬសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្ម មួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០០.០០០ (ដប់ម៉ឺន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល បន្ថែមលើចំនួនប្រាក់សេវាដែលពុំទាន់បានបង់។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥០០.០០០ (ហាសិបម៉ឺន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល បន្ថែមលើចំនួនប្រាក់សេវាដែលពុំទាន់បានបង់។

**មាត្រា៤៤.-**

អគារអាជីវកម្ម តំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្តដែលពុំបានធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ ឬធ្វើការបញ្ចេញទឹកកខ្វក់ចូលប្រព័ន្ធលូឬតំបន់ទឹកសាធារណៈ ដែលគុណភាពមិនឆ្លើយតបនឹងស្តង់ដារបញ្ចេញទឹកកខ្វក់ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ២០០.០០០ (ម្ភៃម៉ឺន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា៤៥.-**

អគារអាជីវកម្ម តំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្តតាំងនៅតាមដង ឬជិតចំណីតំបន់ទឹកសាធារណៈ ឬស្ថិតនៅលើផ្ទៃទឹក ដែលពុំបានរៀបចំប្រព័ន្ធស្តុកទឹកកខ្វក់រួម ឬលួចធ្វើការបង្ហូរទឹកកខ្វក់ចូលតំបន់ទឹកសាធារណៈ ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖



kl

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី៥០០.០០០(ហាសិបម៉ឺន)រៀលទៅ៥.០០០.០០០(ប្រាំលាន)រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

**មាត្រា៤៦.-**

បុរីលំនៅស្ថាន ឬទីក្រុងរណបដែលពុំបានធ្វើការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងផ្ទាល់ ឬធ្វើការបញ្ចេញទឹកកខ្វក់ចូលប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈ ដែលគុណភាពមិនឆ្លើយតបនឹងស្តង់ដាបញ្ចេញទឹកកខ្វក់ ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី១.០០០.០០០ (មួយលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល។

**មាត្រា៤៧.-**

បុរីលំនៅស្ថាន ឬទីក្រុងរណបដែលធ្វើការតភ្ជាប់បណ្តាញលូចូលប្រព័ន្ធលូសាធារណៈដោយពុំបានសុំការអនុញ្ញាត ឬធ្វើការបញ្ចេញចោលទឹកកខ្វក់ចូលប្រព័ន្ធលូ ឬតំបន់ទឹកសាធារណៈដោយពុំបានសុំការអនុញ្ញាត ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ៥០០.០០០(ហាសិបម៉ឺន)រៀលទៅ៣.០០០.០០០(បីលាន) រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ឬពុំព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលការពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

**មាត្រា៤៨.-**

សំណង់បុរីលំនៅស្ថាន ឬទីក្រុងរណបជាគម្រោងអភិវឌ្ឍន៍ថ្មី ដែលពុំបានរៀបចំបណ្តាញលូទឹកកខ្វក់ដាច់ដោយឡែកពីបណ្តាញលូទឹកភ្លៀងនៅក្នុងតំបន់របស់ខ្លួន ដូចមានចែងនៅក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ១០.០០០.០០០(ដប់លាន)រៀល។

**មាត្រា៤៩.-**

បុគ្គលដែលបង្កឱ្យមានការបាក់បែក ឬខូចខាតប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬបង្កឱ្យខូចខាតបរិក្ខារគ្រឿងចក្រនៃស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ឬបង្កឱ្យមានការរអាក់រអួលនៃដំណើរការស្ថានីយ៍



14

ប្រព្រឹត្តកម្មទឹកកខ្វក់រួម ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ១០០.០០០ (ដប់ម៉ឺន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល
- ការបង់ប្រាក់សំណងជួសជុលការបាក់បែកឬខូចខាតប្រព័ន្ធលូសាធារណៈ
- ការបង់ប្រាក់សំណងជួសជុលការខូចខាតបរិក្ខារគ្រឿងចក្រនៃស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ឬការធ្វើឱ្យមានប្រក្រតីភាពនៃដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម។

**មាត្រា៥០.-**

បុគ្គលដែលយកសំរាម សំណល់រឹង សំណល់ប្រេងឥន្ធនៈ សារធាតុគីមី ឬសំណល់កក ចាក់ចូលប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវទទួលទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល
- ការប្រមូលយកសំណល់ ឬសារធាតុដែលបានចាក់ចូលចេញពីប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៥១.-**

បទប្បញ្ញត្តិនៃមាត្រា២១ នៃអនុក្រឹត្យនេះ ត្រូវយកមកអនុវត្តចំពោះរាល់គម្រោងអភិវឌ្ឍន៍នៃសំណង់បុរីលំនៅដ្ឋាន ឬទីក្រុងរណបថ្មី ដែលទទួលបានច្បាប់សាងសង់ក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

**មាត្រា៥២.-**

បទប្បញ្ញត្តិនៃជំពូកទី៦ ទោសប្បញ្ញត្តិ ត្រូវយកមកអនុវត្តចំពោះទីតាំងដែលមានការផ្តល់ជូននូវសេវាកម្មប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ។

ទីតាំងដែលមានការផ្តល់ជូននូវសេវាកម្មប្រព័ន្ធលូ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងក្រសួងសាធារណការ និងដឹកជញ្ជូន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៥៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងស្មារតីនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៨ កើត ខែ បុស្ស ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ គ.ស ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធទី១
## ស្តង់ដាបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប
## និងតំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត
## ចូលទៅក្នុងប្រព័ន្ធលូដែលភ្ជាប់ទៅស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម

| លរ | ប៉ារ៉ាម៉ែត្រ | ឯកតា | កម្រិតកំណត់ស្តង់ដា |
|---|---|---|---|
| | | | កម្រិតសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញ ចូលទៅក្នុងប្រព័ន្ធលូ |
| ១ | ប៉េហាស់ ( pH ) | - | ៥ - ៩ |
| ២ | សារធាតុរឹងដែលអណ្តែតក្នុងទឹក (TSS) | mg/l | < ១៥០ |
| ៣ | ប្រេង ឬខ្លាញ់ | mg/l | < ២០ |
| ៤ | $BOD_5$ ( 5 days at 20 $^0$C ) | mg/l | < ៨០ |
| ៥ | COD ($Cr_2O_7^{2-}$ ) | mg/l | < ១២០ |
| ៦ | សាប៊ូ (Detergents -LAS) | mg/l | < ១៥ |
| ៧ | អាសូតសរុប (T-N) | mg-N/l | < ១០ |
| ៨ | ផូស្វ័រសរុប (T-P) | mg-P/l | < ១ |
| ៩ | អាម៉ូញ៉ាក់ ( $NH_3$ ) | mg/l | < ៨ |

<u>កំណត់សំគាល់</u>

BOD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែនរលាយក្នុងទឹក ដោយពពួកមីក្រូសរីរាង្គត្រូវការខ្យល់សម្រាប់បំបែកសារធាតុសរីរាង្គ ដែលមាននៅក្នុងសំណាកនៃទឹក។

COD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែន សម្រាប់ប្រតិកម្មអុកស៊ីតកម្មបំបែកសារធាតុសរីរាង្គក្នុងទម្រង់រលាយ ឬជាគ្រាប់ ដែលមានក្នុងទឹក។

# តារាងឧបសម្ព័ន្ធទី២

## ស្តង់ដារបញ្ចេញទឹកកខ្វក់ពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់រមណីយដ្ឋាន ឬមណ្ឌលកំសាន្ត ចូលទៅក្នុងតំបន់ទឹកសាធារណៈដោយផ្ទាល់ ឬឆ្លងកាត់តាមប្រព័ន្ធលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ឯកតា | កម្រិតកំណត់ស្តង់ដា<br>កម្រិតសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញ ចូលទៅក្នុងប្រភពទឹកសាធារណៈ |
|---|---|---|---|
| ១ | ប៉េហាស់ (pH) | - | ៦ - ៨ |
| ២ | សារធាតុរឹងដែលអណ្តែតក្នុងទឹក (TSS) | mg/l | < ៨០ |
| ៣ | ប្រេង ឬខ្លាញ់ | mg/l | < ៥ |
| ៤ | $BOD_5$ ( 5 days at 20 $^0$C ) | mg/l | < ៣០ |
| ៥ | COD ( $Cr_2O_7^{2-}$ ) | mg/l | < ៥០ |
| ៦ | សាប៊ូ ( Detergents -LAS ) | mg/l | < ៧ |
| ៧ | អាស៊ូតសរុប (T-N) | mg-N/l | < ៦ |
| ៨ | ផូស្វ័រសរុប (T-P) | mg-P/l | < ០,៥ |
| ៩ | អាម៉ូញ៉ាក់ ($NH_3$) | mg/l | < ៥ |
| ១០ | កូលីហ្វម (Coliform) | MPN/100 ml | ៥០០ - ២៥០០ |

កំណត់សំគាល់

BOD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែនរលាយក្នុងទឹក ដោយពពួកមីក្រូសរីរាង្គត្រូវការខ្យល់សម្រាប់បំបែក សារធាតុសរីរាង្គ ដែលមាននៅក្នុងសំណាកនៃទឹក។

COD៖ការវាស់តម្រូវការបរិមាណអុកស៊ីសែន សម្រាប់ប្រតិកម្មអុកស៊ីតកម្មបំបែកសារធាតុសរីរាង្គក្នុងទម្រង់រលាយ ឬជាគ្រាប់ ដែលមានក្នុងទឹក។

# ឧបសម្ព័ន្ធទី៧

# រូបភាព



ទំហំធំ មុខកាត់ 5 តឹក
តំលៃ $32 ( ពណ៌ខ្មៅ ) / $34 ( ពណ៌ផ្សេងៗ )
0.50m
ធុងបរិស្ថាន
0.56m
0.40m
0.70m
ទំហំតូច មុខកាត់ 4 តឹក
តំលៃ $25 ( ពណ៌ខ្មៅ )
$27 ( ពណ៌ផ្សេងៗ )
0.40m
0.46m
0.30m
0.60m




FOOD WASTE ONLY
PAPER ONLY
PLASTIC BAG ONLY
CANS AND BOTTLES ONLY











ការឌុតសំណល់ប្លាស្ទិក
បង្ករជំងឺមហារីក
និងផ្លូវដង្ហើម
UNIDO








ទិវាបរិស្ថានពិភពលោក២០១៩












Health


បរិស្ថានកម្ពុជា